## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# អភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយ
# លក់មូលបត្រជាសាធារណៈ
# របស់ក្រុមហ៊ុន PPSEZ

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: **ថៅ គីមរ៉ុង**

**ចន សុធា**

សាស្ត្រាចារ្យណែនាំ

លោក **ស សុភាព**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១០

ឆ្នាំចូលរៀន ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ថៅ គីមរ៉ុង និង ចន សុធា ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ថ្នាក់$B_4C_2$ ជំនាន់ទី១០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ឆ្នាំសិក្សា២០១៦-២០១៧ ដែលបានចុះកម្មសិក្សានៅគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយជោគជ័យ គឺអាស្រ័យដោយមានការឧបត្ថម្ភគាំទ្រ និងជ្រោមជ្រែងយ៉ាងកក់ក្តៅពីសំណាក់មជ្ឈដ្ឋានជុំវិញជាច្រើន។ អាស្រ័យហេតុនេះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

-**លោកឪពុក និងអ្នកម្តាយ** ដែលជាអ្នកមានគុណទាំងពីរ និងបានផ្តល់កំណើតធ្វើពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅផ្តល់នូវភាពស្រលាញ់ និងការផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងកំលាំងកាយ កំលាំងចិត្ត និងផ្នែកស្មារតីព្រមទាំងផ្នែកសំភារៈដោយគ្មានការត្អូញត្អែរដល់រូបកូនក្នុងការសិក្សានៅសាកលវិទ្យាល័យ និងរហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រនេះ។

-**ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រចារ្យព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដោយសេចក្តីគោរព និងប្រកបដោយការដឹងគុណដ៏ជ្រាលជ្រៅជាទីបំផុតដែលបានខិតខំប្រឹងប្រែងអស់កំលាំងកាយ កំលាំងចិត្ត ប្រាជ្ញាស្មារតី ក្នុងការបង្ហាត់បង្រៀន ណែនាំ ផ្តល់នូវដំបូន្មានអប់រំចំណេះដឹងជាច្រើនសម្រាប់ការសិក្សា និងការអភិវឌ្ឍន៍ដល់យើងខ្ញុំ អស់រយៈពេលបួនឆ្នាំកន្លងមកនេះ។

-លោកសាស្ត្រាចារ្យ **ស សុភាព** ដែលបានណែនាំ និងចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយជ្រោមជ្រែងចង្អុលបង្ហាញក៏ដូចជាផ្តល់នូវគំនិត និងយោបល់ល្អៗក្នុងការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ ប្រមូលព័ត៌មាន និងកែសម្រួលរៀបចំរបាយការណ៍កម្មសិក្សានេះ ជាពិសេសជួយកែលំអចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើអោយរបាយការណ៍កម្មសិក្សានេះកាន់តែមានលក្ខណៈល្អប្រសើរទៀត។

-**ឯកឧត្តមអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា** ឯកឧត្តមអគ្គនាយករង លោកប្រធាននាយកដ្ឋាន លោកអនុប្រធាននាយកដ្ឋាន លោកប្រធានការិយាល័យ និងលោកអនុប្រធានការិយាល័យរួមទាំងមន្ត្រីបម្រើការនៅគណៈកម្មការមូលបត្រទាំងអស់ដែលបានអនុញ្ញាតផ្តល់លទ្ធភាព និងឱកាសអោយយើងខ្ញុំចុះកម្មសិក្សានៅគណៈកម្មការមូលបត្រកម្ពុជា។

ជាពិសេសចំពោះមន្ត្រីនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុដែលបានផ្តល់នូវឯកសារ ដំបូន្មាន គំនិត និងយោបល់ល្អៗ ក៏ដូចជាផ្តល់ភាពងាយស្រួលក្នុងការឆ្លើយតបនូវរាល់ចំងល់ផ្សេងៗ និងការយកចិត្តទុកដាក់មកលើយើងខ្ញុំអំឡុងពេលចុះកម្មសិក្សានេះដែលធ្វើឱ្យយើងខ្ញុំ ទទួលបានចំណេះដឹង និងបទពិសោធន៍ការងារនៅក្នុងវិស័យមូលបត្រ។

**-រៀមច្បង**ដែលបានបន្សល់ទុកនូវស្នាដៃ ដែលជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្ថែម និងជាប្រភពឯកសារយោងដ៏មានប្រយោជន៍ដល់យើងខ្ញុំ។

**-មិត្តរួមជំនាន់**ទាំងអស់គ្នាដែលតែងតែបានផ្តល់នូវកំលាំងចិត្ត កំលាំងកាយក្នុងការជួយជ្រោម-ជ្រែងរៀបចំរបាយការណ៍ និងអំឡុងពេលសិក្សាតែងតែឆ្លៀតពេលវេលាដ៏មានតម្លៃរបស់ពួកគាត់ក្នុងការជួយយ៉ាងយកចិត្តទុកដាក់ដល់យើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ ជូនចំពោះអ្នកមានគុណទាំងអស់អោយជួបប្រទះនូវពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាឃ្លាតឡើយ។

# អំណរគុណ

ជាបឋម យើងខ្ញុំសូមថ្លែងនូវគោរវកិច្ចចំពោះគណៈគ្រប់គ្រង លោក និងលោកស្រី សាស្ត្រា-ចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ឯកសារដែលយើងខ្ញុំបានចងក្រងឡើងនេះ គឺជាស្នាដៃដែលទទួលបានការពន្យល់ណែនាំពីសំណាក់លោកសាស្ត្រាចារ្យ **ស សុភាព** ហើយក៏ជារបាយការណ៍ការបញ្ចប់ការសិក្សារបស់យើងខ្ញុំផងដែរ។ ដោយសារតែមើលឃើញនូវសារៈសំខាន់នៃទីផ្សារមូលបត្ររួមជាមួយឆន្ទៈ ដើម្បីជាការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជាឲ្យកាន់តែមានភាពរីកចំរើន មូលហេតុនេះទើបជម្រុញឲ្យក្រុមយើងខ្ញុំសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទស្តីអំពី អភិបាលកិច្ចសាជីវកម្មនៃការបោះ-ផ្សាយមូលបត្រជាសាធារណៈរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី(PPSEZ)។

យើងខ្ញុំពិតជាសង្ឃឹមថា របាយការណ៍ដែលទាក់ទងទៅនឹងប្រធានបទស្តីអំពីអភិបាលកិច្ចសាជីវកម្មនៃការបោះផ្សាយមូលបត្រជាសាធារណៈរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSEZ) នេះនឹងផ្តល់នូវផលប្រយោជន៍សម្រាប់សិស្សនិស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ និងសាធារណៈ ជនទូទៅទាំងឡាយដែលមានចំណាប់អារម្មណ៍ និងចង់ស្វែងយល់ពីវិស័យមូលបត្រ។ ដោយសារប្រធានបទនេះជាប្រធានបទមួយថ្មីសម្រាប់ យើងខ្ញុំដូច្នេះឯកសារនេះអាចនឹងមានកំហុសឆ្គងដោយប្រការណាមួយហើយយើងខ្ញុំក៏សូមធ្វើការ អភ័យទោសទុកជាមុនផងដែរចំពោះរាល់កំហុសឆ្គងដោយអចេតនា ឬប្រការណាមួយដែលមានក្នុងរបាយការណ៍កម្មសិក្សានេះ និងរង់ចាំទទួលដោយក្តី សោមនស្សន៍រីករាយនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកអានគ្រប់រូបដើម្បីរួមចំណែកក្នុងអភិវឌ្ឍន៍ស្នាដៃនេះឲ្យកាន់តែមានភាពល្អប្រសើរឡើងថែមទៀត។

ជាទីបញ្ចប់ ក្រុមយើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវនេះនឹងអាចក្លាយជាជំនួយសម្រាប់សិស្សនិងនិស្សិតដែលមានចំណាប់អារម្មណ៍ទាក់ទងនឹងវិស័យមូលបត្រ ជាពិសេសយន្តការសម្រាប់អភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយមូលបត្រនិងការវិនិយោគលើមូលបត្រ។

# មាតិកា


បញ្ជីអក្សរកាត់......v

## សេចក្តីផ្តើម

១.លំនាំបញ្ហា...... ០១

២.ចំណោទបញ្ហា...... ០២

៣.គោលបំណងនៃការស្រាវជ្រាវ...... ០២

៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ...... ០២

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ...... ០២

៦.អត្ថប្រយោជន៍នៃការស្រាវជ្រាវ......០៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ...... ០៤

## ជំពូកទី១៖ រំលឹកទ្រឹស្តី

១.១. អភិបាលកិច្ចសាជីវកម្ម...... ០៦

១.១. ១.ប្រវត្តិនៃអភិបាលកិច្ចសាជីវកម្ម ...... ០៦

១.១.២. និយមន័យអភិបាលកិច្ចសាជីវកម្ម...... ០៦

១.១.៣.គោលដៅរបស់អភិបាលកិច្ចសាជីវកម្ម...... ០៦

១.១.៤. ហេតុអ្វីក្រុមហ៊ុនចាំបាច់មានអភិបាលកិច្ចសាជីវកម្ម?......០៧

១.១.៥.សារៈសំខាន់នៃអភិបាលកិច្ចសាជីវកម្មល្អ ......០៧

១.១.៦. ការរៀបចំអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន ...... ០៨

១.១.៦.១ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល...... ០៨

១.១.៦.២. លេខាធិការរបស់ក្រុមហ៊ុនបោះផ្សាយ និងការបង្ហាញព័តមាន...... ១០

១.១.៦.៣. ការរៀបចំនូវគោលនយោបាយ ...... ១០

១.១.៧. មុខងារ និងភារកិច្ចរបស់អភិបាល...... ១០

១.២. តើអ្វីទៅជាមូលបត្រ? ...... ១១

១.៣.ទីផ្សារមូលបត្រ...... ១១

១.៣.១.និយមន័យ...... ១១

១.៣.២.ប្រវត្តិទីផ្សារមូលបត្រ...... ១១

១.៣.៣.ទីផ្សារដំបូង (Primary Market)...... ១២

១.៣.៤. ទីផ្សារបន្ទាប់ (Secondary Market)........................................................................១៣
១.៣.៥. ទីផ្សារមូលធន (Capital Market).............................................................................១៣
១.៣.៦. ទីផ្សាររូបិយវត្ថុ (Money Market)............................................................................ ១៤
១.៤. ប្រភេទនៃមូលបត្រ....................................................................................................... ១៤
១.៥. សារៈសំខាន់របស់ទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច ..................................................... ១៥
១.៦. គុណវិបត្តិទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច.................................................................. ១៦

## ជំពូកទី២៖ វិស័យមូលបត្រនៅកម្ពុជា

២.១.តួអង្គសំខាន់ៗដែលចូលរួមក្នុងវិស័យមូលបត្រ.................................................................. ១៨
២.១.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)...................................................................... ១៨
២.១.១.១. ប្រវត្តិគណៈកម្មការមូលបត្រកម្ពុជា.......................................................................... ១៨
២.១.១.២. ចក្ខុវិស័យរបស់គណៈកម្មការមូលបត្រកម្ពុជា ............................................................ ១៨
២.១.១.៣.បេសកកម្មរបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................... ១៨
២.១.២. ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ................................................................................ ១៩
២.១.២.១. ប្រវត្តិផ្សារមូលបត្រកម្ពុជា (ផ.ម.ក.). ....................................................................... ១៩
២.១.២.២.ចក្ខុវិស័យ និងបេសកកម្ម ផ.ម.ក.......................................................................... ២០
២.១.២.៣.មុខងាររបស់ផ្សារមូលបត្រកម្ពុជា(ផ.ម.ក.)................................................................ ២០
២.១.២.៤. ក្រុមហ៊ុនមូលបត្រ (Securities Firm)...................................................................... ២៣
២.១.២.៥. ក្រុមហ៊ុនបោះផ្សាយមូលបត្រ................................................................................ ២៥
២.១.២.៦. វិនិយោគិន (Investors)......................................................................................... ២៥
២.១.២.៧. តួអង្គសំខាន់ៗផ្សេងទៀត ....................................................................................... ២៦
២.១.២.៨. លក្ខខណ្ឌនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ..................................................២៧
២.១.២.៨.១. លក្ខខណ្ឌបរិមាណ.........................................................................................៣០
២.១.២.៨.២. លក្ខខណ្ឌគុណភាព .......................................................................................៣១
២.១.២.៩. គំនូសតាងពីនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ .......... ៣២
២.១.៣. ដំណាក់កាលប៊ុកប៊ៀលឌីង (Book Building)..............................................................៣៣
២.១.៤. ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ (Subscription) ....................................................... ៣៤
២.១.៥. ការចុះបញ្ជី .........................................................................................................៣៧

## ជំពូកទី ៣៖ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី ( PPSEZ )


៣.១. ប្រវត្តិក្រុមហ៊ុន ........ ៣៨
៣.២. ទិដ្ឋភាពទូទៅរបស់ក្រុមហ៊ុន ........ ៤២
៣.៣. យុទ្ធសាស្ត្រធុរកិច្ច និងផែនការអនាគតរបស់ក្រុមហ៊ុន ........ ៤៤
៣.៣.១. សេចក្តីថ្លែងការណ៍ស្តីពីទស្សនៈវិស័យ និងបេសកកម្ម ........ ៤៤
៣.៣.២. ផែនការអនាគត ........ ៤៤
៣.៣.៣. យុទ្ធសាស្ត្រធុរកិច្ច ........ ៤៥
៣.៤. រចនាសម្ព័ន្ធនៃគណៈគ្រប់គ្រង ........ ៤៥
៣.៥. ភាគហ៊ុនិក អភិបាល និងបុគ្គលិកជាន់ខ្ពស់ ........ ៤៧
៣.៥.១.ភាគហ៊ុនិក ........ ៤៧
៣.៥.២.អភិបាល ........ ៤៧
៣.៥.៣.បុគ្គលិកជាន់ខ្ពស់ ........ ៤៨
៣.៦. ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ........ ៤៨
៣.៦.១. រចនាសម្ព័ន្ធច្បាប់ ........ ៤៨
៣.៦.២. ព័ត៌មានទូទៅអំពីមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ ........ ៤៩
៣.៧. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ........ ៥១
៣.៨. គោលនយោបាយបែងចែកភាគលាភ ........ ៥១


## ជំពូកទី ៤៖ លក្ខខណ្ឌតម្រូវអភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយមូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនPPSEZ


៤.១. ព័ត៌មានទាក់ទង និងអភិបាលកិច្ចសាជីវកម្ម ........ ៥៣
៤.១.១. អភិបាល ........ ៥៣
៤.១.២. អភិបាលកិច្ចសាជីវកម្ម ........ ៥៤
៤.១.២.១. ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល ........ ៥៤
៤.១.២.២. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ........ ៥៦
៤.២. ព័ត៌មានស្តីពីការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុន ........ ៥៧
៤.២.១.ដំណាក់កាលប៉ុកបៀលឌីង ........ ៥៧

៤.២.២.ដំណាក់កាលនៃការធ្វើបរិវិសកម្មកម្មសិទ្ធិ ........................................................ ៥៩
៤.២.៣.ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ........................................ ៦២
៤.២.៤.តម្លៃបោះផ្សាយ ........................................................................................................៦៣
៤.២.៥.សហាក្រុមហ៊ុនធានាទិញមូលបត្រចម្បង........................................................៦៣
៤.២.៦.កិច្ចសន្យាធានាទិញមូលបត្រ..........................................................................៦៣
៤.២.៧.វិនិយោគិនសាធារណៈ ...........................................................................................៦៣
៤.២.៨.បុគ្គលពាក់ព័ន្ធ ........................................................................................................ ៦៤

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន.................................................................................................... ៦៥
២. ការផ្តល់អនុសាសន៍ ............................................................................................... ៦៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

-PPSEZ : ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ)

-គ.ម.ក. : គណៈកម្មការមូលបត្រកម្ពុជា

-ផ.ម.ក. : ផ្សារមូលបត្រកម្ពុជា

-IPO : ការបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ (Initial Public Offering)

-ISO : អង្គការអន្តរជាតិសម្រាប់ទទួលស្គាល់គុណភាព

-CSD : ប្រតិបត្តិការរក្សាទុកមូលបត្រ (Central Securities Depository)

-CSA : ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ (Cash Settlement Agents)

-CSO : ប្រតិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ (Clearing and settlement Operator)

-CPS : ក្រុមហ៊ុនកម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (CAMPU Securities Plc.)

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើងគឺជាប្រទេសកំពុងអភិវឌ្ឍន៍គ្រប់វិស័យរួមមានដូចជាវិស័យធនាគារ និងវិស័យធានារ៉ាប់រងជាដើម។ ទន្ទឹមនឹងនេះវិស័យហិរញ្ញវត្ថុមានតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចដោយរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍវិស័យនេះ និងបានដាក់ចេញនូវ " **ចក្ខុវិស័យ និងផែនការអភិវឌ្ឍហិរញ្ញវត្ថុសម្រាប់ ឆ្នាំ២០០១ ដល់ ២០១០** " ហើយបានធ្វើបច្ចុប្បន្នកម្មទៅជា" **យុទ្ធសាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុ ឆ្នាំ២០០៦ ដល់ ២០១៥"** ដែលទើបត្រូវបានធ្វើបច្ចុប្បន្នភាពទៅជា " **យុទ្ធសាស្ត្រអភិវឌ្ឍន៍ហិរញ្ញវត្ថុ ឆ្នាំ២០១១ ដល់ ២០២០"**។ តាមរយៈផែនការយុទ្ធសាស្ត្រទាំងនេះ គម្រោងនៃការបង្កើតទីផ្សារមូលបត្រដែលប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អត្រូវបានបង្កើតឡើងដើម្បីធានាឲ្យបាននូវប្រសិទ្ធិភាពក្នុងការទ្រទ្រង់ដល់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុអោយរឹងមាំដោយផ្អែកលើយន្តការទីផ្សារ ដើម្បីគាំទ្រប្រកបដោយសមធម៌ និងចីរភាពនូវការគៀរគរ និងបែងចែកធនធានហិរញ្ញវត្ថុ។ ម្យ៉ាងទៀតដោយសារតែស្ថានភាពសេដ្ឋកិច្ច និងនយោបាយមានសកម្មភាពអំណោយផលក្នុងការទាក់ទាញវិនិយោគិនទាំងក្នុង និងក្រៅប្រទេសទើបធ្វើអោយទីផ្សារមូលបត្រត្រូវបានបង្កើតឡើង។ ចំពោះវិស័យមូលបត្រនេះគឺជាវិស័យថ្មីមួយ ចំពោះប្រទេសកម្ពុជាដែលអាចជួយជម្រុញឲ្យវិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាមានសន្ទុះកាន់តែខ្លាំងជាងមុន។ នៅក្នុងដំណើរការទីផ្សារនេះមានចំណុចជាច្រើនដែលអ្នកវិនិយោគត្រូវធ្វើការសិក្សាបន្ថែមទៅលើប្រតិបត្តិការទីផ្សារមូលបត្រដើម្បីបញ្ចៀសនូវហានិភ័យ និងទទួលបានផលចំណេញពីការវិនិយោគនេះ។

ការធ្វើប្រតិបត្តិការទៅលើអភិបាលកិច្ចសាជីវកម្មនៅក្នុងការបោះផ្សាយមូលបត្រជាសាធារណៈជាលើកដំបូង ពិតជាគឺជារឿងមួយដែលសំខាន់ ដែលតម្រូវអោយមានអ្នកជំនាញខ្ពស់មានការយល់ដឹងលើបទប្បញ្ញត្តិ និងប្រតិបត្តិការនានាដែលជានិយ័តករមួយក្នុងវិស័យហិរញ្ញវត្ថុដែលបានដាក់ចេញសម្រាប់ធ្វើការគ្រប់គ្រងទៅលើប្រតិបត្តិការទីផ្សារមូលបត្រអោយមានភាពរឹងមាំ សុក្រឹត្យភាព និងតម្លាភាព ព្រមទាំងការត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការទីផ្សារមូលបត្រទាំងមូល។

ហេតុដូច្នេះបានជាជ្រើសរើសប្រធានបទស្តីពី " **អភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយមូលបត្ររបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី(PPSEZ)** " មកធ្វើជារបាយការណ៍បញ្ចប់ការសិក្សាក្នុងគោលបំណងដើម្បីទទួលចំណេះដឹង និងផ្តល់ជាព័ត៌មានសម្រាប់សាធារណៈជន ព្រមទាំងនិស្សិតជំនាន់ ក្រោយដែលមានបំណង ចង់យល់កាន់តែច្បាស់ពីវិស័យមូលបត្រ។

## ២. ចំណោទបញ្ហា

វិស័យមូលបត្រកំពុងមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ឯកជន និងធានាចេរភាពនៃកំនើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ហើយវិស័យមូលបត្រត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាវិស័យដ៏សំខាន់មួយទន្ទឹមនឹងវិស័យធនាគារ និងវិស័យធានារ៉ាប់រង។ ហេតុនេះបានជាក្រុមយើងខ្ញុំជ្រើសរើសប្រធានបទខាងលើ ដើម្បីធ្វើការសិក្សា និងស្វែងយល់ពីបញ្ហាមួយចំនួនដូចខាងក្រោមៈ

- តើក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី(PPSEZ) មានដំណើរការក្នុងការរៀបចំអភិបាលកិច្ចសាជីវកម្មយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងដើម្បីសម្រេចនូវគោលបំណង ដើម្បីស្វែងយល់ពង្រីកចំណេះដឹងអំពីអភិបាលកិច្ចសាជីវកម្មនៃការបោះផ្សាយមូលបត្ររបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី (PPSEZ) និងគោលបំណងសំខាន់ៗមួយចំនួនទៀតដូចខាងក្រោមៈ

- ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី(PPSEZ)
- ស្ថានភាពទូទៅរបស់គណៈកម្មាធិការមូលបត្រកម្ពុជា
- តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រ

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានធ្វើការចុះកម្មសិក្សារយៈពេលពីរខែដូចនេះដើម្បីអោយកិច្ចការស្រាវជ្រាវនេះមានដំណើរការទៅបានល្អ និងប្រកបដោយប្រសិទ្ធភាព យើងខ្ញុំបានផ្តោតការសិក្សារជាសំខាន់ទៅលើ អភិបាលកិច្ចសាជីវកម្មនៃការបោះផ្សាយមូលបត្រ។ បន្ថែមពីនេះទៀតការសិក្សាស្រាវជ្រាវនេះអាស្រ័យទៅលើប្រភពទិន្នន័យ និងឯកសារផ្សេងៗទៀតដែលផ្តល់ដោយមន្ត្រីក្នុងនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រនៃគណៈកម្មការមូលបត្រកម្ពុជា។ ប៉ុន្តែទោះបីជាមានការជួយជ្រោមជ្រែងពីសំណាក់លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនៅក្នុងគណៈកម្មការមូលបត្រកម្ពុជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំបានខិតខិស្វែងរកឯកសារផ្ទៃក្នុងមួយចំនួនរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី(PPSEZ) ផងដែរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីចងក្រងជារបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាយើងខ្ញុំបានធ្វើការស្រាវជ្រាវតាមប្រភេទទិន្នន័យបែបគុណ។

<u>ទិន្នន័យបន្ទាប់បន្សំ</u>

យើងខ្ញុំបានចុះកម្មសិក្សាដោយផ្ទាល់នៅគណៈកម្មការមូលបត្រកម្ពុជា និងធ្វើការសាកសួរដោយផ្ទាល់ជាមួយនឹងមន្ត្រីដែលបម្រើការនៅ គ.ម.ក ជាពិសេសមន្ត្រីដែលបម្រើការនៅក្នុងបោះផ្សាយលក់មូលបត្រដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងតាមដានរាល់ប្រតិបត្តិការទីផ្សារជាប្រចាំ។

- ឯកសារដែលផ្តល់ដោយមន្ត្រីគណៈកម្មការមូលបត្រដូចជា ច្បាប់ អនុក្រឹត្យ និងឯកសារពាក់ព័ន្ធផ្សេងៗ។

-ឯកសារទាំងឡាយដែលទាក់ទងនឹងប្រធានបទ តាមរយៈវែបសាយរបស់គណៈកម្មការមូល-បត្រកម្ពុជា ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី(PPSEZ) និងទីផ្សារមូលបត្រកម្ពុជា។

-ឯកសារទាំងឡាយដែលទាក់ទងនឹងប្រធានបទតាមរយៈការណែនាំពីសាស្ត្រាចារ្យដឹកនាំ។

-សារណា ឬរបាយការណ៍បញ្ចប់ការសិក្សារបស់និស្សិតរៀមច្បងមុនៗ និងស្វែងរកសៀវភៅផ្សេងនៅក្នុងបណ្ណាល័យ។

- ឯកសារទាំងឡាយដែលទាក់ទងនឹងប្រធានបទតាមរយៈប្រព័ន្ធអ៊ីនធឺណេត។

-ឯកសារទាំងឡាយដែលទាក់ទងនឹងប្រធានបទ នៅក្នុងគណៈកម្មការមូលបត្រកម្ពុជាមានដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស បទប្បញ្ញត្តិ ឯកសារ ។

- ឯកសារទាំងឡាយដែលទាក់ទងនឹងប្រធានបទតាមរយៈ វេបសាយក្រុមហ៊ុន ភ្នំពេញ អេស-អ៊ីហ្សិត ភិអិលស៊ី (PPSEZ)។

## ៦. អត្ថប្រយោជន៍នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

-សម្រាប់យើងខ្ញុំដែលជាអ្នកស្រាវជ្រាវទៅលើប្រធានបទនេះ ទទួលបានការបង្កើននូវចំណេះដឹងបន្ថែមលើពាក្យបច្ចេកទេសដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ ដែលកាលពីមុនមិនមានការយល់ច្បាស់ ឬកាតព្វកិច្ច និងសកម្មភាពនានានៅគណៈកម្មការមូលបត្រកម្ពុជា និងទទួលបាននូវបទពិសោ-ធន៍ក្នុងការបំពេញការងារនៅទីនោះផងដែរ ជាពិសេសប្រតិបត្តិការទីផ្សារមូលបត្រក្នុងការជួយជម្រុញអោយវិស័យមូលបត្រក៏ដូចជាសេដ្ឋកិច្ចជាតិមានការអភិវឌ្ឍដូចប្រទេសដ៏ទៃដែរ។

លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវនេះបានបង្កនូវបរិយាកាសគួរជាទីមោទនភាពដល់យើងខ្ញុំដោយបង្កើនចំណងមិត្តភាពក៏ដូចជាសាមគ្គីភាពគ្នារវាងសមាជិក និងសមាជិកក្រុមអោយកាន់តែមានភាពចុះសម្រុងគ្នា និងចេះជួយទុកធុរៈគ្នាទៅវិញទៅមកផងដែល។

-សម្រាប់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី (PPSEZ) យើងខ្ញុំសង្ឃឹមថាលទ្ធផលនៃការស្រាវជ្រាវ នេះអាចជាឯកសារដ៏ស្តួចស្តើងមួយសម្រាប់ផ្តល់ជាប្រយោជន៍ក្នុងការទាក់ទាញ ឈ្មួញ

វិនិយោគរបស់ខ្លួនបន្ថែមទៀតតាមរយៈការការពារវិនិយោគិនក្នុងការពិនិត្យ និងពង្រឹងភាពខ្លាំងរបស់ក្រុមហ៊ុនអោយកាន់តែប្រសើរ។

-សម្រាប់សាធារណៈជនទូទៅ ឯកសារនេះអាចជួយអោយនិស្សិតជំនាន់ក្រោយទទួល បានការយល់ដឹងអភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយមូលបត្រ និងជួយអោយនិស្សិតជំនាន់ក្រោយយល់ដឹងពីវិស័យមូលបត្រនៅកម្ពុជាច្បាស់ជាងមុន។ ចំពោះមជ្ឈដ្ឋានខាងក្រៅវាជារបាយការណ៍ដែលផ្តល់ជាព័ត៌មាន និងឯកសារសម្រាប់មជ្ឈដ្ឋានអ្នកអានទូទៅដែលមានបំណងចង់ដឹងពីវិស័យនេះជាពិសេសសម្រាប់ក្រុមហ៊ុនមូលបត្រ និងអ្នកវិនិយោគសាធារណៈដែលមានចំណូលចិត្តចូលរួមខាងវិស័យមូលបត្រនេះ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះរួមមាន៖

**សេចក្តីផ្តើម**

**ជំពូកទី១** រំលឹកទ្រឹស្តី

**ជំពូកទី២** វិស័យមូលបត្រនៅកម្ពុជា

**ជំពូកទី៣** ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី(PPSEZ)

**ជំពូកទី៤** លក្ខខណ្ឌតម្រូវអភិបាលកិច្ចសាជីកម្មក្នុងការបោះផ្សាយមូលបត្រជាសារធារណៈរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី(PPSEZ)

**សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍**

រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ដែលបង្ហាញពីទំនាក់ទំនងនៃផ្នែកនីមួយៗ និងដំណើរការរបស់កិច្ចការស្រាវជ្រាវទាំងមូល។

**គំនូសបំព្រួញបង្ហាញពីរចនាសម្ព័ន្ធនៃការស្រាវជ្រាវ**


សេចក្តីផ្តើម
ជំពូកទី១
រំលឹកទ្រឹស្តី
ជំពូកទី២
វិស័យមូលបត្រនៅកម្ពុជា
ជំពូកទី៣
ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី(PPSEZ)
ជំពូកទី៤
លក្ខខណ្ឌតម្រូវអភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយមូលបត្រជាសាធារណៈរបស់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី(PPSEZ)
សេចក្តីសន្និដ្ឋាន
និងអនុសាសន៍

# ជំពូកទី១៖ រំលឹកទ្រឹស្តី

## ១.១ អភិបាលកិច្ចសាជីវកម្ម

### ១.១.១ ប្រវត្តិនៃអភិបាលកិច្ចសាជីវកម្ម

អភិបាលកិច្ចចាប់ផ្តើមលូតលាស់ និងពេញនិយមដំបូងនៅក្នុងសតវត្សទី២០ ពោលគឺចាប់ពីវិបត្តិសេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំ១៩២៥មកម្លេះ។ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ១៩២៩ ក្នុងសហរដ្ឋអាមេរិក មានបណ្តាលអ្នកប្រាជ្ញមួយចំនួន ដូចជា លោក Adolf Augustus Berle លោក Edwin Dodd និងលោក Gardiner C, Means បានចាប់ផ្តើមគិតពិចារណាទៅលើការផ្លាស់ប្តូរនៃតួនាទីរបស់សាជីវកម្មនៅក្នុងសម័យទំនើបតាមរយៈការរៀបចំអភិបាលនៅក្នុងក្រុមហ៊ុន។ បន្ទាប់មកនៅក្នុងទសវត្សន៍ ១៩៨០ លោក Eugence Fama និងលោក Michael Jensen បានបង្កើតជាគោលការណ៍មួយដែលមានឈ្មោះថា Principal-Agent Problem ដើម្បីជាមធ្យោបាយមួយក្នុងការស្វែងយល់អំពីអធិបាលកិច្ចក្នុងក្រុមហ៊ុន។ ចាប់ពីដើមទសវត្សន៍ទី ២០០០ មកអភិបាលកិ្ចត្រូវបានក្រុមហ៊ុនជាច្រើនចាប់អារម្មណ៍ និងទាញយកមកប្រើប្រាស់ដើម្បីបម្រើផលប្រយោជន៍នៅក្នុងក្រុមហ៊ុនរបស់ខ្លួន។

### ១.១.២ និយមន័យអភិបាលកិច្ចសាជីវកម្ម

ក្នុងន័យសាមញ្ញអភិបាលកិច្ចសាជីវកម្មគឺជាប្រព័ន្ធសម្រាប់ដឹកនាំ និងគ្រប់គ្រងក្រុមហ៊ុន ហើយជាប់ពាក់ព័ន្ធនឹងការធ្វើឲ្យមានតុល្យភាពនៃផលប្រយោជន៍របស់ភាគីពាក់ព័ន្ធនានានៅក្នុងក្រុមហ៊ុនមានដូចជា៖ ភាគហ៊ុនិក គណៈគ្រប់គ្រងក្រុមហ៊ុន អតថិជន អ្នកផ្គត់ផ្គង់ អ្នកផ្តល់ហិរញ្ញប្បទាន រដ្ឋាភិបាល និងសហគមន៍។ បច្ចុប្បន្ននេះគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) បាន និងកំពុងសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation, IFC) ដើម្បីធ្វើបច្ចុប្បន្នភាព និងបង្កើតបទដ្ឋានអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុននៅកម្ពុជា។

អភិបាលកិច្ចសាជីវកម្មល្អ ស្តែងតាមរយៈ៖

-ការបង្កើតនូវយន្តការនានាដើម្បីធានាឱ្យមានប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ក្រុមហ៊ុន គណនេយ្យភាព ភាពត្រឹមត្រូវ និងតម្លាភាព

-ការបង្កើតឱ្យមាននូវយន្តការការពារសិទ្ធិរបស់ភាគហ៊ុននិក

-ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង

-ការបង្កើតជាប្រព័ន្ធត្រួតពិនិត្យជាដើម។

### ១.១.៣ គោលដៅរបស់អភិបាលកិច្ចសាជីវកម្ម

គោលបំណងធំនៃអភិបាលកិច្ចសាជីវកម្ម គឺដើម្បីជួយសម្រួលដល់ប្រសិទ្ធិភាពសហគ្រិនភាព ភាពប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងក្រុមហ៊ុន ដើម្បីធានាបាននូវភាពជោគជ័យរយៈពេលវែងរបស់ក្រុមហ៊ុនប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ជាទូទៅក្រុមប្រឹក្សាភិបាលគឺជាអ្នកទទួលខុសត្រូវចំពោះអភិបាលកិច្ចក្រុមហ៊ុនរបស់ពួកគេ។ ចំណែកឯភាគហ៊ុនិកវិញមានតួនាទីក្នុងការជ្រើសរើសតាំងអភិបាល(នាយក) និងសវនករ(អ្នកត្រួតពិនិត្យផ្ទៃក្នុង) ដើម្បីបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចមួយដែលសមស្របសម្រាប់ក្រុមហ៊ុន។

**១.១.៤ ហេតុអ្វីក្រុមហ៊ុនចាំបាច់មានអភិបាលកិច្ចសាជីវកម្ម?**

-ជៀសវាងនូវបញ្ហាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍

-ជាកាតាលីករមួយដែលជំរុញក្រុមហ៊ុនឱ្យមានការរីកចំរើន

-ធានាបាននូវលំនឹងនៃស្ថានភាពហិរញ្ញវត្ថុអាជីវកម្ម

-ជៀសផុតពីការដួលរលំរបស់ក្រុមហ៊ុន

-ជៀសវៀងបញ្ហារាំងស្ទះសកម្មភាពអាជីវកម្មរបស់ខ្លួន

-ជាផ្នែកមួយនៃការប្រកួតប្រជែងរបស់ក្រុមហ៊ុន ជាដើម។

**១.១.៥ សារៈសំខាន់នៃអភិបាលកិច្ចសាជីវកម្មល្អ**

ការអនុវត្តអភិបាលកិច្ចសាជីវកម្ម ផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើន និងជួយពង្រឹងបរិយាកាសវិនិយោគរបស់ក្រុមហ៊ុន និងវិនិយោគិនដូចជា៖

- ជួយកែលំអកេរ្តិ៍ឈ្មោះក្រុមហ៊ុន និងបង្កើតទំនុកចិត្តរបស់វិនិយោគិនលើក្រុមហ៊ុន និងឱកាសឈានចូលទីផ្សារមូលបត្របានងាយស្រួល។
- ជួយបង្កើនលទ្ធភាព និងសមត្ថភាពក្នុងការប្រកួតប្រជែងរបស់ក្រុមហ៊ុនកាន់តែខ្លាំង។
- ងាយស្រួលក្នុងការស្វែងរកដើមទុន ឬហិរញ្ញប្បទានបន្ថែមសម្រាប់ពង្រីក និងពង្រឹងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។
- ធានាសុវត្ថិភាពចំពោះការវិនិយោគរបស់ភាគហ៊ុនិក។
- អាចទទួលបាននូវការជូនដំណឹងគ្រប់គ្រាន់ និងទាន់ពេលពាក់ព័ន្ធនឹងការសម្រេចចិត្តនានា របស់ក្រុមហ៊ុនដែលអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន។ល។

ជាទូទៅ មានក្រុមហ៊ុនជាច្រើននៅទូទាំងពិភពលោកបាន និងកំពុងព្យាយាមអភិវឌ្ឍក្រុមហ៊ុនឲ្យមានអភិបាលកិច្ចសាជីវកម្មល្អ។ សម្រាប់ភាគហ៊ុនិកមួយចំនួនធំការគ្រាន់តែធ្វើឲ្យក្រុមហ៊ុនទទួលបានប្រាក់ចំណេញតែមួយមុខនោះគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ពោលគឺក្រុមហ៊ុនគួរបង្ហាញភាព

ជាពលរដ្ឋល្អនៅក្នុងសង្គមតាមរយៈការរក្សាក្រមសីលធម៌ពាណិជ្ជកម្មគិតគូរ និងចូលរួមថែរក្សាបរិស្ថាន និងចូលរួមក្នុងកិច្ចការអភិវឌ្ឍសង្គមជាដើម។[1]

**១.១.៦. ការរៀបចំអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន**

ជាដំបូងក្រុមហ៊ុនត្រូវរៀបចំ ក្រុមប្រឹក្សាភិបាលៈ ត្រូវមាសមាសភាពនូវអភិបាល ប្រតិបត្តិ អភិបាលមិនប្រតិបត្តិ និងអភិបាលឯករាជ្យ។ "តាមបទបញ្ញត្តិៈ សមាជិកចាប់ពី ០៥ (ប្រាំ) រូប ទៅ ១៥ (ដប់ប្រាំ) រូប ដែលក្នុងនោះមានអភិបាលឯករាជ្យយ៉ាងតិចចំនួន ១/៥ (មួយភាគប្រាំ) រូប នៃចំនួនអភិបាលសរុប"។

-អភិបាលឯករាជ្យៈសំដៅទៅដល់សមាជិកឯករាជ្យដែលមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រងផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅដែលមិនសមស្រប។

-អភិបាលប្រតិបត្តិៈសំដៅដល់អភិបាលដែលមានមុខដំណែងជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

-អភិបាលមិនប្រតិបត្តិ សំដៅដល់អភិបាលដែលមិនមែនជាអភិបាលប្រតិបត្តិ។

**១.១.៦.១ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល**

ដើម្បីធានានូវអភិបាលកិច្ចសាជីវកម្មល្អ ក្រុមប្រឹក្សាភិបាលត្រូវបានបង្កើតនូវគណៈកម្មាធិការមួយចំនួន ដូចខាងក្រោមៈ

-គណៈកម្មាធិការសវនកម្ម

-គណៈកម្មាធិកាគ្រប់គ្រងហានិភ័យ

-គណៈកម្មាធិការតែងតាំង

<u>ក. គណៈកម្មាធិការសវនកម្ម</u>

គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ)រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ និងសមាជិកដទៃទៀតត្រូវមានការយល់ដឹងផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលដោយរាប់បញ្ចូលនូវតួនាទី និងភារកិច្ចជាអាទិ៍ ដូចខាងក្រោមមៈ

-ពិនិត្យរបាយការបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

[1] (www.secc.gov.kh)

-ពិនិត្យរបាយការណ៍ផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង

-រាយការណ៍ទៅឲ្យក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន។

ខ. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវមានតួនាទីគន្លឹះក្នុងការគ្រប់គ្រងហានិភ័យនៅក្នុងកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុន។ គណៈកម្មធិការនេះត្រូវមានសមាជិកយ៉ាងតិច ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។ តួនាទី និងភារកិច្ចអាចមានជាអាទិ៍ ដូចខាងក្រោម៖

-ការវាយតម្លៃអំពីហានិភ័យ (Risk Evaluation)

-ការរាយការណ៍អំពីហានិភ័យ (Risk Reporting)

-ការលើកវិធានការទប់ទល់ហានិភ័យ (Risk Treatment)

-ការតាមដានអំពីហានិភ័យ (Risk Monitoring)

ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូកបត្រជាសាធារណៈ ដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០(ពីររយពាន់លានរៀល) តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យអាចអនុវត្តដោយគណៈកម្មាធិការសវនកម្ម។

គ. គណៈកម្មាធិការតែងតាំង

ករណីមានគណៈកម្មាធិការតែងតាំង គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូបដែលមានសមាជិកទាំងអស់ត្រូវជាអភិបាលមិនប្រតិបត្តិដោយក្នុងនោះត្រូវមានសមាជិកយ៉ាតតិច ០១ (មួយ) រូប ជាអភិបាលឯករាជ្យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលដោយរាប់បញ្ចូលនូវការពិនិត្យ និងការវាយតម្លៃអំពីគុណវុឌ្ឍិបេក្ខអភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលត្រូវតែងតាំងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

គណៈកម្មាធិការតែងតាំងអាចមានការទទួលខុសត្រូវផងដែរ ចំពោះការរៀបចំនីតិវិធី ឬការពិនិត្យឡើងវិញ និងករផ្តល់អនុសាសន៍ សម្រាប់លាភការ និងប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិក និងបុគ្គលិកជាន់ខ្ពស់។

(ប្រកាស០០២ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ)

**១.១.៦.២. លេខាធិការរបស់ក្រុមហ៊ុនបោះផ្សាយ និងការបង្ហាញព័តមាន**

-លេខាធិការរបស់ក្រុមហ៊ុនបោះផ្សាយៈ ត្រូវតែងតាំងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនជាលេខាធិការរបស់ក្រុមហ៊ុន(មានសញ្ជាតិខ្មែរ បទពិសោធន៍ការងារ និងមានលក្ខណសម្បត្តិល្អ )។

-ការបង្ហាញព័តមានៈ ត្រូវចាត់តាំងបុគ្គលិកម្នាក់ដើម្បីទទួលខុសត្រូវក្នុងការបង្ហាញព័តមាន។

**១.១.៦.៣. ការរៀបចំនូវគោលនយោបាយ**

ដើម្បីធានានូវការអនុវត្តអភិបាលកិច្ចសាជីវកម្មល្អ ក្រុមហ៊ុនត្រូវត្រួតពិនិត្យរៀបចំឱ្យមាននូវគោលនយោបាយដូចខាងក្រោមៈ

-ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

-គោលនយោបាយគ្រប់គ្រងការជួញដូរមូលបត្រ របស់សហគ្រាសដែលធ្វើឡើងដោយ អភិបាលនិងបុគ្គលិកជាន់ខ្ពស់

-គោលនយោបាយលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

-គោលនយោបាយគ្រប់គ្រងយុទ្ធសាស្ត្រក្នុងការគាំទ្រ និងការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធយន្តការពាក់ព័ន្ធនឹងសកម្មភាពដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងការត្រួតត្រាក្រុមហ៊ុនជាអាទិ៍[2]

**១.១.៧. មុខងារ និងភារកិច្ចរបស់អភិបាល**

អភិបាលត្រូវមានមុខងារ និងភារកិច្ច ដូចខាងក្រោមៈ

-អនុម័តលើគោលនបាយ និងនិតិវិធីអនុវត្តសម្រាប់ក្រុមហ៊ុន

-ចូលរួមចំណែក និងអនុម័តលើផែនការរយុទ្ធសាស្ត្រ

-តាមដាននូវការអនុវត្តគោលនយោបាយ

-ទទួលខុសត្រូវចំពោះក្រុមហ៊ុន

-ជ្រើសតាំងនាយកប្រតិបត្តិ

-ធានាសាធនហិរញ្ញវត្ថុរបស់ក្រុមហ៊ុនតាមរយៈការគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុបាន ត្រឹមត្រូវ និងការការពារទ្រព្យសកម្មរបស់ ភាគហ៊ុនិក។

-ផ្តល់នូវភាពជាអ្នកដឹកនាំ ជួយគាំទ្រ និងលើកទឹកចិត្តដល់និយោជិត

-ធានាថា ក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំក្រុមហ៊ុន

-ធានានូវការសម្រេចបានគោលដៅរបស់ក្រុមហ៊ុន

[2] (www.secc.gov.kh)

-ផ្តល់នូវទស្សនវិស័យស្តីពីប្រសិទ្ធិភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក

(ប្រកាស០០២ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ)

## ១.២. តើអ្វីទៅជាមូលបត្រ?

មូលបត្រ សំដៅដល់ភាគហ៊ុនកម្មសិទ្ធិ សញ្ញាបណ្ណ (បណ្ណបំណុល) និង ឧបករណ៍និស្សន្ទ ឬ ដេរីវេទីវ អុបសិន(Option) ហ្វូឈឺ (Futures) ។

វិស័យមូលបត្រ គឺជាទីផ្សារមួយដែលត្រូវបានបង្កើតឡើងដើម្បីធ្វើការជួញដូរនូវឧបករណ៍ហិរញ្ញវត្ថុជាច្រើនប្រភេទ។ មិនតែប៉ុណ្ណោះវិស័យមូលបត្រជាផ្នែកមួយយ៉ាងសំខាន់ ក្នុងវិស័យហិរញ្ញវត្ថុដែលជួយជំរុញអោយកំណើនសេដ្ឋកិច្ចមានការរីកចំរើនក្នុងការជំរុញការអភិវឌ្ឍន៍ និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុទាំងមូលអោយកាន់តែមានប្រសិទ្ធភាពដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងដើម្បីធានាដល់ការប្រកួតប្រជែងទីផ្សាររបស់ព្រះរាជាណាចក្រកម្ពុជាក្នុងសកលភាវូបនីយកម្ម។ វិស័យមូលបត្រជាវិស័យមួយយ៉ាងសំខាន់ក្នុងប្រព័ន្ធហិរញ្ញវត្ថុជាតិតាមរយៈការផ្តល់យន្តការសម្រាប់គៀងគរប្រភពហិរញ្ញវត្ថុ ដើម្បីទទួលបានហិរញ្ញប្បទានពង្រីកអាជីវកម្មគម្រោងវិនិយោគនានា ក្នុងន័យជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចអោយមានភាពសម្បូរ និងមានកំណើនខ្ពស់។

## ១.៣ ទីផ្សារមូលបត្រ

### ១.៣.១.និយមន័យ

ទីផ្សារមូលបត្រគឺជាកន្លែងសម្រាប់ជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត។ តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន"សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នីការទិញ-លក់មូលបត្រ" ឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះរួមមានមូលបត្រកម្មសិទ្ធិមូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។

### ១.៣.២.ប្រវត្តិទីផ្សារមូលបត្រ

ផ្សារភាគហ៊ុនបានកកើតឡើងពីសកម្មភាពដោះដូរដើមដំបូងក្នុងផលិតផលកសិកម្ម និងផលិតផលផ្សេងទៀត។ ពាណិជ្ជករនៅទីផ្សារអឺរ៉ុបនៅក្នុងមជ្ឈឹមសម័យមានការងាយស្រួលក្នុងការប្រើប្រាស់ឥណទានដែលទាមទារអោយមាននូវឯកសារពង្រាងដោយមានឯកសារគាំទ្រ ដូចជាប័ណ្ណលិខិតផ្លាស់ប្តូរ។ ផ្សារភាគហ៊ុនបារាំងត្រូវបានរកឃើញកាលពីសតវត្សទី ១២ នៅពេលដែលការធ្វើជំនួញបានកើតឡើងជារូបភាពជាលិខិតផ្លាស់ប្តូរពាណិជ្ជកម្ម។ ដើម្បីគ្រប់គ្រងនូវទីផ្សារដែលទើបតែចាប់ផ្តើម លោកហ្វីលីបឌឺហ្វែរ (Philip The fair 1268 – 1314) បានបង្កើតនូវជំនាញមួយនៃការផ្លាស់ប្តូរ

ដូចជាអ្នកនាំមុខគេនៃអ្នកគួកជេរហ៊ុនបារាំងទំនើប ឬជាភ្នាក់ងារផ្លាស់ប្តូរ។ ប្រហែលជាពេលនោះដែរ ពាណិជ្ជករបានចាប់ផ្តើមប្រមូលផ្តុំគ្នានៅមុខផ្ទះនៃគ្រួសារ វ៉ាន់ឌែប៊ួអែស Van der Buerse ដើម្បីទំនាក់ទំនងក្នុងការធ្វើជំនួញ។ ចាប់តាំងពីពេលនោះមកឈ្មោះគ្រួសារនេះត្រូវបានគេបញ្ជាក់ភ្ជាប់ជាមួយនឹងការធ្វើជំនួញ ដោយគេហៅថា "បួក្ស" (Bourse) មានន័យថាផ្សារភាគហ៊ុន(Stock Exchange) ។ ការចាប់ផ្តើមស្ថាប័ននៃផ្សារភាគហ៊ុនក៏បានកើតឡើងក្នុងអំឡុងសតវត្សទី១៦ និងទី១៧នៅក្នុងមជ្ឈមណ្ឌលដ៏ធំផ្សេងទៀតនៅទូទាំងពិភពលោកដូចជា អាំស្ទ័រដាំ ចក្រភពអង់គ្លេស ដាណឺម៉ាក អាឡឺម៉ង់។

ផ្សារមូលបត្រនៅក្នុងសហរដ្ឋអាមេរិក បានចាប់ផ្តើមជាមួយនឹងការធ្វើជំនួញដែលមានការឡើងចុះឆាប់រហ័សក្នុងការចេញបោះផ្សាយថ្មីៗរបស់រដ្ឋាភិបាល។ ក្នុងឆ្នាំ ១៧៩១ ផ្សារភាគហ៊ុនដំបូងរបស់អាមេរិកត្រូវបានបង្កើតឡើងនៅ រដ្ឋហ្វីឡាដេផ្យា។ ផ្សារភាគហ៊ុននៅទីក្រុងញូយ៉កត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៧៩២ នៅពេលដែលពាណិជ្ជករ និងអ្នកគួកជេរចំនួន២៤នាក់ បានសម្រេចចិត្តយកកម្រៃជើងសារនៅពេលដើរតួនាទីជាភ្នាក់ងារសម្រាប់មនុស្សផ្សេងទៀត ហើយដើម្បីផ្តល់ការពេញចិត្តទៅអោយគ្នាទៅវិញទៅមក។ ដោយបានធ្វើជំនួញរបស់ពួកគេនៅក្រោមដើមឈើមួយនៅផ្លូវវ៉លស្ទ្រីត លេខ ៦៨។ ក្នុងឆ្នាំ ១៨១៧ អ្នកគួកជេរនៅទីក្រុងញូយ៉កបានសម្រេចចិត្តចាត់ចែងជាផ្លូវការនូវក្រុមប្រឹក្សាផ្សារភាគហ៊ុន។ ឆ្នាំ១៨៦៣ ផ្សារភាគហ៊ុនញូយ៉កបានអនុម័តនូវឈ្មោះបច្ចុប្បន្នរបស់ខ្លួន។ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ផ្សារភាគហ៊ុនមួយចំនួនត្រូវបានគេរៀបចំឡើងហើយផ្សារភាគហ៊ុនមួយចំនួនក្នុងចំណោមនោះ ដែលចាត់ទុកថាជាអ្នកនាំមុខគេគឺ ផ្សារភាគហ៊ុនអាមេរិក (American Stock Exchange)ហើយក៏ជាផ្សារភាគហ៊ុនធំបំផុតទីពីរនៃសហរដ្ឋអាមេរិក។[3]

(ហាស់ វាសនា, ២០០៧, ទំព័រទី៥-៩)

### ១.៣.៣.ទីផ្សារដំបូង ( Primary Market )

ទីផ្សារដំបូង គឺជាទីផ្សារដែលធ្វើការជួញដូរមូលបត្រដែលទើបនឹងបោះផ្សាយលក់ ឬគេអាចហៅថាជាទីផ្សារបោះផ្សាយមូលបត្រ។ប្រភពមូលធនសំខាន់របស់ទីផ្សារនេះ គឺជាប្រភពប្រាក់សន្សំរបស់សាធារណៈជនក៏ដូចជាអង្គការមិនមែនស្ថាប័នហិរញ្ញវត្ថុមួយចំនួនទៀតដែរ។ ទីផ្សារដំបូង អនុវត្តនូវមុខងារសំខាន់បំផុតរបស់ទីផ្សារមូលធននោះ គឺជាមុខងារសេដ្ឋកិច្ចមានន័យថាយកមូលធនពីអ្នកមានមូលធនលើសទៅផ្តល់ឲ្យអ្នកដែលខ្វះមូលធនឬជាការគៀគរមូលធនដែលទំនេរយកទៅវិនិយោគ។

ទីផ្សារដំបូង គឺជាកន្លែងបោះផ្សាយពីព្រោះកន្លែងនេះជាកន្លែងទិញ-លក់បណ្តាមូលបត្រដែលទើបនឹងបោះផ្សាយលើកដំបូង រវាងអ្នកបោះផ្សាយ (អ្នកលក់) និងអ្នកវិនិយោគ (អ្នកទិញ)។

---

[3] (ហាស់ វាសនា, ២០០៧, ទំព័រទី៥-៩)

តួនាទីចំបងរបស់ទីផ្សារដំបូង គឺបង្កើតទំនិញឲ្យទីផ្សារជួញដូរ និងធ្វើឲ្យកើនមូលធនវិនិយោគដល់វិស័យសេដ្ឋកិច្ច។ តួនាទីនោះគឺះ

-ទី១: គឺជាដំណើរការនៃមូលបត្រ ដើម្បីប្រមូលនូវមូលធនពេលត្រូវការ។

-ទី២:គឺជាដំណើរការហិរញ្ញវត្ថុដោយផ្ទាល់ ដែលផ្ទេរប្រាក់ទៅជាទំរង់មូលធនរយៈ ពេលមធ្យម និងរយៈពេលវែង។[4]

(សួនចំរើន, ២០០៩, ទំព័រទី៣៨-៣៩)

**១.៣.៤. ទីផ្សារបន្ទាប់** (Secondary Market)

ទីផ្សារបន្ទាប់ គឺជាទីផ្សារដែលធ្វើការជួញដូរមូលបត្រទាំងឡាយ ដែលធ្លាប់បានធ្វើការជួញដូរម្តងរួចហើយនៅក្នុងទីផ្សារដំបូង។ ទីផ្សារនេះជាចំណែកមួយដ៏សំខាន់នៃទីផ្សារមូលបត្រដោយភ្ជាប់ទំនាក់ទំនងយ៉ាងជិតសិទ្ធជាមួយនឹងទីផ្សារដំបូង។

ទីផ្សារបន្ទាប់អនុវត្តនូវបណ្តាមុខងារដូចជាះ

-បង្កើតលក្ខណៈងាយស្រួលដើម្បីលក់ឧបករណ៍ហិរញ្ញវត្ថុ ក្នុងគោលបំណងប្រមូលនូវសាច់ប្រាក់ និងបង្កើននូវឧបករណ៍ហិរញ្ញវត្ថុ។ មានន័យថាបង្កើននូវលក្ខណៈងាយស្រួលក្នុងការ ផ្ទេរសាច់ប្រាក់ទៅជាឧបករណ៍ហិរញ្ញវត្ថុ និងផ្ទេរពីឧបករណ៍ហិតញ្ញវត្ថុទៅជាសាច់ប្រាក់ (សន្ទនីយភាពសាច់ប្រាក់)។

- រកផលចំណេញពីការកាន់កាប់នូវមូលបត្រ(ទទួលបានភាគលាភ ឬការប្រាក់)។

-កំណាត់តម្លៃមូលបត្រឲ្យបានសមស្របនៅលើមូលដ្ឋានដេញថ្លៃដោយសេរី (ការប្រកួតប្រជែងដោយសេរី)។[5]

(សួនចំរើន,២០០៩, ទំព័រទី៣៩-៤០)

**១.៣.៥. ទីផ្សារមូលធន** (Capital Market)

ទីផ្សារមូលធន (Capital Market) គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្រកម្មសិទ្ធិ (Equity Securities) និងឧបករណ៍បំណុលរយៈពេលវែង ដែលមានឥណប្រតិទានរយៈពេលមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំ។ ឧបករណ៍ហិរញ្ញវត្ថុរយៈពេលវែងមានដូចជាះ ប័ណ្ណភាគហ៊ុនធម្មតា (Common Stock) ប័ណ្ណភាគហ៊ុនអាទិភាព (Preferred Stock) សញ្ញាប័ណ្ណ (Bond) ជាដើម។[6]

---

[4] (សួនចំរើន, ២០០៩, ទំព័រទី៣៨-៣៩)

[5] (សួនចំរើន,២០០៩, ទំព័រទី៣៩-៤០)

[6] (បៀន សាំង, ២០១១, ទំព័រទី១៦)

(បៀន សាំង, ២០១១, ទំព័រទី១៦)

### ១.៣.៦. ទីផ្សាររូបិយវត្ថុ (Money Market)

ទីផ្សាររូបិយវត្ថុ (Money Market) គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្ររយៈពេលខ្លីតិចជាងមួយឆ្នាំ ដែលមានដូចជា ៖

- ប័ណ្ណរតនាគារ (Treasury Bill/T-bill) ជាប័ណ្ណបំណុលរយៈពេលខ្លីតិចជាងមួយឆ្នាំរបស់រដ្ឋាភិបាលដែលបោះផ្សាយដោយរតនាគារក្នុងគោលបំណងប្រមូលថវិការរដ្ឋដើម្បីអភិវឌ្ឍន៍។ ប័ណ្ណនេះត្រូវបានលក់ដោយធនាគារកណ្តាល។

- ផលបត្រពាណិជ្ជកម្ម (Commercial Paper) ជាប័ណ្ណបំណុលរយៈពេលខ្លី ដែលបោះផ្សាយដោយធនាគារធំៗ ឬក្រុមហ៊ុនសាជីវកម្មក្នុងគោលបំណងសុំខ្ចីលុយពីទីផ្សារ ដើម្បីទូទាត់បំណុលទំនិញ និងសេវាផ្សេងៗ។

- Banker Acceptance ជាប័ណ្ណបំណុលរយៈពេលខ្លីដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មមានការទទួលខុសត្រូវ ឬការធានារបស់ធនាគារដែលបោះផ្សាយក្នុងគោលបំណងទូទាត់ទំនិញ សេវា ឬបំណុលផ្សេងៗ នៅក្នុងពាណិជ្ជកម្មអន្តរជាតិ។[7]

(Mishkin and Eakins, fifth edition, 2006, Page 217)

## ១.៤. ប្រភេទនៃមូលបត្រ

-មូលបត្រមហាជន(Non-government Securities) សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានអនុញ្ញាតឱ្យបោះ-ផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់។

មូលបត្រទាំងនោះមាន៖

ក.មូលបត្រកម្មសិទ្ធិរាប់បញ្ចូលទាំងភាគហ៊ុន។

ខ.មូលបត្របំណុល រាប់បញ្ចូលទាំងសញ្ញាប័ណ្ណ។

គ.ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម។

ឃ.ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវដែលទាក់ទងនឹងមូលបត្រមួយគឺយោងទៅលើចំណុច(ក) (ខ) ឬ(គ)ខាងលើ។

ង.ឧបករណ៍ហិរញ្ញវត្ថុ ដទៃទៀតដែលកំណត់ថាជាមូលបត្រ។

---

[7] (Mishkin and Eakins, fifth edition, 2006, Page 217)

-មូលបត្រកម្មសិទ្ធិ(Equity Securities) សំដៅដល់ប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលបរទេសប្រហាក់ប្រហែលហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

-មូលបត្រភាហាក(Bearer Securities) សំដៅដល់មូលបត្រដែលកម្មសិទ្ធិនៃមូលបត្រនោះត្រូវបានកំណត់ដោយការកាន់កាប់ជារូបវន្ត មិនមែនតាមរយៈការចុះបញ្ជីនៃកម្មសិទ្ធិករនៅក្នុងបញ្ជីមូលបត្ររក្សាទុកដោយ ឬរក្សាទុកសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

-មូលបត្រថ្មី(New Securities) សំដៅដល់មូលបត្រដែលមិនធ្លាប់បានបោះផ្សាយ ឬធ្វើសំណើលក់ជាសាធារណៈពីមុនមកដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលមានចែងក្នុងច្បាប់។

-មូលបត្របំណុល (Debt Securities) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឱ្យប្រាក់ខ្ចី ឬដាក់ជាប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្តី។

## ១.៥. សារៈសំខាន់របស់ទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច

ទីផ្សារមូលបត្រ គឺជាកត្តាមួយយ៉ាងសំខាន់សំរាប់សេដ្ឋកិច្ចជាតិគេតែងនិយាយថាទីផ្សារមូលបត្រជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់រាល់ការបម្រែបម្រួលនៃបរិបទជាតិ និងអន្តរជាតិ (សេដ្ឋកិច្ច-សង្គម និងនយោបាយ) វានឹងធ្វើឱ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាមដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញពីឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋ - កិច្ចយ៉ាងណាពីព្រោះសន្ទស្សន៍ហ៊ុនរបស់ទីផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីសេដ្ឋកិច្ចជាតិ ហេតុនេះស្ទើរគ្រប់បណ្តាប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍទាំងអស់មានទីផ្សារមូលបត្រនេះហើយវាបានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ៖

-ទីផ្សារមូលបត្រជួយជំរុញឱ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់មិនមានតម្រូវការប្រើប្រាស់ទៅវិនិយោគនៅក្នុងសេដ្ឋកិច្ច។

-ទីផ្សារមូលបត្រគឺជាមធ្យោបាយបម្រែបម្រួលកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗមិនទាន់មានតម្រូវការប្រើប្រាស់ពួនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។

-ទីផ្សារមូលបត្រគឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។

-ទីផ្សារមូលបត្រជួយជំរុញឱ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មប្រកបដោយប្រសិទ្ធិភាព តម្លាភាព។

-ទីផ្សារមូលបត្រជួញជំរុញឱ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។

-ទីផ្សារមូលបត្រជួយបង្កើតនូវទំលាប់នៃការវិនិយោគ។

## ១.៦. គុណវិបត្តិទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច

ទោះបីជាទីផ្សារមូលបត្រមានគុណសម្បត្តិ ដ៏សំខាន់សម្រាប់ជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ក៏ដោយក៏មានគុណវិបត្តិមួយចំនួនដែរ ជាពិសេសសម្រាប់បណ្តាប្រទេសមានប្រព័ន្ធច្បាប់ទន់ខ្សោយ ដែល តែងតែជួយប្រទះនូវបញ្ហាដូចខាងក្រោម៖

-ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់(Speculation): គឺជាការជួញដូរមួយដែលមាន ការគិតគូរយ៉ាងម៉ត់ចត់ដើម្បីទទួលបានផលចំណេញ ដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាស កេងចំណេញក្នុងការទិញ-លក់នេះអាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយរំពឹងថានា ពេលអនាគតនឹងទទួលបានប្រាក់ចំណេញទៅយតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេង ចំណេញក្នុងការទិញ-លក់របៀបនេះវានឹងបង្កឱ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះធ្វើ ឱ្យមានភាពងាយស្រួលនៅពេលពួកគេត្រូវរ៉ូវគ្នាក្នុងការជួញដូរ ដែលនាំឱ្យស្ថានភាពនៅលើទីផ្សារ មានពេលខ្លះធ្វើឱ្យភាគហ៊ុនខ្វះ ឬលើសហើយធ្វើឱ្យមានចលនាឡើយចុះតម្លៃនៃការជួញដូរមូលបត្រ នៃការជួញដូរមូលបត្រនៅទីផ្សារមូលបត្រ។

-ការជួញដូរផ្ទៃក្នុង: មានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីឆ្លៀតឱ្យកាសយកព័ត៌មាន ផ្ទៃក្នុង របស់ក្រុមហ៊ុនដើម្បីធ្វើការជួញដូរភាគហ៊ុនស្វែងរកចំណេញរបស់ខ្លួនដែលមានឥទ្ធិពលដល់ តម្លៃភាគហ៊ុនរបស់ទីផ្សាយមូលបត្រដែលព័ត៌មាននោះមិនមែនព័ត៌មានសាធារណ:។

-ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ : គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេសមិនធ្វើសកម្មភាពដែលបណ្តាឱ្យឬអាចបណ្តាលឱ្យ លក្ខណ:ក្លែងបន្លំឬនាំឱ្យមានការយល់ ចំពោះការជួញដូរមូលបត្រ ឬធ្វើប្រតិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណ:សិប្បនិម្មិតទាក់ទង នឹងមូលបត្រនៅលើទីផ្សារមូលបត្រ។

-សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យមានការយល់ខុសធ្ងន់ធ្ងរដែល បណ្តាលឱ្យសាធារណជនទិញ-លក់មូលបត្រ ឬបណ្តាលឱ្យមានការកើនឡើង ឬថយចុះ ឬនៅថេរ ចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។

-ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រតម្រូវឱ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចសាជីវកម្មល្អដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រឹងអាជីវកម្មរបស់ខ្លួន។[8]

(http://www.secc.gov.kh)

[8] (http://www.secc.gov.kh)

# ជំពូកទី២៖

# វិស័យមូលបត្រនៅកម្ពុជា

## ២.១.តួអង្គសំខាន់ៗដែលចូលរួមក្នុងវិស័យមូលបត្រ

### ២.១.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យ ទីផ្សារមូលបត្រ គ្រប់គ្រងបណ្ដាប្រតិបត្តិការមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារអ្នកវិនិយោគមូលបត្រព្រមទាំងធានាអោយមានការជួញដូរមូលបត្រ ប្រកបដោយសណ្ដាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។

#### ២.១.១.១. ប្រវត្តិគណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនដែលត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃ គ.ម.ក ត្រូវបានធ្វើឡើងដោយអនុលោមតាមអនុក្រឹត្យស្ដីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០០៨។[9]

(អនុក្រឹត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ២០០៩)

#### ២.១.១.២. ចក្ខុវិស័យរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាហៅកាត់ថា គ.ម.ក. ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូល-បត្ររដ្ឋ និងច្បាប់ស្ដីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ គ.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណៈជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

#### ២.១.១.៣.បេសកកម្មរបស់គណៈកម្មការមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បី៖

[9] អនុក្រឹត្យស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ២០០៩

-បង្កើតនិងរក្សាអោយមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការការពារសិទ្ធិស្របច្បាប់ របស់អ្នកវិនិយោគ និងធានាអោយមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។

- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រអោយមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះអោយមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

-ជំរុញអោយមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យតាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។

-ជំរុញអោយមានការវិនិយោគទិនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈនៅក្នុងព្រះរាជាណា-ចក្រកម្ពុជា។

### ២.១.២. ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)

#### ២.១.២.១. ប្រវត្តិ ផ.ម.ក.

ដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុងការជំរុញកំនើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និងការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃបព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រហាកូរ៉េបានចុះហត្ថលេខាអនុស្សរណៈយោគយល់ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានប្រកាសឱ្យបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែ មិនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រហាកូរ៉េបានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សាមូលបត្រ (ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា) ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សាមូលបត្រកម្ពុជាបានចុះបញ្ជីពាណិជ្ជកម្មនៅ ថ្ងៃទី២៣ខែកុម្ភៈ ឆ្នាំ ២០១០ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់បាប់ភាគហ៊ុនចំនួន ៤៥%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិការរក្សាទុកមូលបត្រពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយមូលបត្រមហាជន។

**២.១.២.២.ចក្ខុវិស័យ និងបេសកកម្ម ផ.ម.ក.**

-ចក្ខុវិស័យ គឺដើម្បីកសាង នូវ **មហាទិដ្ឋី** ហិរញ្ញវត្ថុសម្រាប់កម្ពុជា។

-បេសកកម្មៈ

១.ដើម្បីសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា

២.ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងអស់ក្នុងប្រទេសនិងក្រៅប្រទេស

៣.ដើម្បីបង្កើតនូវផលិតផលនិងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់

៤.ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៏ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា

**២.១.២.៣.មុខងាររបស់ផ្សារមូលបត្រកម្ពុជា(ផ.ម.ក.)**

**ក. <u>ប្រតិបត្តិករទីផ្សារមូលបត្រ</u>** (Market Operation)

ប្រតិបត្តិករទីផ្សារមូលបត្រជានិយ័តករជួរមុខក្នុងការគ្រប់គ្រងនូវដំណើរការជួញដូរមូលបត្រក្នុងផ្សារមូលបត្រ។

ប្រតិបត្តិករទីផ្សារមូលបត្រ សំដៅដល់បុគ្គលដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រដូចជាៈ

-ការផ្តល់នូវសេវាសម្រាប់សម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីឲ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបាននូវការបន្ស៊ីលើប្រតិបត្តិការបញ្ជាទិញ-លក់មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិក។

- សកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយ គ.ម.ក។

ប្រតិបត្តិករនេះមានតួនាទីផ្គូរផ្គងតំលៃរវាងអ្នកលក់ និងអ្នកទិញ ដើម្បីរកតំលៃមួយអោយត្រូវគ្នាដោយផ្តល់អាទិភាពដល់អ្នកលក់ដែលដាក់តម្លៃទាបជាងគេ។

អាទិភាពនៃការផ្គូរផ្គងនេះ គឺផ្តោតទៅលើតំលៃពោលគឺចំពោះអ្នកទិញណាដែលហ៊ានអោយថ្លៃខ្ពស់គេនឹងទទួលបានមុន ហើយអ្នកលក់ណាដែលហ៊ានលក់ក្នុងតំលៃទាបគេនឹងទទួលបានមុន។

ក្នុងករណីតំលៃដូចគ្នា គេពិនិត្យមើលលើពេលវេលា។ បើពេលដូចគ្នាទៀត គេមើលលើបរិមាណ ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.២៥%។

**ខ. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ** ( Clearing and Settlement Operator )

ប្រតិបត្តិករនេះជាអ្នកធានាថាមូលបត្របានដល់ដៃអ្នកទិញ ហើយលុយបានដល់ដៃអ្នកលក់ ក្នុងពេលតែមួយក្រោយពីការផ្គូរផ្គងទទួលបានជោគជ័យ។

ត្រួតពិនិត្យមូលបត្រខាងអ្នកលក់(ថាតើមានមូលបត្រគ្រប់គ្រាន់សម្រាប់លក់ឬទេ) និងខាងអ្នកទិញ (តើមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទិញឬទេ) ដើម្បីបញ្ចៀសនូវហានិភ័យការទូទាត់។

គេដកសាច់ប្រាក់ពីអ្នកទិញ តាមរយៈភ្នាក់ងារទូរទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដែលមានដូចជាធនាគារអេស៊ីលីដា, ធនាគារកាណាឌីយ៉ា និងធនាគារ ប៊ី អាយ ឌី ស៊ី។ គេដកមូលបត្រពីអ្នកលក់តាមរយៈប្រតិបត្តិកររក្សារទុកមូលបត្រ។ ការផាត់ទាត់ធ្វើឡើងនៅ២ថ្ងៃក្រោយបន្ទាប់ពីថ្ងៃជួញដូរ (T+2) ។ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ ០.១០%។

**❖ នីតិវិធីនៃប្រតិបត្តិការផាត់ទាត់ និងទូទាត់**

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នារបស់សមាជិកនីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវជូនដំណឹងអំពីព័ត៌មានដូចខាងក្រោមដល់សមាជិកនៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់៖

១. កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២. បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន។

៣. ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗដូចខាងក្រោម ៖

-ចំពោះមូលបត្រត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗសម្រាប់សមាជិកដែលពាក់ព័ន្ធ។

-ចំពោះសាច់ប្រាក់ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុបសម្រាប់សមាជិកនីមួយៗដែលពាក់ព័ន្ធ។

សមាជិកត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ នៅមុនម៉ោង ៨: ៣០នាទីព្រឹក នៅកាលបរិច្ឆេទទូទាត់ (Settlement

Date) ហើយប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវធ្វើការទូទាត់មូលបត្រ និងសាច់ប្រាក់ បន្តទៅឲ្យសមាជិកដែលត្រូវទទួលការទូទាត់បន្ទាប់ពីម៉ោង ៨:៣០នាទីព្រឹក នៅកាលបរិច្ឆេទទូទាត់។

(ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ)

**គ. ប្រតិបត្តិកររក្សាទុកមូលបត្រ** ( Central Securities Deposit )

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់បុគ្គលយល់ព្រមជាមួយបុគ្គលមួយទៀតដែលជាអតិថិជនរបស់ខ្លួនថាផ្តល់សេវាកម្ម ដូចខាងក្រោមនេះទោះបីជាអតិថិជនធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងនាមបុគ្គលផ្សេងទៀតក៏ដោយ ៖

១.កាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀតក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

២.ទទួលរក្សាទុកនូវមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដទៃទៀតទោះបីមានរូបភាពជាវិញ្ញាបនប័ត្រកម្មសិទ្ធ ឬជាទម្រង់អរូបី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រក្នុងនាម អតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។

៣.ផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងទៀត ដែលទាក់ទិននឹងការផ្តល់សេវាកម្មដូចមានចែងក្នុងកថាខណ្ឌ (១) និង(២)។

ប្រតិបត្តិករនេះ ជាអ្នករក្សារទុកមូលបត្រជូនវិនិយោគិន ព្រោះវិនិយោគិនមិនអាចយកមូលបត្រមកទុកនៅគេហដ្ឋានរបស់ខ្លួនបានឡើយ។ថ្លៃសេវាដែលយកដោយប្រតិបត្តិករនេះគឺ០.១០%។

**កម្រៃសេវាប្រតិបត្តិការរក្សាទុកមូលបត្រ**

សមាជិក និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រត្រូវបង់ប្រាក់កម្រៃសេវារក្សាទុកមូលបត្រ ប្រាក់កម្រៃផ្ទេរវាងគណនីមូលបត្រ និងប្រាក់កម្រៃសេវាផ្សេងទៀតសម្រាប់សេវាដែលទទួលបាន។

សមាជិកនិងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃសេវាជូន ផ.ម.កដូចខាងក្រោម៖

១.ប្រាក់កម្រៃសេវារក្សាទុកមូលបត្រ ជាកម្រៃសម្រាប់ការដាក់ផ្ញើមូលបត្រដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ Initial Public Offerings (IPO) ។ប្រាក់កម្រៃសេវារក្សាទុកមូលបត្រប្រចាំខែ ត្រូវបង់នៅថ្ងៃទី ១០ នៃខែបន្ទាប់ពីខែដែលប្រាក់កម្រៃនោះបានកើតឡើង ហើយមូលបត្រដែលបានដាក់ផ្ញើ ត្រូវបានដកវិញដោយសារមូលហេតុនៃការបិទគណនីនៅកាលបរិច្ឆេទបិទគណនីតាមលក្ខខណ្ឌដូចខាងក្រោម៖

ក. អត្រា២០ (ម្ភៃ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០,០០០,០០០ (ដប់លាន)រៀល។ ក្នុងករណីនេះកម្រៃសេវា ត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូនក្នុងសៀវភៅគណនីមូលបត្រ។

ខ. អ្នកបង់ប្រាក់ជាបុគ្គលដែលទទួលការអនុញ្ញាតឲ្យដាក់ផ្ញើមូលបត្រ។

២. កម្រៃសេវាផ្ទេរមូលបត្ររវាងគណនី

ក.អត្រាប្រាក់កម្រៃនៃការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋានទឹកប្រាក់នៃការជួញដូរដែលបានទូទាត់ តាមអត្រា ១០/១០,០០០ (ដប់ភាគមួយម៉ឺន ចំពោះមូលបត្រកម្មសិទ្ធិ ហើយទឹកប្រាក់កម្រៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ. អ្នកត្រូវបង់ប្រាក់ជាក្រុមហ៊ុនមូលបត្រជាសមាជិក។

គ. ពេលវេលាបង់ប្រាក់នៅម៉ោង ៨: ៣០នាទីព្រឹក នៅកាលបរិច្ឆេទទូទាត់។

៣. កម្រៃប្រតិបត្តិការផ្សេងៗ

ក.ប្រាក់កម្រៃនៃការផ្ទេរមូលបត្រដែលមិនត្រូវបានជួញដូរ គឺ ១៥ (ដប់ប្រាំ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០,០០០,០០០ (ដប់លានរៀល) រៀល។ សមាជិក និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រត្រូវបង់ប្រាក់កម្រៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក នៅពេលស្នើសុំផ្ទេរមូលបត្រ។

ខ. កម្រៃនៃការដក់មូលបត្រ គឺ២០ (ម្ភៃ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០,០០០,០០០ (ដប់លានរៀល)។ សមាជិក និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបង់ប្រាក់កម្រៃនេះជូនប្រតិបត្តិករ រក្សាទុកមូលបត្រនៃ ផ.ម.ក នៅពេលស្នើសុំផ្ទេរមូលបត្រ។[10]

(ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ)

**២.១.២.៤. ក្រុមហ៊ុនមូលបត្រ** (Securities Firm)

ក្រុមហ៊ុនមូលបត្រអាចធ្វើអាជីកម្មដោយពឹងផ្អែកទៅលើ អាជីវកម្មធនាទិញមូលបត្រ (Securities Underwriting) អាជីវកម្មជួញដូរមូលបត្រ (Securities dealing) អាជីវកម្មជើងសារមូលបត្រ (Securities Brokerage) និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ (Securities Advisory)។

-អាជីវកម្មធនាទិញមូលបត្រ (Securities Underwriting) គឺជាស្ថាប័នដែលផ្តល់សេវាកម្មសម្រាប់ការបោះផ្សាយលក់មូលបត្រ និងមានសិទ្ធិក្នុងការជួញដូរមូលបត្រតាមបញ្ជាអតិថិជន និងខ្លួនឯងផ្ទាល់។

[10] ប្រកាសស្តីពី ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ

- ផ្តល់ប្រឹក្សាសំខាន់លើការបោះផ្សាយលក់មូលបត្រជាសាធារណៈដូចជាការដាក់តម្លៃមូលបត្រ (Pricing) ការកំណត់ទំហំទឹកប្រាក់ (Issue Amount) និងចំនួនមូលបត្រ (Number of to be Issue) នៃសំណើរបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ (Distribution Timely) ជាដើម។
- ទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្របូចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់បត្រជាសាធារណៈ។
- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រអាចធ្វើសកម្មភាពអាជីវកម្មដូចជា អាជីវកម្មធានាទិញមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

-អាជីវកម្មជួញដូរមូលបត្រ (Securities dealing) គឺជាអ្នកធ្វើការទិញ លក់មូលបត្រដោយផ្ទាល់នៅលើទីផ្សារហិរញ្ញវត្ថុ (ធ្វើការជួញដូរតាមបញ្ជារបស់អតិថិជន និងមានសិទ្ធិក្នុងការជួញដូរផ្ទាល់ខ្លួន)។

- ជាការជួញដូរមូលបត្រលើគណនីផ្ទាល់ ដោយធានារ៉ាប់រងហានិភ័យដោតខ្លួនឯង។
- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រធ្វើជាក្រុមហ៊ុនជួញដូរមូលបត្រអាចធ្វើសកម្មភាពអាជីវកម្មដូចជា អាជីវកម្មធានាទិញមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

-អាជីវកម្មជើងសារមូលបត្រ (Securities Brokerage) គឺជាអ្នកសម្រួលប្រតិបត្តិការទិញ-លក់មូលបត្រដល់អតិថិជន កំរៃរបស់ឈ្នួញជើងសារបានពីកំរៃជើងសារប្រតិបត្តិការ (មានសិទ្ធិជួញដូរតាមតែបញ្ជារបស់អតិថិជន) ។

- ការទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួនដោយទទួលបាននូវកម្រៃជើងសា។
- ការទិញ ឬលក់មូលបត្រក្នុងនាមក្រុមហ៊ុនផ្ទាល់ និងតាមបញ្ជាអតិថិជនរបស់ខ្លួនដោយទទួលបាននូវកម្រៃជើងផ្សារ។

- ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មជើងសាមូលបត្រ អាចធ្វើអាជីវកម្មដូចជា អាជីវកម្មជើងសាមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

-អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ (Securities Advisory)

- ការផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រដល់អ្នកវិនិយោគិនសាធារណៈដោយផ្ទាល់ដោយទទួលបានកម្រៃសេវា។
- ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនដល់អ្នកវិនិយោគសាធារណៈ។
- ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគអាចធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគប៉ុណ្ណោះ។

**២.១.២.៥. ក្រុមហ៊ុនបោះផ្សាយមូលបត្រ**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាអង្គភាពដែលបោះផ្សាយ(លក់)មូលបត្រដែលមានតម្លៃតំណាងឲ្យអត្រាភាគរយនៃភាគហ៊ុននៅក្នុងអង្គភាពនោះ ឬជាការសន្យាមួយថានឹងបង់ត្រឡប់មក វិញនូវប្រាក់កម្ចី (Loan) ជាមួយការប្រាក់ (សម្រាប់សញ្ញាបណ្ណ) ឬបង់ភាគលាភ (សម្រាប់ប័ណ្ណភាគហ៊ុន)។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ អាចជាស្ថាប័នសាធារណៈ ឬក្រុមហ៊ុនមហាជនដែលស្វែងរកទុននៅលើទីផ្សារមូលបត្រតាមរយៈការលក់ភាគហ៊ុនរបស់ខ្លួន។

**២.១.២.៦. វិនិយោគិន** ( Investors )

វិនិយោគិន សំដៅដល់អ្នកទិញ និងអ្នកលក់ (អ្នកជួញដូរ) មូលបត្រដើម្បីស្វែងរកប្រាក់ចំណេញ (ហៅថាចំណូល) ទៅលើការវិនិយោគរបស់ខ្លួន។ ជាទូទៅវិនិយោគិននៅលើទីផ្សារមូលបត្រចែកចេញជាពីរប្រភេទគឺ វិនិយោគិនជាបុគ្គល (Individual Investors) និងវិនិយោគិនជាស្ថាប័ន (Institutional Investors) ។

- វិនិយោគិនជាបុគ្គល (Individual Investors) គឺជាសាធារណៈជនទូទៅ ឬអាចហៅម៉្យាងទៀតថាជាវិនិយោគិនរាយ (Retail Investors) ដោយសារវិនិយោគិនទាំងនេះទិញ និងលក់មូលបត្រតាមរយៈទីផ្សារលក់រាយមួយ (A Retail Market) ហើយក្នុងកម្រិតតម្លៃលក់រាយពីឈ្មួញជើងសារមូល-បត្រ (Brokers) ។ កម្រិតនៃការវិនិយោគសម្រាប់វិនិយោគិនជាបុគ្គល គឺវិវឌ្ឍន៍ពីអ្នកកេងចំណេញ (Speculators) ទៅជាអ្នកទិញ ឬអ្នកកាន់កាប់សន្លឹកហ៊ុន (Hold Investors) ។

- វិនិយោគិនជាស្ថាប័ន (Institutional Investors) ៖ ក្រុមហ៊ុនហិរញ្ញវត្ថុធំៗជាច្រើន វិនិយោគនៅក្នុងទីផ្សារមូលធន(Capital Market) ជាផ្នែកមួយនៃគំរូធ្វើជំនួញរបស់ពួកគាត់។ ក្រុមហ៊ុនធានារ៉ាប់រង

មានផ្នែកមួយដើម្បីវិនិយោគប្រាក់ធានាភ័យ (Premium) ដែលបានបង់ដោយកាន់កាប់គោលនយោបាយធានារ៉ាប់រងរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនសាជីវកម្មធំៗ ឬភ្នាក់ងាររដ្ឋាភិបាលនានាដែលមានទ្រព្យសកម្មជាមូលនិធិសោធន៍និវត្តន៍ (Pension Fund) អ្នកចាត់ចែងគ្រប់គ្រងការវិនិយោគសម្រាប់ពួកគេ។ ផ្នែក បរធនបាលកិច្ចរបស់ធនាគារមួយចំនួន (Bank Trust Department) ធ្វើការវិនិយោគ ប្រាក់តម្កល់ (Deposits) នៃអតិថិជនរបស់ខ្លួនដើម្បីបង្កើតប្រាក់ចំណេញ។ អ្នកទាំងនេះ ត្រូវបានគេឲ្យឈ្មោះថា "វិនិយោគិនស្ថាប័ន"។ វិនិយោគិនជាស្ថាប័នទាំងនេះ មានឥទ្ធិពលជាច្រើនក្នុងទីផ្សារមូលបត្រដោយសារទំហំ និងចំនួនសាច់ប្រាក់ដែលចូលរួមនៅក្នុងទីផ្សារមានចំនួនច្រើន។[11]

(បៀនសាំង,២០១១,ទំព័រទី១៥-១៦)

### ២.១.២.៧. តួអង្គសំខាន់ៗផ្សេងទៀត

-ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ (Law firms)

- ចូលរួមក្នុងក្រុមការងារ IPO
- ត្រួតពិនិត្យ និងផ្តល់យោបល់ពីការបំពេញកាតព្វកិច្ចផ្នែកច្បាប់
- ធ្វើរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់
- ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ត្រូវទទួលស្គាល់ដោយគណៈកម្មការមូលបត្រកម្ពុជា

-ក្រុមហ៊ុនគណនេយ្យជំនាញ (Professional Accounting Frims)

- ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនដ៏ទៃទៀតដែលធ្វើធុរកិច្ចនៅក្នុងវិស័យមូលបត្រត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលទទួលបានការទទួលស្គាល់ដោយគណៈកម្មការមូលបត្រកម្ពុជាដើម្បីធ្វើសវនកម្មនូវរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវស្តង់ដាដែលបានកំណត់។

-ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ (Valuation Companies)

- ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនដ៏ទៀត ដែលធ្វើធុរកិច្ចនៅក្នុងវិស័យមូលបត្រត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យដែលទទួលបានការទទួលស្គាល់ដោយគណៈកម្មការមូលបត្រកម្ពុជាដើម្បីវាយ តម្លៃទ្រព្យសកម្មដោយអនុវត្តឲ្យខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់

-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar Agent)

[11] បៀនសាំង,២០១១,ទំព័រទី១៥-១៦

- គ្រប់គ្រងនូវដំណើរការនៃការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រ
- កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រ
- ធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូកបត្រ

-ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (Cash Settlement Agent)

- ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចជាការផ្ទេរ ឬការបង្វែរសាច់ប្រាក់រវាងភាគីជួញដូរ
- ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ប្រកបដោយសុវត្ថិភាព
- បំពេញប្រតិប្តិការឲ្យដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ

-ក្រុមហ៊ុនផ្តល់សេវាកម្មបកប្រែ (Translation Service Company)

- បកប្រែឯកសារពាក់ព័ន្ធនឹង IPO ឲ្យបានត្រឹមត្រូវតាមអត្ថន័យដើម

-ក្រុមហ៊ុនផ្តល់សេវាកម្មបោះពុម្ព (Printing Service Company)

- ធានាថាឯកសារបោះពុម្ពពាក់ព័ន្ធនឹង IPO មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដើម។

-ភ្នាក់ងារវាយតម្លៃលទ្ធភាពសងបំណុល (Credit Rating Agency)

- ទទួលបានការទទួលស្គាល់ពីគណៈកម្មការមូលបត្រកម្ពុជា សម្រាប់ការផ្តល់សេវាភ្នាក់ងារវាយតម្លៃលទ្ធភាពសងបំណុលដល់ក្រុមហ៊ុនបោះផ្សាយ។
- ផ្តល់នូវសេវាយតម្លៃលទ្ធភាពសងបំណុលក្នុងវិស័យមូលបត្រដែលអាចទុកចិត្តបាន និងថែទាំនូវប្រតិបត្តិការវាយតម្លៃលទ្ធភាពសងបំណុល និងមានឧបករណ៍ជំរុញផ្សេងៗ ដែលមានសុវត្ថិភាពគ្រប់គ្រាន់ក្នុងប្រព័ន្ធដែលអាចប្រើប្រាស់បាន និងការគ្រប់គ្រងហានិភ័យផ្សេងៗ។

### ២.១.២.៨. លក្ខខណ្ឌនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ

ដើម្បីបោះផ្សាយលក់មូលបត្រជាសាធារណៈបានសម្រួលដល់ការយល់ដឹងធានាឲ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក) បានដាក់ចេញនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដូចខាងក្រោម៖

**១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ**

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជូនទៅ គ.ម.ក ដែលលិខិតមានខ្លឹមសារ ៣ (បី) ចំនុចដូចខាងក្រោម ៖

ក. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)។

ខ. គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើក ដំបូង (Expected Timetable) ។

គ. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹង ទុក (Expected IPO Team) រួមមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

**២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ**

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយត្រូវជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាពី គ.ម.ក។

**៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង**

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី គ.ម.ក ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។

**៤.ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)**

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

**៥.ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនមូលបត្រកម្ពុជា។

**៦.ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក**

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបើផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មានមុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

**៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ( Book Building)**

ក្រោយពីទទួលបាន ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រ

តាមប៊ុកបៀលនឹងអាចដាក់លក់នៅលើទីផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលនឹងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូនគ.ម.ក ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**១០. ការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និងជំពូកទី ៤ នៃប្រកាសស្តីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈនេះ។

**១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន គ.ម.ក។

**១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូល-បត្រត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**២.១.២.៨.១. លក្ខខណ្ឌបរិមាណ**

ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវបំពេញតាម លក្ខខណ្ឌបរិមាណដូចខាងក្រោម៖

- មានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច៥,០០០លានរៀល (ប្រាំពាន់លានរៀន) គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

- ត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធយ៉ាងតិចបំផុត ២០ (ម្ភៃ) ភាគរយនៃមូលធនភាគហ៊ុនិកសរុបសម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកតិចជាង ២០,០០០,០០០,០០០ (ម្ភៃពាន់លាន) រៀលនិងត្រូវបោះផ្សាយលក់មូលបត្រកម្មសិទ្ធិយ៉ាងតិច ១៥%នៃមូលធនភាគហ៊ុនិកសរុប សម្រាប់ក្រុមហ៊ុនដែលមានមូលធនភាគហ៊ុនិកចាប់ពី ២០,០០០,០០០,០០០ (ម្ភៃពាន់លាន) រៀលឡើងទៅ។

- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ៥០០,០០០,០០០ (ប្រាំរយលាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងមានផលចំណេញសរុបសម្រាប់រយៈពេល ៣ (បី) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយចំនួន ១,០០០,០០០,០០០ (មួយពាន់លាន) រៀល។

- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុត ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

- ត្រូវទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុតលើការដាក់តម្លៃមូលបត្រដែលធ្វើសំណើរលក់។

### ២.១.២.៨.២. លក្ខខណ្ឌគុណភាព

លក្ខខណ្ឌគុណភាពដែលក្រុមហ៊ុនមានបំណងចង់បោះផ្សាយត្រូវបំពេញមាន៖

- ត្រូវតែជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

- ត្រូវមានសកម្មភាពអាជីវកម្មដែលមានស្ថេរភាព និងធានាឲ្យមានកំណើនរយៈពេលវែង។

- មានស្ថេរភាពហិរញ្ញវត្ថុ និងមានមូលធនបង្វិលគ្រប់គ្រាន់។

-ត្រូវគោរពទៅតាមគោលការណ៍អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រជាសាធារណៈ។

- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។

- ត្រូវមានកិច្ចសន្យាធានាទិញមូលបត្រជាមួយក្រុមហ៊ុនមូលបត្រ។

- ត្រូវរៀបចំឲ្យបានពេញនូវឯកសារផ្តល់ព័ត៌មាន ដើម្បីទទួលបានការអនុញ្ញាត និងចុះបញ្ជីដោយ គ.ម.ក.។

- មានយន្តការដោះស្រាយទំនាស់ផលប្រយោជន៍ របាយការណ៍ហិរញ្ញវត្ថុធ្វើសវនកម្មដោយឯករាជ្យរយៈពេល ៣ឆ្នាំចុងក្រោយ។

### ២.១.២.៩. គំនូសតាងពីនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ

ដំហ៊ាននៃការបោះផ្សាយលក់មូលបត្រជាសាធារណៈមានដូចខាងក្រោម៖



### ២.១.៣. ដំណាក់កាលប៊ុកបៀលឌីង ( Book Building )

១. បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពី គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) លើសំណើរសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីង ដោយត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារៈណៈ ដើម្បីអញ្ជើញវិនិយោគិនអោយចូលរួម។

២.ដើម្បីជម្រុញអោយវិនិយោគិនចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាថាថ្លៃមូលបត្រកម្មសិទ្ធិ បានឆ្លុះបញ្ចាំងតម្រូវការទីផ្សារ មូលបត្រដែលត្រូវដាក់ឲ្យធ្វើប៊ុកបៀលឌីងមានចំនួន ៧០(ចិតសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលៃបំរុងទុកសម្រាប់លក់ជូនបុគ្គលិក ករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្តតាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ដោយឡែកចំណែកមូលបត្រកម្មសិទ្ធិដែលនៅសល់ ៣០ (សាមសិប) ភាគរយទៀត គឺត្រូវលៃបំរុងទុកសម្រាប់ការធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

៣. វិនិយោគិនដែលបានចូលរួមក្នុងដំណើរប៊ុកបៀលឌីង ត្រូវបំពេញពាក្យសុំធ្វើប៊ុកបៀលឌីងដែលកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងធ្វើបរិវិសកម្ម បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីងនេះ។

៤. វិនិយោគិនដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០(ដប់) ភាគរយនៃថ្លៃមូលបត្រកម្មសិទ្ធិសរុប ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀល ឌីង។

៥. ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើរលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងនិងវិនិយោគិនដែលមិនទទួលបានជោគជ័យ។

៦. វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលដាក់ថ្លៃខ្ពស់ជាង ឬស្មើថ្លៃមូលបត្រកម្មសិទ្ធិដែលបានធ្វើសំណើរលក់ (Offering Price) ។ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិ ដែលត្រូវធ្វើ

សំណើរលក់ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted –Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំធ្វើចូលរួមប៊ុកបៀលឌីង។

៧. ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនា អាចត្រូវបានកែតម្រូវ (Adjustment) ដើម្បីអោយឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ ដោយមានការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា។

៨. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ បន្ទាប់ពីគណៈកម្មការមូលបត្រកម្ពុជា បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្ទេរប្រាក់កក់១០(ដប់)ភាគរយជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងនិងមានបំណងបន្តធ្វើបរិវិសកម្ម។

### ២.១.៤. ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ( Subscription )

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងដោយក្រុមហ៊ុនធានាទិញមូលបត្រ បន្ទាប់ពីបានបញ្ចប់ការធ្វើប៊ុកបៀលឌីង ក៏ដូចជាទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារព័ត៌មានការធ្វើបរិវិសកម្មត្រូវបានចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារព័ត៌មាននៅមានសុពលភាព។ វិនិយោគិន ត្រូវចុះឈ្មោះទិញមូលបត្រតាមរយៈក្រុមហ៊ុនធានាទិញមូលបត្រ។ វិនិយោគិនដែលទទួលបានជោគជ័យក្នុង ប៊ុកបៀលឌីងអាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិលើសពីចំនួនដែលដាក់ពាក្យស្នើសុំចូលរួមប៊ុកបៀលឌីងដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែមដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មដែលត្រូវធ្វើ។ ក្រុមហ៊ុនមូលបត្របញ្ជូនពាក្យស្នើសុំធ្វើបរិវិសកម្មរបស់វិនិយោគិន ទៅភ្នាក់ងារបញ្ជិកាមូលបត្រ។ បន្ទាប់មកភ្នាក់ងារបញ្ជិកាមូលបត្ររៀបចំឯកសារពាក់ព័ន្ធនឹងការធ្វើបរិវិសកម្ម ធ្វើការផ្ទៀងផ្ទាត់ពីទំហំនៃការធ្វើបរិវិសកម្មរបស់វិនិយោគិននីមួយៗ និងធ្វើការពិនិត្យពីភាពត្រឹមត្រូវនៃចំនួនទឹកប្រាក់ទៅតាមចំនួនមូលបត្រ ដែលបានធ្វើបរិវិសកម្មនីមួយៗក្រោយពីទទួលបានសំណុំបែបបទនៃការធ្វើបរិវិសកម្មពីក្រុមហ៊ុនធានាទិញមូលបត្រ។ ភ្នាក់ងារបញ្ជិកាមូលបត្រធ្វើការបូកសរុបបញ្ជីឈ្មោះអ្នកធ្វើបរិវិសកម្ម និងចំនួនមូល-បត្រដែលបានធ្វើបរិវិសកម្មដើម្បីបែងចែកមូលបត្របន្ទប់ពីរយៈពេលធ្វើបរិវិសកម្ម។

**ការធ្វើបរិវិសកម្មត្រូវអនុវត្តដូចខាងក្រោម៖**

- ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក។

- ក្រុមហ៊ុនមូលបត្រ ត្រូវតែរក្សាប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែក នៅធនាគារពាណិជ្ជ។

- ការធ្វើបរិវិសកម្ម ត្រូវបានចាប់ទុកថាបានបញ្ចប់នៅពេលអ្នកធ្វើបរិវិសកម្មបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មបានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។

**ការធ្វើបរិវិសកម្មត្រូវកំណត់ដូចខាងក្រោម៖**

- ចំនួនភាគហ៊ុន ២០ (ម្ភៃ) ភាគរយ នៃសំណើលក់ជាសាធារណៈសរុបត្រូវបានបម្រុងសម្រាប់វិនិយោគិនសញ្ជាតិខ្មែរ។

- ចំនួនភាគហ៊ុន ៨០ (ប៉ែតសិប) ភាគរយ ដែលនៅសល់ត្រូវបើកចំហចំពោះវិនិយោគិនសញ្ជាតិខ្មែរ និងវិនិយោគិនមិនមែនសញ្ជាតិខ្មែរ។

**បន្ទាប់ពីបែងចែកមូលបត្រចប់ ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវ៖**

- ផ្តល់ព័ត៌មានជាផ្លូវការដល់វិនិយោគិនដែលធ្វើបរិវិសកម្មបានសម្រេច និងមិនបានសម្រេច ទៅក្រុមហ៊ុនធានាទិញមូលបត្រ និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

- រៀបចំបញ្ជូនព័ត៌មានលម្អិតពីអ្នកធ្វើបរិវិសកម្មបានសម្រេចដែលក្លាយជាកម្មសិទ្ធិករមូលបត្រ ទៅប្រតិបត្តិកររក្សាទុកមូលបត្រដើម្បីធ្វើការផ្ទេរមូលបត្រពីគណនីមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រទៅគណនីមូលបត្ររបស់អ្នកធ្វើបរិវិសកម្មបានសម្រេចទាំងនោះ។

❖ **កិច្ចដំណើរការនៃការធ្វើបរិវិសកម្មមូលបត្រ**

## គណៈកម្មការមូលបត្រ



### ២.១.៥. ការចុះបញ្ជី

ការចុះបញ្ជី គឺជាដំណើរការដែលអនុញ្ញាតឲ្យក្រុមហ៊ុនមួយយកភាគហ៊ុនទាំងអស់របស់ខ្លួនមកចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា(ផ.ម.ក.)។ ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)ស្វាគមន៍នូវរាល់សំណើសុំព័ត៌មានពីសំណាក់បុគ្គល ក៏ដូចជាក្រុមហ៊ុនដែលមានបំណងស្វែងយល់អំពីផលប្រយោជន៍នៃការចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)។

❖ **នីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ**

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញត្រូវចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម និងផ្តល់នូវឯកសារពាក់ព័ន្ធជូន ផ.ម.ក.។ ផ.ម.ក.ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល០៥ថ្ងៃនៃថ្ងៃធ្វើការ។

**លក្ខខណ្ឌតម្រូវក្នុងការចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ**

- លក្ខខណ្ឌតម្រូវជាតួលេខ ៖ ត្រូវមានចំនួនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១%(មួយភាគរយ)ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០(ដប់)ភាគហ៊ុនឡើងទៅត្រូវមានចំនួនយ៉ាងតិច ២០០នាក់។ ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១%ត្រូវមានចំនួនសរុបចាប់ពី ២០០,០០០ភាគហ៊ុនឡើងទៅ ឬ១៥%នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

- លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ ៖ មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ០១ឆ្នាំចុងក្រោយរហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រ ជាផ្លូវការ។ មូលបត្រទាំងអស់ដែលបានបោះផ្សាយត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដែលទទួលបានការអនុញ្ញាតពី គ.ម.ក។

# ជំពូកទី៣៖
# ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ភ្នំពេញ
# អេសអ៊ីហ្សិត ភីអិលស៊ី(PPSEZ)

## ៣.១. ប្រវត្តិក្រុមហ៊ុន

ប្រវត្តិរបស់ PPSEZ ក្នុងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសចាប់ផ្តើមក្នុងឆ្នាំ ២០០៥ នៅពេលលោកជំទាវឧកញ៉ា **លីម ឈីវហូរ** មានគម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសមួយ។ ស្របពេលនោះមានក្រុមហ៊ុនមួយឈ្មោះ ក្រុមហ៊ុន យេផេន-ខេមបូឌាន ឌីវែលឡុបមេន អ៊ិនស្ទីស្ទូសិន (JDI) បានផ្តល់ប្រឹក្សាឱ្យលោកជំទាវឧកញ៉ា **លីម ឈីវហូរ** ធ្វើការអភិវឌ្ឍដីមួយកន្លែងឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេស ហើយដែលដីនោះបច្ចុប្បន្នជាទីតាំងរបស់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។ ក្រុមហ៊ុន JDI គឺជាក្បាលម៉ាស៊ីនឯករាជ្យ និងជាក្រុមហ៊ុនផ្តល់ប្រឹក្សាដែលមានជំនាញក្នុង ការអភិវឌ្ឍអន្តរជាតិ។ ជាមួយនឹងជំនួយ និងការប្រឹក្សាដែលផ្តល់ដោយក្រុមហ៊ុន JDI លោកជំទាវឧកញ៉ា **លីម ឈីវហូរ** និងក្រុមហ៊ុន JDI បានធ្វើការរួមគ្នាលើការសិក្សាភាពដែលអាចធ្វើទៅបាននៃការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសនៅរាជធានីភ្នំពេញ។ ជាលទ្ធផល ក្រុមហ៊ុនទាំងពីរបានរៀបចំប្លង់មេមួយសម្រាប់អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ដែលតំបន់សេដ្ឋកិច្ចពិសេសនឹងត្រូវបានអភិវឌ្ឍជាបី (០៣) ដំណាក់កាល។ ប្លង់មេត្រូវបានរៀបចំឡើងដោយពិចារណាលើឧស្សាហកម្មដែលមានសក្តានុពលនានាដែល PPSEZ ផងដែរនូវបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធដែលអាចសម្រួលដល់ប្រតិបត្តិការរបស់វិនិយោគិន។

បន្ទាប់ពីបញ្ចប់គម្រោងសិក្សាលទ្ធភាព និងការសរុបចុងក្រោយលើប្លង់មេ ក្រុមហ៊ុនត្រូវបានបង្កើតឡើងដោយ លោកជំទាវឧកញ៉ា **លីម ឈីវហូរ** ក្នុងឆ្នាំ២០០៦ បន្ទាប់ពីបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ ដើមទុនចុះបញ្ជីដំបូងរបស់ក្រុមហ៊ុនយើងមានចំនួន១ លានដុល្លារអាមេរិក។ បន្ទាប់ពីការបង្កើតរួចរាល់ ក្រុមហ៊ុនបានទិញដីដែលមានទំហំសរុបប្រមាណ ៣៥២,៤៦ ហិចតាពី លោកជំទាវឧកញ៉ា **លីម ឈីវហូរ** ក្នុងតម្លៃប្រមាណ៦,៥០ លានដុល្លារអាមេរិក។ ក្នុងឆ្នាំដដែលក្រុមហ៊ុនបានទិញយកក្រុមហ៊ុនជាសម្ព័ន្ធភាពមួយគឺ ក្រុមហ៊ុន Japan (Cambodia) Development Corporation Co.,Ltd (JCDC) តាមរយៈការលក់ដីដែលមានតម្លៃ ៣លានដុល្លារអាមេរិក ក្នុងបរិវេណ PPSEZ ទៅឱ្យក្រុមហ៊ុន JCDC ដើម្បីជាថ្នូរនៃការដោះដូរនូវមូលធនចំនួនសែសិបប្រាំបួនភាគរយ(៤៩%) នៃភាគហ៊ុនសរុបរបស់ ក្រុមហ៊ុន JCDC។

ការសាងសង់ដំណាក់កាលទី១ នៃ PPSEZ ត្រូវបានចាប់ផ្តើមក្នុងឆ្នាំ២០០៧ ដែលមានផ្ទៃដីប្រមាណ ១៣៧,៩៥ហិចតា ក្នុងនោះមានដីឡូត៍សម្រាប់រោងចក្រ និងពាណិជ្ជកម្មប្រមាណចិតសិបប្រាំបី(៧៨) ឡូត៍។

ក្នុងឆ្នាំ២០០៨ ក្រុមហ៊ុន Tiger Wing Co., Ltd. សហគ្រាសផលិតស្បែកជើងមួយមកពីប្រទេសជប៉ុនបានជួលរោងចក្រ និងឃ្លាំងសម្រាប់ដាក់ទំនិញមួយពីក្រុមហ៊ុន PPSEZ ដែលក្រុមហ៊ុននេះជារោងចក្រដំបូងដែលបានធ្វើប្រតិបត្តិការក្នុង PPSEZ។ លើសពីនេះ ក្នុងឆ្នាំដដែលក្រុមហ៊ុនទទួលបានក្រុមហ៊ុន Yamaha Moto (Cambodia) Co., Ltd. ជាវិនិយោគិនតំបន់សេដ្ឋកិច្ចពិសេស។ ក្រុមហ៊ុននេះបានបង្កើតរោងចក្រ តម្លើងម៉ូតូសម្រាប់ លក់ក្នុងទីផ្សារក្នុងស្រុក។

ក្នុងឆ្នាំ២០០៩ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារធំៗដែលរួមមានការឈូសឆាយដី ការសាងសង់ផ្លូវថ្នល់ និងប្រព័ន្ធបណ្តាញទឹក ការតម្លើងបរិក្ខារ និងបណ្តាញអ៊ិនធឺណេតសម្រាប់ដំណាក់កាលទី១ នៃតំបន់សេដ្ឋកិច្ចពិសេសត្រូវបានបញ្ចប់។ ក្នុងឆ្នាំដដែលក្រុមហ៊ុនបានទទួលវិនិយោគិនមួយចំនួនពីប្រទេសតៃវ៉ាន់ និងជប៉ុន រួមមានក្រុមហ៊ុន Ajinomoto (Cambodia) Co., Ltd.។ សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការទាក់ទាញ និងទទួលបានក្រុមហ៊ុនជប៉ុនធំៗ មួយចំនួនដើម្បីមកវិនិយោគក្នុង PPSEZ ពង្រឹងជំនឿចិត្តរបស់វិនិយោគិននាពេលអនាគតក្នុងការវិនិយោគក្នុង PPSEZ។ នេះជាភស្តុតាងនៃភាពជោគជ័យរបស់ក្រុមហ៊ុនក្នុងការជួលដីឡូត៍ទំនេរមួយចំនួនក្នុងដំណាក់កាលទី១ នៃ PPSEZ ទោះបីមានតម្រូវការតិចជាងមុនដោយសារវិបត្តិហិរញ្ញវត្ថុសកលលោក ក្នុងអំឡុងឆ្នាំ ២០០៩ និងឆ្នាំ២០១០ ដើម្បីស្របតាមគម្រោងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ក្នុងខែមេសា ឆ្នាំ២០០៩ ក្រុមហ៊ុនបានទិញភាគហ៊ុននៅសេសសល់ទាំងអស់ក្នុងក្រុមហ៊ុន JCDC។ យោងតាមការទិញភាគហ៊ុនក្នុងក្រុមហ៊ុន JCDC នីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនថ្មីត្រូវបានប្តូរទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលមានក្រុមហ៊ុន Zephyr ជាភាគហ៊ុនិកថ្មីរបស់ក្រុមហ៊ុនដែលកាន់កាប់ភាគហ៊ុន ម្ភៃពីរភាគរយ(២២%) នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន ស្របពេលដែលលោកជំទាវឧកញ៉ា **លឹម ឈីវហ្វេរ** កាន់កាប់ភាគហ៊ុនចំនួនចិតសិបប្រាំបីភាគរយ (៧៨%) របស់ក្រុមហ៊ុន។ ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនរក្សាចំនួនដើមគឺ ១ លានដុល្លារអាមេរិក។

លើសពីនេះតាមរយៈការទិញយកក្រុមហ៊ុន JCDC ក្រុមហ៊ុនក៏បានទិញភាគហ៊ុនចំនួនសែសិបភាគរយ (៤០%) នៃភាគហ៊ុនរបស់ក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេត ដែលក្រុមហ៊ុននេះបានក្លាយជាក្រុមហ៊ុនជាសម្ព័ន្ធនឹងគ្នារហូតមកដល់សព្វថ្ងៃ។ ក្នុងឆ្នាំដដែលក្រុមហ៊ុនបានទិញភាគហ៊ុន

ចំនួន ៥១០ ភាគហ៊ុន ក្នុងក្រុមហ៊ុន ខូលបេន ភីភីអេសអ៊ីហ្សេត ដែលស្មើនឹងហាសិបមួយភាគរយ (៥១%) នៃភាគហ៊ុន ជាមួយការដាក់ទុនជាទ្រព្យដែលមានតម្លៃប្រមាណ ២,៥៥ លានដុល្លារអាមេរិក។

ជាផ្នែកមួយនៃការកែទម្រង់ផ្ទៃក្នុង ក្នុងឆ្នាំ២០១០ PPSP បានទទួលយកទ្រព្យសកម្ម និងបំណុល ទាំងអស់ក៏ដូចជាប្រតិបត្តិការរបស់ក្រុមហ៊ុន JCDC ត្រូវបានរំលាយ។ ក្នុងអំឡុងពេលឆ្នាំសារពើពន្ធ ដែលបានលើឡើងនេះ ដែលផ្នែកមួយនៃការខិតខំជាបន្តបន្ទាប់របស់ ក្រុមហ៊ុនក្នុងការបង្កើននូវទំហំដី របស់ PPSEZ ក្រុមហ៊ុនបានទិញដីបន្ថែមប្រមាណ ៩,៨៦ ហិចតា ដែលមានទីតាំងជាប់ នឹងព្រំប្រទល់ PPSEZ ស្រាប់។ ឆ្នាំដដែលក្រុមហ៊ុនបានទទួលវិញ្ញាបនបត្រមាត្រដ្ឋានអន្តរជាតិ ISO ៩០០១ ដែលជា សក្ខីភាពនៃការប្តេជ្ញាចំពោះគុណភាព និងហេដ្ឋារចនាសម្ព័ន្ធទំនើបដែលត្រូវបានរៀបចំឡើងក្នុង PPSEZ នៅពេលកំពុងផ្តល់សេវាកម្មអតិថិជនកម្រិតខ្ពស់ដល់វិនិយោគិនតំបន់របស់ PPSEZ។ លើសពីនេះ ក្រុមហ៊ុនក៏ទទួលបានវិញ្ញាបនបត្រមាត្រដ្ឋានអន្តរជាតិ ISO ១៤០០១ សម្រាប់ការចូលរួមក្នុងការថែទាំ បរិស្ថានក្រុមហ៊ុន។

ក្នុងឆ្នាំ២០១១ ការងារសាងសង់សម្រាប់ដំណាក់កាលទី២ របស់តំបន់សេដ្ឋកិច្ចពិសេសត្រូវបាន ចាប់ផ្តើមដោយមានការពង្រីកបណ្តាញផ្លូវដែលមានស្រាប់ និងពង្រីកប្រព័ន្ធបង្ហូរទឹក។ ក្រុមហ៊ុនបាន អនុម័តនូវទស្សនៈផ្នែកលក់ខុសប្លែកពីមុនសម្រាប់ដំណាក់កាល២ របស់PPSEZ បើធៀបនឹងដំណាក់កាល១ ដែលក្នុងដំណាក់កាល១ របស់PPSEZ យូនីតសម្រាប់រោងចក្រ ហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាបណ្តាញផ្លូវ ត្រូវបានបង្កើតរួចរាល់មុននឹងលក់ទៅឱ្យវិនិយោគិនតំបន់។ សម្រាប់ដំណាក់កាល២ របស់PPSEZ ជាលទ្ធផលនៃហេដ្ឋារចនាសម្ព័ន្ធបន្ថែមដូចជាផ្លូវថ្នល់ និងប្រព័ន្ធបង្ហូរទឹក នៅពេលពួកគេទទួលបាន វិនិយោគិនថ្មី។ នេះធ្វើឱ្យការគ្រប់គ្រងលំហូរសាច់ប្រាក់មានភាពប្រសើរ និងអាចកាត់បន្ថយហានិភ័យ ដែលមានសក្តានុពល តាមរយៈការទទួលបានវិនិយោគទាប។

ក្នុងឆ្នាំ២០១២ ក្រុមហ៊ុនទទួលបានជោគជ័យក្នុងការចុះកិច្ចសន្យាទិញលក់ដីជាមួយក្រុមហ៊ុន ផលិតកម្មចម្រុះជាតិសាសន៍របស់ប្រទេសជប៉ុន ដូចជាក្រុមហ៊ុន Minebea (Cambodia) Co., Ltd. និងក្រុមហ៊ុន Sumi (Cambodia) Wiring Systems Co., Ltd.។

ក្នុងអំឡុងឆ្នាំ២០១៣ ក្រុមហ៊ុនទទួលបានជោគជ័យក្នុងការចុះកិច្ចសន្យាទិញលក់ដីជាមួយ ក្រុមហ៊ុន Laurelton Diamonds (Cambodia) Co., Ltd. (ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Tiffany & Co. ជាក្រុមហ៊ុនចម្រុះជាតិសាសន៍របស់សហរដ្ឋអាមេរិកដែលលក់គ្រឿងអលង្ការ និងឯកទេសភ័ណ្ឌ) និងក្រុមហ៊ុន YHS (Cambodia) Food & Beverage Pte Ltd. (ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Yeo Hiap Seng Limited ជាក្រុមហ៊ុនហូលឌីងវិនិយោគ ក៏ដូចជារោងចក្រផលិតភេសជ្ជៈរបស់

ប្រទេសសឹង្ហបូរី និងម៉ាឡេស៊ី)។ បន្ថែមពីនេះនៅខែកញ្ញា ឆ្នាំ២០១៣ ក្រុមហ៊ុនបានពង្រីកធុរកិច្ចរបស់ក្រុមហ៊ុនទៅដល់ប្រទេសឡាវ ដែលយើងបានវិនិយោគក្នុងក្រុមហ៊ុន SJD ជាទឹកប្រាក់ប្រមាណ ២៦០.០០០ ដុល្លារអាមេរិក ស្មើនឹងប្រមាណម្ភៃភាគរយ(២០%) នៃភាគហ៊ុនសរុបក្នុងគម្រោងនេះ។

ក្នុងឆ្នាំ២០១៤ ក្នុងការខិតខំប្រឹងប្រែងដើម្បីពង្រីកមុខមាត់ និងសេវាកម្មសាជីវកម្ម ក្រុមហ៊ុនបានផ្តើម និងឧបត្ថមភព្រឹត្តិការណ៍សាជីវកម្មដូចជា សិក្ខាសាលាស្តីពីការប្រឹក្សាផ្នែកពន្ធដារដល់វិនិយោគិនតំបន់ដែលមានវាគ្មិនដែលត្រូវបានអញ្ជើញពីអគ្គនាយកដ្ឋានពន្ធដាររបស់កម្ពុជា សិក្ខាសាលាស្តីពីសេវាកម្មអតិថិជនដែលវិនិយោគិនតំបន់ផ្តល់ជាមតិយោបល់លើស្ថានភាពតំបន់សេដ្ឋកិច្ចពិសេស និងសកម្មភាពទីផ្សារសាជីវកម្មគួរកត់សម្គាល់ដទៃទៀត។ ដើម្បីបំពេញបន្ថែមសេវាកម្មបច្ចុប្បន្ន និងផ្តល់សេវាកម្មសន្តិសុខក្នុង PPSEZ ក្រុមហ៊ុនបានទិញភាគហ៊ុនមួយរយភាគរយ(១០០%) ក្នុងក្រុមហ៊ុនសហ័ស ភីភីអេសអ៊ីហ្សិត ពីលោកជំទាវឧកញ៉ា លីម ឈីវហ្វរ ក្នុងតម្លៃមួយ(០១) ដុល្លារអាមេរិក។ ក្រុមហ៊ុនក៏ទទួលបានជោគជ័យក្នុងការចុះកិច្ចសន្យាទិញលក់ដីជាមួយវិនិយោគិនតំបន់ ដូចជាក្រុមហ៊ុន Hosiden Corporation(ក្រុមហ៊ុនចម្រុះជាតិសាសន៍មួយដែលអភិវឌ្ឍ និងផលិតគ្រឿងអេឡិចត្រូនិចគ្រឿបន្លាស់អេឡិចត្រូនិច និងគ្រឿងបន្លាស់យានយន្ត) ក្រុមហ៊ុន Kui Co., Ltd. (ក្រុមហ៊ុនចម្រុះជាតិសាសន៍មួយដែលច្នៃម៉ូត និងផលិតកាបូបដៃ និងផលិតផលម៉ូតដទៃទៀត)។

បន្ថែមពីនេះ ក្នុងឆ្នាំដដែលក្រុមហ៊ុនបានទិញដីទំនេរប្រមាណ ៥២,៩៥ ហិចតាក្នុងខេត្តបន្ទាយមានជ័យ ក្នុងតម្លៃប្រមាណ ៥,២៨លានដុល្លារអាមេរិក។ បច្ចុប្បន្ន គណៈគ្រប់គ្រងក្រុមហ៊ុនកំពុងស្ថិតក្នុងដំណាក់កាលសិក្សាភាពដែលអាចអភិវឌ្ឍបាន ដើម្បីក្លាយជាតំបន់សេដ្ឋកិច្ចពិសេសមួយ។ ដើម្បីជាយុទ្ធសាស្ត្រ អចលនទ្រព្យដែលបានលើកឡើងខាងលើនឹងត្រូវបញ្ចូលជាទ្រព្យសកម្មរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលកាន់កាប់ទាំងស្រុងឈ្មោះថា ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត។

នៅឆមាសទីមួយនៃឆ្នាំ២០១៥ ក្រុមហ៊ុនបានទទួលជោគជ័យក្នុងការចុះកិច្ចព្រមព្រៀងទិញលក់ដីជាមួយក្រុមហ៊ុន Cambodia Beverage Company Ltd.(ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនកូកាកូឡា ដែលជាក្រុមហ៊ុនភេសជ្ជៈចម្រុះជាតិសាសន៍ដ៏ល្បីល្បាញមួយ) ក្រុមហ៊ុន SVI Public Company Limited (ក្រុមហ៊ុនថៃដែលមានជំនាញខាងផលិតឧបករណ៍គ្រប់គរង (Control System) និងក្រុមហ៊ុន Taisun Vietnam Co., Ltd. (ក្រុមហ៊ុនវៀតណាមដែលមានជំនាញខាងផលិតផលអនាម័យ)។

## ៣.២. ទិដ្ឋភាពទូទៅរបស់ក្រុមហ៊ុន




PPSEZ មានទីតាំងយុទ្ធសាស្ត្រ ដែលតភ្ជាប់ទៅនឹងបណ្តាញផ្លូវដែក និងបណ្តាញផ្លូវថ្នល់។ PPSEZ មានទីតាំងស្ថិតនៅចម្ងាយប្រមាណជាដប់ប្រាំបី(១៨) គីឡូម៉ែត្រពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ ដែលងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តភ្នំពេញ (កំពង់ផែទន្លេអន្តរជាតិនៅរាជធានីភ្នំពេញ) និងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (អាកាសយានដ្ឋានអន្តរជាតិធំជាងគេនៅកម្ពុជា)។ ជាងនេះទៅទៀត PPSEZ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ដែលជាផ្លូវគមនាគមន៍ចម្បង និងងាយស្រួលក្នុងការធ្វើដំណើរទៅកាន់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលជាកំពង់ផែអន្តរជាតិ និងពាណិជ្ជកម្មសមុទ្រទឹកជ្រៅតែមួយគត់របស់កម្ពុជា។

បន្ថែមលើទីតាំងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន PPSEZ ជួយសម្រួល និងទាក់ទាញវិនិយោគិនរបស់ខ្លួន តាមរយៈលក្ខណៈពិសេសដូចខាងក្រោមៈ

(១).រោងចក្រផលិតថាមពលអគ្គិសនីឯកជន ធ្វើការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅពេលដែលមានកង្វះខាតថាមពលអគ្គិសនីពីរោងចក្រ ផ្គត់ផ្គង់អគ្គិសនីជាតិ ដែលដំណើរការដោយក្រុមហ៊ុន ខូលបេន

ភីភីអេសអ៊ីហ្សេត ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនជាសម្ព័ន្ធភាពទាំងអស់របស់ក្រុមហ៊ុន PPSEZ។

(២).ប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជន ដែលមានស្ថានីយ៍បន្សុតទឹក និងប្រព្រឹត្តិកម្មទឹកសំណល់។

(៣).ផែស្ងួតក្នុង PPSEZ ផ្តល់សេវាលើកដាក់ និងសេវាផ្ទុកទំនិញដែលអាចទុកចិត្តបាន និងឆាប់ រហ័សដើម្បីសម្រួលដល់ការនាំចេញនាំចូល និងដល់តម្រូវការដឹកជញ្ជូននានា ដែលដំណើរការ ដោយ ក្រុមហ៊ុន បុកសេង ភីភីអេសអ៊ីហ្សេត ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនជាសម្ព័ន្ធភាព ទាំងអស់របស់ក្រុមហ៊ុន PPSEZ។

(៤).បណ្តាញទូរគមនាគមន៍ខ្វាត់ខ្វែង និងធំទូលាយ ដែលអាចតភ្ជាប់ជាមួយអ្នកផ្តល់សេវាកម្ម អ៊ីនធឺណេតចំនួនដប់ពីរ(១២) ផ្សេងគ្នា និងអ្នកផ្តល់សេវាកម្មទូរស័ព្ទខុសគ្នាចំនួនបួន(៤)។

(៥).ប្រព័ន្ធទប់ស្កាត់ទឹកជំនន់បំពាក់ដោយប្រព័ន្ធបង្ហូរទឹកទំនើប ដែលធានាដល់ប្រតិបត្តិការ របស់ វិនិយោគិនតំបន់ឱ្យមានភាពរលូន និងមានសុវត្ថិភាពខ្ពស់។

(៦).សេវាសន្តិសុខផ្តល់ដោយក្រុមហ៊ុន សហ័ស ភីភីអេសអ៊ីហ្សេត ជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែល កាន់កាប់ទាំងស្រុងដោយ PPSP ដើម្បីត្រួតពិនិត្យ និងរក្សាសុវត្ថិភាពក្នុងតំបន់។ និង

(៧).សេវាច្រកចេញចូលតែមួយ ដែលមាននៅក្នុងតំបន់ស្រាប់ ដែលសហការជាមួយភ្នាក់ងារ រដ្ឋាភិបាល ពាក់ព័ន្ធនានា ដូចជាភ្នាក់ងាររបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស នាយកដ្ឋានគយ និង រដ្ឋករកម្ពុជា កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសម្រួលដក់ការបង់ពន្ធគយ ការចុះបញ្ជីពាណិជ្ជកម្ម និងការគោរពតាមច្បាប់ដល់វិនិយោគិន តំបន់របស់ខ្លួន។

ជាមួយនឹងហេដ្ឋរចនាសម្ព័ន្ធដ៏ទំនើប PPSEZ បានទាក់ទាញវិនិយោគិនជាច្រើនឱ្យមកបង្កើត ប្រតិបត្តិការរបស់ពួកគេក្នុងតំបន់។

ជាមួយនឹងក្រឡាផ្ទៃសរុបប្រមាណជា ៣៥៧,៣២ ហិចតា PPSEZ ត្រូវបានអភិវឌ្ឍជាបី(៣) ដំណាក់កាល៖

(១). ដំណាក់កាលទី១ មានផ្ទៃដីទំហំប្រមាណ ១៣៧,៩៤ ហិចតា បានបញ្ចប់សំណង់ហេដ្ឋារចនា សម្ព័ន្ធធំៗ របស់ខ្លួនក្នុងឆ្នាំ២០០៩។ ដំណាក់កាល១ ភាគច្រើនត្រូវបានអភិវឌ្ឍជាឡូត៍សម្រាប់រោងចក្រ ឡូត៍សម្រាប់ពាណិជ្ជកម្ម ក៏ដូចជាទីតាំង និងបរិក្ខារនានាសម្រាប់ផែស្ងួតតំបន់។

(២). ដំណាក់កាល២ មានផ្ទៃដីទំហំប្រមាណ ១៦១,៥៩ ហិចតា ដែលត្រូវបានអភិវឌ្ឍជាពីរដំណាក់កាល គឺដំណាក់កាល ២-១ និងដំណាក់កាល២-២។ ដំណាក់កាល២-១ មានក្រឡាផ្ទៃប្រមាណ ៨៧,៨៥

ហិចតាបានបញ្ចប់ការសាងសងហេដ្ឋរចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗក្នុងឆ្នាំ២០១៤ ចំណែកឯដំណាក់កាល២-២វិញ មានក្រឡាផ្ទៃប្រមាណ ៧៣,៧៤ ហិចតា បាននឹកកំពុងអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗរបស់ខ្លួន ដែលនឹងត្រូវបញ្ចប់នៅដើមឆ្នាំ២០១៦។ និង

(៣). ដំណាក់កាល៣ មានផ្ទៃប្រមាណ ៥៧,៧៩ ហិចតា កំពុងស្ថិតក្នុងដំណាក់កាលរៀបចំគម្រោងអភិវឌ្ឍន៍ និងមិនទាន់បានអភិវឌ្ឍនៅឡើយទេ។ យោងតាមគម្រោងអភិវឌ្ឍន៍បឋមដំណាក់កាលនេះគឺផ្តោតសំខាន់លើដីឡូត៍សម្រាប់រោងចក្រ ដែលក្រុមហ៊ុនបានរំពឹងទុកថានឹងចាប់ផ្តើមសាងសង់ហេដ្ឋា-រចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗនៅដំណាច់ឆ្នាំ២០១៦។

## ៣.៣. យុទ្ធសាស្រ្តធុរកិច្ច និងផែនការអនាគតរបស់ក្រុមហ៊ុន

### ៣.៣.១. សេចក្តីថ្លែងការណ៍ស្តីពីទស្សនៈវិស័យ និងបេសកកម្ម

ទស្សនៈវិស័យរបស់ក្រុមហ៊ុន៖

ទស្សនៈវិស័យរបស់ក្រុមហ៊ុនគឺធ្វើជាអ្នកអភិវឌ្ឍ និងប្រតិបត្តិករតំបន់សេដ្ឋកិច្ចពិសេសដែលឈានមុខគេនៅព្រះរាជាណាចក្រកម្ពុជា និងបង្កើតគុណភាពតម្លៃសម្រាប់ភាគហ៊ុនិករបស់ក្រុមហ៊ុនបុគ្គពាក់ព័ន្ធ និងសហគមន៍របស់ក្រុមហ៊ុន។

បេសកកម្មរបស់ក្រុមហ៊ុន៖

បេសកកម្មរបស់ក្រុមហ៊ុនគឺក្លាយជាតំបន់សេដ្ឋកិច្ចពិសេសឈានមុខ គេនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនមានបំណងផ្តល់ឱ្យក្រុមហ៊ុនផលិតកម្ម នូវអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុដើម្បីធានាដល់ការវិនិយោគរយៈពេលវែងស្របពេលដែលក្រុមហ៊ុនមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុកដោយសារមានហេដ្ឋារចនាសម្ព័ន្ធដែលទទួលស្គាល់ដោយបទដ្ឋានអន្តរជាតិISO សេវាកម្មរដ្ឋបាលក្នុងតំបន់ និងទីតាំងល្អសម្រាប់ទូរគមនាគមន៍ក្នុងតំបន់។

### ៣.៣.២. ផែនការអនាគត

ផែនការអនាគតមានដូចខាងក្រោម៖

១.បន្តទិញដីនៅជុំវិញ PPSEZ

២.ធ្វើឱ្យមានវិនិយោគិនច្រើនប្រភេទក្នុងតំបន់

៣.ការបង្កើតទីផ្សារដែលមានសក្តានុពលនៅកម្ពុជា និងពង្រីកទៅប្រទេសដ៏ទៃទៀតក្នុងតំបន់ទន្លេមេគង្គ និង

៤. ពង្រីកការផ្តល់សេវាកម្មពាក់ព័ន្ធផ្សេងៗ។

### ៣.៣.៣. យុទ្ធសាស្ត្រធុរកិច្ច

ធាតុផ្សំសំខាន់នៃយុទ្ធសាស្ត្រធុរកិច្ចរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

១. ការបង្កើតឱ្យមានវត្តមាននៃទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាង

២. ទាក់ទាញអតិថិជន និងបង្កើនការពេញចិត្តរបស់អតិថិជន

៣. ការបង្កើននូវប្រាក់ចំណូលដុល

៤. បន្តអភិវឌ្ឍដីទំនេរនៅ PPSEZ ដែលក្រុមហ៊ុនជឿជាក់ថានឹងក្លាយជាប្រភពដ៏សំខាន់ក្នុងការរកប្រាក់ចំណូល និងជាកត្តាជំរុញនៃការរីកចំរើននាពេលអនាគត

៥. ការផ្តល់ពហុសេវាកម្មគាំទ្រដល់វិនិយោគិនតំបន់របស់ក្រុមហ៊ុន

៦.ទាក់ទាញ និងរក្សាឱ្យបាននូវបុគ្គលិកជាន់ខ្ពស់ និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់សំខាន់ៗដែលមានបទពិសោធន៍ខ្ពស់ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍ និងភាពជោគជ័យរបស់សម្ព័ន្ធក្រុមហ៊ុន និង

៧. ការពង្រីកធុរកិច្ចរបស់ក្រុមហ៊ុនដោយចាប់យកវិនិយោគិនតំបន់ថ្មី។

## ៣.៤. រចនាសម្ព័ន្ធនៃគណៈគ្រប់គ្រង

រចនាសម្ព័ន្ធខាងក្រោម បង្ហាញពីគណៈគ្រប់គ្រងរបស់ក្រុមហ៊ុននាកាលបរិច្ឆេទនៃ ឯកសារផ្តល់ព័ត៌មាន៖


ក្រុមប្រឹក្សាភិបាល
លោកជំទាវឧកញ៉ា លឹម ឈីវហ្វេរ
ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិលោក
Hiroshi Uematsu អភិបាលប្រតិបត្តិ
លោក តាន់ កាក់ឃុន អភិបាលមិនប្រតិបត្តិ
លោកស្រី តាន់ សឺយមួយ អភិបាលមិនប្រតិបត្តិ
លោក Hiroshi Otsubo អភិបាលមិនប្រតិបត្តិ
លោក Kenji Toyota អភិបាលមិនប្រតិបត្តិ
លោក Kang Wei Geilh អភិបាលឯករាជ្យ
លោក ហែម សុវត្ថិ អភិបាលឯករាជ្យ
លេខាធិការក្រុមហ៊ុន និង
ការិយាល័យផ្តល់ព័ត៌មាន
ប្រធាន
លោកស្រី ភូ មួយបួយ
គណៈកម្មាធិកាសវនកម្ម
លោក Kang Wei Geih ប្រធាន
លោកស្រី តាន់សឺយមួយ សមាជិក
លោក ហែម សុវត្ថិ សមាជិក
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
លោក ហែម សុវត្ថិ ប្រធាន
លោក Hiroshi Uematsu សមាជិក
លោក តាន់ កាក់ឃុន សមាជិក
ការិយាល័យសវនកម្មផ្ទៃក្នុង
ប្រធាន
លោក លាងតារា
នាយកប្រតិបត្តិ
លោក Hiroshi Uematsu
នាយកហិរញ្ញវត្ថុ
លោក Fong Nee Wai
ការិយាល័យគណនេយ្យ
និង ហិរញ្ញវត្ថុ
អ្នកគ្រប់គ្រងថ្នាក់ខ្ពស់
លោកស្រី ហ៊ុន ចាន់ប៉ី
ការិយាល័យផ្នែកលក់ និង
ទីផ្សារ/សេវាអតិថិជន
អ្នកគ្រប់គ្រងជាន់ខ្ពស់
លោកស្រិ Zhao Minqian
ការិយាល័យធនធានម
នុស្ស និងរដ្ឋបាល
អ្នកគ្រប់គ្រងជាន់ខ្ពស់
លោក ស៊ុន សាមឿន
ការិយាល័យវិស្វកម្ម
ប្រធានវិស្វកម្ម
លោក Kenici
Yoshida

## ៣.៥. ភាគហ៊ុនិក អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ៣.៥.១.ភាគហ៊ុនិក

តារាងខាងក្រោមបង្ហាញនូវការប៉ាន់ស្មាន (Pro forma) នៃការកាន់កាប់ភាគហ៊ុនរបស់ភាគហ៊ុនិកទាំងអស់របស់ក្រុមហ៊ុនមុន និងក្រោយពេល IPO

| ភាគហ៊ុនិក | មុនពេល IPO | | ក្រោយពេល IPO | |
|---|---|---|---|---|
| | ចំនួនភាគហ៊ុន | ភាគរយ | ចំនួនភាគហ៊ុន | ភាគរយ |
| លោកជំទាវឧកញ៉ា លីម ឈីវហ្វរ | ៣២.៤១០.០០ | ៧០,០០ | ៣២.៤១០.០០ | ៥៦,០០ |
| ក្រុមហ៊ុន Zephyr | ១០.១៨៦.០០០ | ២២,០០ | ១០.១៨៦.០០០ | ១៧,៦០ |
| លោកស្រី លីម ស្រីពៅ | ១.៨៥២.០០០ | ៤.០០ | ១.៨៥២.០០០ | ៣,២០ |
| លោកស្រី អាន ម៉ិយតាន់ | ១.៨៥២.០០០ | ៤.០០ | ១.៨៥២.០០០ | ៣,២០ |
| គម្រោង ESOP | | | ១.១៥៧.៥០០ | ២,០០ |
| វិនិយោគិនសាធារណជន | | | ១០,៤១៧,៥០០ | ១៨,០០ |
| សរុប | ៤៦.៣០០.០០០ | ១០០.០០ | ៥៧.៨៧៥.០០០ | ១០០,០០ |

### ៣.៥.២.អភិបាល

តារាងខាងក្រោមរាយនាមរបស់អភិបាលរបស់ក្រុមហ៊ុន គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយៈ

| លេខ | ឈ្មោះអភិបាល | តួនាទីក្នុងក្រុមប្រឹក្សាភិបាល |
|---|---|---|
| ១ | លោកជំទាវឧកញ៉ា លីម ឈីវហ្វរ | ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ |
| ២ | លោក Hiroshi Uematsu | អភិបាលប្រតិបត្តិ |
| ៣ | លោក តាន់ កាក់យុន | អភិបាលមិនប្រតិបត្តិ |
| ៤ | លោកស្រី តាន់ ស៊ីយមួយ | អភិបាលមិនប្រតិបត្តិ |
| ៥ | លោក Hiroshi Otsubo | អភិបាលមិនប្រតិបត្តិ |
| ៦ | លោក Kenji Toyata | អភិបាលមិនប្រតិបត្តិ |
| ៧ | លោក ហែម សុវត្ថិ | អភិបាលឯករាជ្យ |
| ៨ | លោក Kang Wei Geih | អភិបាលឯករាជ្យ |

### ៣.៥.៣.បុគ្គលិកជាន់ខ្ពស់

តារាងខាងក្រោមរាយនាមរបស់បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ៖

| លេខ | ឈ្មោះ | តួនាទីក្នុងក្រុមហ៊ុន |
|---|---|---|
| ១ | លោក Hiroshi Uematsu | នាយកប្រតិបត្តិ |
| ២ | លោក Fong Nee Wai | នាយកផ្នែកហិរញ្ញវត្ថុ |
| ៣ | លោក លាង តារា | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង |
| ៤ | លោក Kenichi Yoshida | ប្រធានវិស្វករ/ប្រធានផ្នែកវិស្វកម្ម |
| ៥ | លោកស្រី Zhao Minqian | អ្នកគ្រប់គ្រងជាន់ខ្ពស់/ប្រធានផ្នែកលក់ និងទីផ្សារ និងសេវាអតិថិជន |
| ៦ | លោក ស៊ុន សាមឿន | អ្នកគ្រប់គ្រងជាន់ខ្ពស់/ប្រធានផ្នែកធនធានមនុស្ស |
| ៧ | លោកស្រី ភូ មួយបួយ | លេខាធិកាក្រុមហ៊ុន/ប្រធានផ្នែកផ្តល់ព័ត៌មាន |
| ៨ | លោកស្រី ហ៊ុន ចាន់ប៊ី | អ្នកគ្រប់គ្រងជាន់ខ្ពស់/ប្រធានផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ |

## ៣.៦ ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ៣.៦.១. រចនាសម្ព័ន្ធច្បាប់

មូលបត្រកម្មសិទ្ធិបោះផ្សាយលក់ត្រូវបានដាក់លក់ដោយផ្អែកលើព័ត៌មាន និងអនុលោមតាមលក្ខខណ្ឌខសន្យា ដែលមានកំណត់ក្នុងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំតែប៉ុណ្ណោះ។ គ្មានបុគ្គលណាត្រូវបានអនុញ្ញាតឱ្យផ្តល់ព័ត៌មានដែលទាក់ទងនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធា-រណៈ ឬការធានាអះអាងផ្សេងទៀត ដែលបពុំមានកំណត់ក្នុងឯកសារផ្តល់ព័ត៌មាននេះ។ ព័ត៌មានឬការធានាអះអាងដែលពុំមាននៅក្នុងឯកសារនេះ មិនត្រូវបានយកមកធ្វើជាសំអាងដូចព័ត៌មានដែលត្រូវបានអនុញ្ញាតដោយក្រុមហ៊ុន ភាគហ៊ុនិក សហាក្រុមហ៊ុនធានាទិញមូលបត្រចម្បង សហាក្រុមហ៊ុនធានាទិញមូលបត្រ អភិបាល បុគ្គលិក ឬទីប្រឹក្សាណាមួយ ឬភាគីណាមួយដែលបានចូលរួមក្នុងការបោះផ្សាយលក់ មូលបត្រជាសាធារណៈនេះ។

ក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ក្រោមច្បាប់នៃព្រះរាជាណាចក្រ-កម្ពុជាដោយមានលេខចុះបញ្ជីពាណិជ្ជកម្ម Inv. ១០៧៦KH/២០០៦ ក្រោមទម្រង់ជាសហាគ្រាស

ឯកបុគ្គលទទួលខុសត្រូវមានកម្រិត។ ក្រោយមកនាថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ក្រុមហ៊ុនបានបំលែងខ្លួនទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ក្រោមឈ្មោះថា ភ្នំពេញ អេសអ៊ីហ្សេតភីអិលស៊ី។

ដើម្បីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពី ភាគហ៊ុនិក និងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្នុងការធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង និងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.។

ចំនួនមូលបត្រចុះបញ្ជីដែលបានបោះចេញ និងបានបង់រួចគ្រប់ចំនួន មុនពេលធ្វើការបោះផ្សាយលក់មានចំនួន ៤៦.៣០០.០០ ភាគហ៊ុន។ បន្ទាប់ពីការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ចំនួនភាគហ៊ុនត្រូវបានតម្លើងដល់ ៥៧.៨៧៥.០០០ភាគហ៊ុន។ មូលបត្រកម្មសិទ្ធិបោះផ្សាយលក់មានចំនួន ១១.៥៧៥.០០០ ភាគហ៊ុនថ្មី(២០,០០% នៃភាគហ៊ុនដែលតម្លើងរួច បន្ទាប់ពីការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) នឹងត្រូវបានកាន់កាប់ដោយវិនិយោគិនសាធារណៈ ចំណែកភាគហ៊ុន ៤៦.៣០០.០០០ ភាគហ៊ុនទៀត(៨០,០០% នៃភាគហ៊ុនដែលត្រូវបានតម្លើងរួចបន្ទាប់ពីការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) នឹងត្រូវបានកាន់កាប់ដោយអ្នកផ្តួចផ្តើម។

### ៣.៦.២. ព័ត៌មានទូទៅអំពីមូលបត្រកម្មសិទ្ធិបោះផ្សាយលក់

ក្រុមហ៊ុនបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិចំនួន ១១.៥៧៥.០០០ ភាគហ៊ុនថ្មីដែលត្រូវបានបោះផ្សាយសម្រាប់ការធ្វើបរិសកម្មជូនសាធារណជននៅព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ព្រះរាជាណាចក្រកម្ពុជាស្តីពីមូលបត្រ។ តារាងខាងក្រោមបង្ហាញអំពីសេចក្តីសង្ខេបនៃលក្ខខណ្ឌនៃ IPO របស់ក្រុមហ៊ុន៖

ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់៖ ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត

| | |
|---|---|
| ប្រភេទនៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ | ៖ ភាគហ៊ុនថ្មីដែលត្រូវបានបោះផ្សាយ |
| ចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ | ៖ ១១.៥៧៥.០០០ ភាគហ៊ុន |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៖ ២.០០០រៀល |
| តម្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ | ៖ ២.៨៦០រៀល ក្នុងមួយភាគហ៊ុនថ្មី |
| ចំនួនទឹកប្រាក់សរុបនៃការបោះផ្សាយលក់ | ៖ ៣៣.១០៤.៥០០.០០០រៀល<br>( ប្រមាណ៨.២៥២..៩៧៥ ដុល្លារអាមេរិក) |

គោលបំណងនៃការបោះផ្សាយលក់៖ គោលបំណងចម្បងរបស់ក្រុមហ៊ុនក្នុងការចុះបញ្ជីគឺ

១. ដើម្បីបង្កើននូវកេរ្តិ៍ឈ្មោះ ភាពលេចធ្លោ និងភាពអាចទុកចិត្តបានរបស់សម្ព័ន្ធក្រុមហ៊ុន PPSEZ ដេលជាសញ្ញាល្អសម្រាប់ PPSEZ និងតំបន់សេដ្ឋកិច្ចពិសេសផ្សេងៗដែលសម្ព័ន្ធក្រុមហ៊ុន PPSEZ នឹងអភិវឌ្ឍ និងគ្រប់គ្រង។

២. ដើម្បីប្រមូលដើមទុនសម្រាបពង្រឹងនូវប្រតិបត្តិការធុរកិច្ចរបស់សម្ព័ន្ធក្រុមហ៊ុន PPSEZ ដែលរួម បញ្ចូលទាំងការអភិវឌ្ឍរបស់ PPSEZ និងការទិញដីបន្ថែម។

៣.ដើម្បីអនុញ្ញាតឱ្យសាធារណៈជនក្លាយជាផ្នែកមួយនៃការអភិវឌ្ឍនាពេលអនាគតរបស់សម្ព័ន្ធ ក្រុមហ៊ុន PPSEZ។

រូបិយបណ្ណសម្រាប់ការជួញដូរៈ ភាគហ៊ុនរបស់ក្រុមហ៊ុននឹងត្រូវបានកំណាត់តម្លៃលក់ និងជួញដូរជារៀល លើបញ្ជីផ្លូវការរបស់ ផ.ម.ក.។ ការទូទាត់ប្រាក់អាចត្រូវបានធ្វើឡើងជារៀល ឬដុល្លារអាមេរិក. ប្រាក់បង្វិលទៅវិញត្រូវធ្វើឡើងជារូបិយបណ្ណដូចគ្នា ដែលបានបង់ដោយវិនិយោគិនសាធារណៈ។

ការធ្វើបរិវិសកម្មអប្បបរមាៈ ១.០០០ភាគហ៊ុន សម្រាប់ដំណាក់កាលប៊ុកបៀលខឹង។

១០០ ភាគហ៊ុន សម្រាប់ដំណាក់កាលធ្វើបរិវិសកម្ម។

កាលបរិច្ឆេទសម្រាប់ធ្វើបរិវិសកម្មៈ រយៈពេលធ្វើបរិវិសកម្មនឹងចាប់ផ្តើមពីម៉ោង ៨ព្រឹក នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ និងបញ្ចប់នៅម៉ោង ៥ល្ងាច ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦។ លុះត្រាតែត្រូវបានកំណត់រយៈពេលខ្លីជាង ឬវែងជាងរយៈពេលដែលបានកំណត់ខាងលើស្របតាមកិច្ចព្រមព្រៀងរបស់ក្រុមហ៊ុន សហាក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហាក្រុមហ៊ុនធានាទិញមូលបត្រ ដែលនឹងត្រូវសុំការអនុញ្ញាតពី គ.ម.ក.។

កាលបរិច្ឆេទសម្រាប់បែងចែកមូលបត្រជូនវិនិយោគិនៈ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦

កាលបរិច្ឆេទសម្រាប់ការបង្វិលប្រាក់វិញៈ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ (ប្រសិនបើមានចំនួន លើ)

ភ្នាក់ងារបញ្ជិកាមូលបត្រ/ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ/ភ្នាក់ងារទូទាត់ៈ ត្រាយខ័រ ស៊ីឃ្យូរីធីភីអិលស៊ី

លើសពីនេះ អនុលោមតាមប្រការ ៣៧ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈភាគហ៊ុនបោះផ្សាយលក់យ៉ាងតិចម្ភៃភាគរយ(២០%)(ស្មើនឹង ២.៣១៥.០០០ ភាគហ៊ុនថ្មីតាមរយៈ IPO របស់ក្រុមហ៊ុន) ចាំបាច់ត្រូវចែកទៅឱ្យវិនិយោគិនសញ្ជាតិខ្មែរ លើកលែងតែមានការណែនាំ និងអនុញ្ញាតផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។ ជនជាតិខ្មែរសំដៅលើរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលដែលមានដើមទុនសរុបមិនតិចជាងហាសិបមួយភាគរយ (៥១%) នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុបកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។

## ៣.៧. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ក្រុមហ៊ុនរំពឹងថានឹងទទួលបានសាច់ប្រាក់សរុបពី IPO ចំនួន ៣៣.១០៩.៥០០.០០០ រៀល (ប្រមាណ៨.២៥២.៩៧៥ ដុល្លារអាមេរិក) ដោយផ្អែកលើតម្លៃបោះផ្សាយលក់ ២.៨៦០ រៀល(ប្រមាណ ០,៧១៣ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន។ ក្រុមហ៊ុនមានបំណងប្រើប្រាស់ប្រាក់ដែលទទួលបានពី IPO នេះជាចម្បងដើម្បីផ្គត់ផ្គង់ដល់ការរីកចម្រើនលូតលាស់នាពេលអនាគតរបស់ខ្លួនដូចជា ការទិញដី និងការអភិវឌ្ឍដី ការកាត់បន្ថយកម្ចី និងតម្រូវការដើមទុនប្រតិបត្តិការរយៈពេលខ្លី។

## ៣.៨. គោលនយោបាយបែងចែកភាគលាភ

ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៥ សម្រាប់ឆ្នាំសារពើពន្ធ ២០១៥ និងបន្តបន្ទាប់ វាជាគោលនយោបាយរបស់ ក្រុមប្រឹក្សាភិបាល ក្នុងការប្រកាសភាគលាភ ដើម្បីអនុញ្ញាតឱ្យភាគហ៊ុនិកទទួលបានប្រាក់ចំណេញរបស់ក្រុមហ៊ុនក៏ដូចជាបម្រុងទុកឱ្យបានគ្រប់គ្រាន់សម្រាប់ការលូតលាស់នាពេលអនាគតរបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានអនុម័តគោលនយោបាយបម្រុងទុកប្រាក់ចំណេញ (Plough back policy) ដើម្បីធានាអំពីការរីកចម្រើនរបស់ក្រុមហ៊ុន ដូច្នេះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបង់ភាគលាភ ឬធ្វើការបែងចែកក្រោមទម្រង់ផ្សេងទៀតដល់ភាគហ៊ុនិក អាស្រ័យលើកត្តាមួយចំនួនដែលរួមមានជាអាទិ៍ដូចជា៖

១. ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុនដែលរួមមានលំហូរសាច់ប្រាក់ និងស្ថានភាព សន្ទនីយភាព អត្រានៃភាពខុសគ្នារវាងដើមទុន និងឥណទាន (Gearing) និងអតិរេក (Surplus) របស់សម្ព័ន្ធ ក្រុមហ៊ុន

២. ប្រតិបត្តិការហិរញ្ញវត្ថុដែលសម្ព័ន្ធក្រុមហ៊ុនរំពឹងទុករួមមានលទ្ធភាពចំណេញ

៣. ទុនបង្វិលដែលក្រុមហ៊ុនមាន រួមមានមូលធនបែងចែកសម្រាប់ចំណាយមូលធន និងគម្រោងវិនិយោគពេលអនាគត និង

៤. កាតព្វកិច្ចបំណុលដែលមានស្រាប់ និងពេលអនាគតរបស់សម្ព័ន្ធក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានស្នើបង់ភាគលាភ ដែលបានមកពីសាច់ប្រាក់ទទួលបានពីប្រតិបត្តិការរបស់សម្ព័ន្ធក្រុមហ៊ុន បន្ទាប់ពីការផាត់ទាត់ចំណាយមូលធនដែលចាំបាច់ទុកបង្វិល ចាំបាច់ និងចំណុចផ្សេងទៀតដូចមានកំណត់ក្នុងចំណុច(១) ដល់ (៤) ខាងលើ។ ផ្អែកលើគោលនយោបាយភាគលាភនេះ ក្រុមហ៊ុនបានកំណត់គោលដៅនៃអនុបាតនៃការបង់ភាគលាភមិនឱ្យតិចជាងម្ភៃភាគរយ (២០%) នៃប្រាប់ចំណេញរបស់ក្រុមហ៊ុនដល់អ្នកកាន់កាប់មូលបត្ររបស់ក្រុមហ៊ុនបានអនុលោម CIFRS.

វិនិយោគិនគួរកត់សម្គាល់ថា គោលនយោបាយបែងចែកភាគលាភគ្រាន់តែបង្ហាញអំពីគោលបំណង បច្ចុប្បន្នរបស់ក្រុមហ៊ុនប៉ណ្ណោះហើយវាមិនត្រូវបានចាត់ទុកថាជាសេចក្តីថ្លែង ចងកាតព្វកិច្ចតាមផ្លូវច្បាប់ណាមួយឡើយពាក់ព័ន្ធនឹងការបែងចែកភាគប៉ុនរបស់ក្រុមហ៊ុននាពេលអនាគតឡើយ។ គោលនយោបាយនេះអាចត្រូវបានកែប្រែ (ដែលរួមមានការមិនប្រកាសផ្សេងទៀតដែលពាក់ព័ន្ធ) ដោយឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាភិបាល។ វិនិយោគិនមិនត្រូវចាត់ទុកសេចក្តីថ្លែងណាមួយខាងលើថាជាលទ្ធភាពចំណេញនាពេលអនាគត ឬសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបែងចែកភាគលាភនាពេលអនាគតឡើយ។

# ជំពូកទី ៤៖

# លក្ខខណ្ឌតម្រូវអភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយ មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនPPSEZ

## ៤.១.ព័ត៌មានទាក់ទង និងអភិបាលកិច្ចសាជីវកម្ម

### ៤.១.១.អភិបាល

| លេខ | ឈ្មោះអភិបាល | អាសយដ្ឋាន | តួនាទីក្នុងក្រុមប្រឹក្សាភិបាល | កាលបរិច្ឆេទក្លាយជាអភិបាល |
|---|---|---|---|---|
| ១ | លោកជំទាវឧកញ៉ា លីម ឈីវហួរ | ផ្ទះលេខ៥៣ ផ្លូវលេខ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ | ប្រធានក្រុមប្រឹក្សាភិបាលមិនប្រតិបត្តិ | ១០.ឧសភា.២០០៦ |
| ២ | លោក Hiroshi Uematsu | ផ្ទះលេខ១៧ ផ្លូវលេខ៣២២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ | អភិបាលប្រតិបត្តិ | ០៩.កុម្ភៈ.២០១០ |
| ៣ | លោក តាន់ កាក់យុន | ផ្ទះលេខ៥៣ ផ្លូវលេខ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ | អភិបាលមិនប្រតិបត្តិ | ០៩.កុម្ភៈ.២០១០ |
| ៤ | លោកស្រី តាន់ សឺយមួយ | ផ្ទះលេខ៥៣ ផ្លូវលេខ៣៨៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ | អភិបាលមិនប្រតិបត្តិ | ០១.មករា.២០១៣ |
| ៥ | លោក Hiroshi Otsubo | Yotsuya Twin Tower East,1401,5 Yotsuya 3-chome. Shinjuku-ku ទីក្រុងតូក្យូ ប្រទេសជប៉ុន | អភិបាលមិនប្រតិបត្តិ | ៣០.សីហា២០១៤. |

| | | | | |
|---|---|---|---|---|
| ៦ | លោក Kenji Toyata | 201 Brillia Wellith Tsukisima, 1-15-10 Tsukisima, Chuo-ku, ទីក្រុងតូក្យូ ប្រទេសជប៉ុន | អភិបាលមិនប្រតិបត្តិ | ៣០.សីហា២០១៤. |
| ៧ | លោក ហែម សុវត្ថិ | ផ្ទះលេខ១៨ ផ្លូវលេខ៣១៦២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | អភិបាលឯករាជ្យ | ៣០.សីហា២០១៤. |
| ៨ | លោក Kang Wei Geih | បន្ទប់លេខ១ សណ្ឋាគារកាំបូឌីយ៉ាណា ផ្លូវលេខ៣១៣ វិថីស៊ីសុវត្ថិ រាជធានីភ្នំពេញ | អភិបាលឯករាជ្យ | ០១.មេសា.២០១៥ |

## ៤.១.២.អភិបាលកិច្ចសាជីវកម្ម

### ៤.១.២.១.ការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល

ក.អាណត្តិ ការជ្រើសរើសតាំង និងការបញ្ឈប់តំណែងជាអភិបាល

លុះត្រាមានការចែងក្នុងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗពីនេះ ក្រុមប្រឹក្សាភិបាលត្រូវមានសមាសភាពមិនតិចជាងប្រាំ (០៥) រូប និងមិនត្រូវលើសពីដប់ប្រាំ (១៥) រូបនោះទេ។ អភិបាលមិនតម្រូវឲ្យជាភាគហ៊ុនិកនោះទេ។ យ៉ាងណាមួយភាគប្រាំ (១/៥) នៃអភិបាលទាំងអស់ ឬចំនួនដ៏ទៃផ្សេងទៀតដែលបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិត្រូវតែជាអភិបាលឯករាជ្យ។

អភិបាលត្រូវជ្រើសរើស ឬដកចេញពីតំណែង ដោយសេចក្តីសម្រេចធម្មតារបស់ភាគហ៊ុនិក។ ប្រសិនបើគ្មានការចែងផ្សេងពីនេះក្នុងសេចក្តីសម្រេចនោះទេ អភិបាលម្នាក់ៗត្រូវបានជ្រើសរើសតាំងសម្រាប់រយៈពេលពីរ (០២)ឆ្នាំ និងអាចត្រូវបានជ្រើសរើសសាជាថ្មី។ ប្រសិនបើមានតំណែងអភិបាលទំនេរមុនពេលផុតអាណត្តិ ភាគហ៊ុនិកត្រូវជ្រើសតាំងអភិបាលបន្ថែម ដើម្បីបំពេញតំណែងដែលនៅទំនេរនោះសម្រាប់រយៈពេលដែលនៅសល់របស់អភិបាលដែលបានដកចេញ។

ខ.សន្និបាតរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំយ៉ាងតិចជារៀងរាល់បី (០៣) ខែម្តង។ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងតាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬសម្លេងមួយភាគបី (១/៣) នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងមូល។ អភិបាលមួយរូបអាចត្រូវចាត់តាំងដោយអភិបាលមួយរូបផ្សេងទៀតតាមរយៈលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរ ឲ្យធ្វើជាតំណាងរបស់ខ្លួនក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល។ អភិបាលនីមួយៗដែលចូលរួមក្នុងកិច្ចប្រជុំត្រូវមានសិទ្ធិបោះឆ្នោតមួយ (០១) សម្លេង។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលមានសពលភាពចាប់បង្ខំនៅពេលដែលសេចក្តីសម្រេចនោះ ត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃអភិបាលដែលមានវត្តមានក្នុងកិច្ចប្រជុំ។ ក្រុមនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាភិបាល គឺសម្លេងភាគច្រើននៃអភិបាលទាំងអស់ដោយក្នុងនោះត្រូវមានអភិបាលឯករាជ្យយ៉ាតិមួយ (០១) រូប។

ក្រុមប្រឹក្សាភិបាលអាចអនុម័តលើសេចក្តីសម្រេចដោយមិនចាំបាច់រៀបចំកិច្ចប្រជុំបានលុះត្រាតែសេចក្តីសម្រេចនោះត្រូវបានចុះហត្ថលេខាដោយអភិបាលទាំងអស់របស់ក្រុមហ៊ុន។ ហត្ថលេខារបស់អភិបាលម្នាក់ៗអាចចុះក្នុងឯកសារតែមួយ ឬឯកសារច្រើនដែលមានទម្រង់ដូចគ្នាទាំងអស់។

<u>គ.អភិបាលឯករាជ្យ</u>

លុះត្រាតែមានការតម្រូវផ្សេងពីនេះដោយច្បាប់ និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនត្រូវមានអភិបាលឯករាជ្យយ៉ាងហោចណាស់មួយ (០១) រូបក្នុងចំណោមរាល់អភិបាលប្រាំ (០៥) រូប។ រាល់កិច្ចប្រជុំរបស់ក្រុមហ៊ុនត្រូវមានវត្តមានអភិបាល ឯករាជ្យយ៉ាងហោចណាស់មួយ (០១) រូប។ អភិបាលឯករាជ្យត្រូវតែជាសមាជិកនៃគណៈកម្មាធិការសវនកម្ម គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំង។

<u>ឃ.លេខាធិការក្រុមហ៊ុន</u>

ប្រការ៣៣ នៃលក្ខន្តិកៈរបស់ក្រុមហ៊ុនចែងថាក្រុមប្រឹក្សាភិបាលត្រូវធ្វើការជ្រើសរើសតាំងលេខាធិការក្រុមហ៊ុនដើម្បីជួយសម្រួលដល់ការងាររបស់ការងាររបស់ពួកគាត់។ លេខាធិការរបស់ក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរជាបុគ្គលិកជាន់ខ្ពស់មួយ (០១) រូប ដែលបានបំពេញមុខងារបានល្អ មានភក្តីភាព និងមានវិន័យល្អ។

លេខាធិការរបស់ក្រុមហ៊ុនមានមានកាតព្វកិច្ចរាយការណ៍ជូនក្រុមប្រឹក្សាភិបាលតាមរយៈប្រធានក្រុមប្រឹក្សាភិបាល និងមានតួនាទី កាតព្វកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- បង្កើតឲ្យមានប្រសិទ្ធិភាពនៃទំនាក់ទំនងការងារជាមួយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន
- ផ្តល់ជំនួយដល់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល
- តាមដាននូវការវិវត្តន៍នៃច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដែលអាចនឹងមានការប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុនហ៊ុន និងក្រុមប្រឹក្សាភិបាល
- តាមដានអំពីការវិវត្តនៃអភិបាលកិច្ចសាជីវកម្ម និងការទទួលខុសត្រូវផ្នែកសង្គម
- សម្របសម្រួលឲ្យកាតទំនាក់ទំនងរវាងក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ឲ្យមានប្រសិទ្ធិភាព ដើម្បីជួយដល់ការធ្វើសេចក្តីសម្រេចនានា
- រៀបចំ និងគ្រប់គ្រងនិតិវិធី និងការកត់ត្រាកំណត់ហេតុ និងរក្សាកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងមហាសន្និបាតភាគហ៊ុនិក
- ការងារដ៏ទៃទៀតដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាលពីមួយពេលទៅមួយពេល។

**៤.១.២.២.គណៈកម្មាធិការក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលរបស់យើងអាចបង្កើតគណៈកម្មាធិការដើម្បីជួយសម្រួលដល់កិច្ចការរបស់ពួកគាត់ ឬតាមការតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច។ គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាចត្រូវបានបង្កើតឡើងដោយ សេចក្តីសម្រេចសម្លេងភាគច្រើនជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ គណៈកម្មាធិការនីមួយៗត្រូវមានអភិបាលចំនួនមួយ (០១) រូប ឬច្រើននាក់ដែលត្រូវបានជ្រើសតាំងដោយសម្លេងភាគច្រើនរបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ គណៈកម្មធិការត្រូវរៀបចំកិច្ចប្រជុំរបស់ពួកគេក្នុងលក្ខណៈដូចគ្នានឹងក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនដែរ។ គណៈកម្មាធិការនីមួយៗទទួលបានអំណាចដូចដែលផ្តល់ឲ្យតាមរយៈឯកសារជាលាយលក្ខណ៍អក្សរដែលបង្កើតគណៈកម្មាធិការនោះ។

គិតត្រឹមកាលបរិច្ឆេទដាក់ឯកសារផ្តល់ព័ត៌មាននេះ ក្រុមហ៊ុនបានបង្កើតគណៈកម្មាធិការចំនួនពីរ (០២) គឺៈ គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ។ គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងតិចចំនួនបី (០៣)រូប និងត្រូវដឹកនាំដោយអភិបាលដោយអភិបាលឯករាជ្យមួយ (០១) រូប។ សមាជិមួយរូប នៃគណៈកម្មាធិការសវនកម្មត្រូវតែជាអ្នកជំនាញផ្នែកហិរញ្ញវត្ថុ។ សមាជិកដ៏ទៃទៀតនៃគណៈកម្មាធិការសវនកម្មត្រូវមានបទពិសោធន៍ខាងផ្នែកគណេយ្យ និងហិរញ្ញវត្ថុ។

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មនឹងត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុទាំងអស់
- ពិនិត្យលើរបាយការគ្រប់គ្រងផ្ទៃក្នុង
- ពិនិត្យលើការធ្វើសវនកម្មផ្ទៃក្នុង
- ពិនិត្យលើការធ្វើសវនកម្មដោយសវនកម្មឯករាជ្យ
- ធ្វើរបាយការណ៍អំពីកិច្ចការរបស់គណៈកម្មាធិការដាក់ជូបក្រុមប្រឹក្សាភិបាល។

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនេះ នឹងត្រូវបានកំណត់ដោយក្រុមប្រឹក្ស ភិ-បាលដែលរួមមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ការវិភាគហានិភ័យដែលមានរួមមាន៖ ការពណ៌នាអំពីហានិភ័យ ការកំណត់ហានិភ័យ ការប៉ានប្រមាណហានិភ័យ
- ការវាយតម្លៃហានិភ័យ
- ការរាយការណ៍អំពីហានិភ័យ
- ការដោះស្រាយហានិភ័យ
- ការតាមដានហានិភ័យ

## ៤.២. ព័ត៌មានស្តីពីការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុន

### ៤.២.១.ដំណាក់កាលប៊ុកបៀលឌីង

- បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយដោយមានការប្រឹក្សាពីសហាក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីងដោយធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈដើម្បីអញ្ជើញវិនិយោ-គិនឱ្យចូលរួម។
- ដើម្បីជំរុញឱ្យវិនិយោគិនចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង និងធានាថាតម្លៃមូលបត្រកម្មសិទ្ធិបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលបានដាក់ធ្វើប៊ុកបៀលឌីង ត្រូវមានចំនួនចិតសិបភាគរយ (៧០%) នៃមូលបត្រកម្មសិទ្ធិសរុបដែលបានបោះផ្សាយជាសាធារណៈសម្រាប់ធ្វើបរិវិសកម្មដោយសាធារណជន គឺបន្ទាប់ពីការលៃបម្រុងទុកសម្រាប់លក់ជូនវិនិយោគិនសក្តានុពល និងលក់ជូនបុគ្គលិក

ក្នុងករណីដែលក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្តតាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក។ ចំណែកមូលបត្រកម្មសិទ្ធិដែលនៅសល់សាមសិបភាគរយ (៣០%) ទៀតត្រូវបានបម្រុងទុកសម្រាប់ការធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនបានចូលរួមប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីង។

- វិនិយោគិនដែលចូលរួមក្នុងប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង (Book-Building Form) ដែលកំណត់ដោយ គ.ម.ក.។ ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង វិនិយោគិនត្រូវជ្រើសរើសថ្លៃសុំទិញមួយពីក្នុងចន្លោះថ្លៃ (Price range) នៃមូលបត្រកម្មសិទ្ធិដែលត្រូវបានកំណត់ក្នុងឯកសារផ្តល់ព័ត៌មាន និងដែលទទួលបានអនុញ្ញាតជាគោលការណ៍ពី គ.ម.ក.។ វិនិយោគិនត្រូវបញ្ជាក់ផងដែរពីចំនួនមូលបត្រកម្មសិទ្ធិដែលខ្លួនមានបំណងចង់ធ្វើបរិវិសកម្ម។
- វិនិយោគិនដែលបានចូលរួមក្នុងប៊ុកបៀលឌីងត្រូវតម្កល់ប្រាក់កក់ស្មើនឹងដប់ភាគរយ (១០%) នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលខ្លួនបានសុំទិញ ដូចដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។
- ក្រោយពីការបញ្ចប់ដំណើរការប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានការផ្តល់យោបល់ពីសហក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើរលក់ និងស្នើសុំការអនុញ្ញាតពី គ.ម.ក. ដោយភ្ជាប់ជាមួយបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យ និងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង។
- វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃស្មើ ឬខ្ពស់ជាងថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់។ ក្រុមហ៊ុនបោះផ្សាយដោយមានការផ្តល់យោបល់ពីសហក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ដោយប្រើប្រាស់វិធីថ្លឹងរកមធ្យមភាគ (Weighted-average) លើមូលដ្ឋានតម្លៃ និងចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនបានជ្រើសរើស និងបង្ហាញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

- ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ដែលបានគណនាក្នុងកថាខណ្ឌខាងលើ អាចត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពទីផ្សារដោយមានការសម្រេចពី គ.ម.ក.។
- បន្ទាប់ពីទទួលបានការអនុញ្ញាតចុងក្រោយលើការចុះបញ្ជីឯកសារផ្តល់ព័ត៌មានភ្លាម ក្រុមហ៊ុនបោះផ្សាយដោយមានការផ្តល់យោបល់ពីសហក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវជូនដំណឹងទៅវិនិយោគិនដែលទទួលបានជោគជ័យ និងមិនទទួលបានជោគជ័យពីការធ្វើប៊ុកបៀលឌីង។ ស្របពេលជាមួយគ្នា ក្រុមហ៊ុនបោះផ្សាយត្រូវផ្ទេរប្រាក់កក់ដប់ភាគរយ (១០%) ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងការប៊ុនបៀលឌីង ឬរក្សាទុកក្នុងករណីវិនិយោគិនដែលមិនទទួលបានជោគជ័យណាមួយសម្រេចបន្តចូលរួមក្នុងដំណាក់កាលធ្វើបរិវិ-សកម្ម។

### ៤.២.២.ដំណាក់កាលនៃការធ្វើបរិវិសកម្មកម្មសិទ្ធិ

- វិនិយោគិនដែលទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មចំនួនមូលបត្រកម្មសិទ្ធិលើសពីចំនួនដែលដែលបានរក្សាទុកពីការធ្វើប៊ុកបៀលឌីង ដោយត្រូវការដាក់បន្ថែម ឱ្យស្របនឹងចំនួនមូលបត្រកម្មសិទ្ធិជាក់ស្តែងដែលបានធ្វើបរិវិសកម្ម។
- វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងការប៊ុកបៀលឌីង ហើយមានបំណងបន្តចូលរួមក្នុងការធ្វើបរិវិសកម្មអាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដោយត្រូវការដាក់ប្រាក់បន្ថែម ឱ្យស្របនឹងចំនួនមូលបត្រកម្មសិទ្ធិជាក់ស្តែងដែលបានធ្វើបរិវិសកម្ម។
- វិនិយោគិនដែលមិនបានចូលរួមក្នុងការធ្វើប៊ុកបៀលឌីង ក៏អាចចូលរួមធ្វើបរិវិសកម្មដោយដាក់ប្រាក់កក់យ៉ាងតិចមួយរយភាគរយ(១០០%) នៃចំនួនមូលបត្រកម្មសិទ្ធិទាំងអស់ដែលបានធ្វើបរិវិសកម្ម។
- វិនិយោគិនដែលទទួលបានជោគជ័យក្នុងការប៊ុកបៀឌីង ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្មក្នុងករណីដែលចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងការប៊ុកបៀលឌីងលើសពីចំនួនដែលត្រូវបានរក្សាទុកសម្រាប់វិនិយោគិននោះពីការធ្វើប៊ុកបៀលឌីង

ហើយមានវិនិយោគិនដែលទទួលបានជោគជ័យនោះ អាចសម្រេចមិនធ្វើបរិវិសកម្ម និងដកប្រាក់កក់ដប់ភាគរយ(១០%) មកវិញបាន។

- ក្នុងករណីដែលវិនិយោគិនដែលទទួលបានជោគជ័យ ធ្វើបរិវិសកម្មចំនួនមូលបត្រកម្មសិទ្ធិដែលលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានបម្រុងទុកសម្រាប់វិនិយោគិននោះពីការធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យពីការធ្វើបរិវិសកម្ម តាមវិធានប្រូរ៉ាតា (Pro Rata)។
- ក្នុងករណីដែលវិនិយោគិនដែលទទួលបានជោគជ័យ (ទាំងនីតិបុគ្គល និងរូបវន្តបុគ្គល) ពីការធ្វើប៊ុកបៀឌីងមានចំនួនច្រើនលុប ដែលបណ្តាលឱ្យការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដោយវិនិយោគិនដែលទទួលបានជោគជ័យមានចំនួនច្រើនលើសលុបលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបម្រុងទុកសម្រាប់ការធ្វើប៊ុកបៀលឌីងនោះ គ.ម.ក. អាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិនិត្យលើការបែងចែកមូលបត្រកម្មសិទ្ធិចំនួនបន្ថែមជូនដល់វិនិយោគិនដែលទទួលបានជោគជ័យ ដែលចំនួនបន្ថែមនេះមិនលើសពីពីរភាគបី(២/៣) នៃចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានលៃបម្រុងទុកសម្រាប់វិនិយោគិនដទៃរួមទាំងវិនិយោគិនដែលមិនទទួលបានជោគជ័យ និងវិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការធ្វើប៊ុកបៀលឌីង។
- បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ប្រសិនបើមានអ្នកធ្វើបរិវិសកម្មដែលមិនទទួលបានចំណែកមូលបត្រកម្មសិទ្ធិដែលខ្លួនបានធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីសហាក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហាក្រុមហ៊ុនធានាទិញមូលបត្រត្រូវបង្វិលសាច់ប្រាក់ពីការធ្វើបរិវិសកម្មទៅអ្នកធ្វើបរិវិសកម្មវិញ។
- ចំពោះវិនិយោគិនទាំងឡាយដែលទទួលបានជោគជ័យដែលបានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ប្រសិនបើចំនួនមូលបត្រកម្មសិទ្ធិដែលបានធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យទាំងនោះ មានចំនួនតិចជាងចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានបម្រុងទុកសម្រាប់ពួកគាត់ពីការធ្វើប៊ុកបៀឌីង វិនិយោគិនដែលទទួលបានជោគជ័យនោះត្រូវធ្វើបរិវិសកម្មចំនួនមូលបត្រយ៉ាងតិចស្មើនឹងប្រាក់កក់ដប់ភាគរយ(១០%)។
- ក្នុងករណីដែលចំនួនមូលបត្រកម្មសិទ្ធិសរុប ដែលបានធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង មានចំនួនតិចជាងមូលបត្រកម្មសិទ្ធិ

ដែលត្រូវបានបម្រុងទុកសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងការប៊ុកបៀលនីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រត្រូវបែងចែកជូនវិនិយោគិនដែលទទួលបានជោគជ័យនូវចំនួនមូលបត្រកម្មសិទ្ធិដែលបានស្នើសុំទិញក្នុងពេលធ្វើប៊ុកបៀលនីង។ បន្ទាប់មកចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់ត្រូវបែងចែកជូនវិនិយោគិនដទៃទៀត រួមទាំងវិនិយោគិនដែលមិនទទួលបានជោគជ័យ និងវិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការធ្វើប៊ុកបៀលនីង។

- ក្នុងករណីដែលចំនួនមូលបត្រកម្មសិទ្ធិសរុប ដែលត្រូវបានធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនទទួលបានជោគជ័យ និងវិនិយោគិនដែលមិនបានចូលរួមក្នុងការប៊ុកបៀលនីង មានចំនួនលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបានបម្រុងទុកសម្រាប់ក្រុមវិនិយោគិនប្រភេទនេះ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបែងចែកមូលបត្រកម្មសិទ្ធិ តាមវិធានប្រូរ៉ាតា។
- ក្នុងករណីដែលចំនួនមូលបត្រកម្មសិទ្ធិសរុប ដែលត្រូវបានធ្វើបរិវិសកម្មដោយវិនិយោគិនមិនទទួលបានជោគជ័យ និងវិនិយោគិនដែលមិនបានចូលរួមក្នុងការប៊ុកបៀលនីង មានចំនួនតិចជាងចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបម្រុងទុកសម្រាប់ក្រុមវិនិយោគិនប្រភេទនោះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិននោះស្របទៅតាមការស្នើសុំធ្វើបរិវិសកម្ម ហើយចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវបែងចែកជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលនីង ដោយវិនិយោគិនដែលទទួលបានជោគជ័យទាំងនោះ បានធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិលើសពីចំនួនដែលបានបម្រុងទុកសម្រាប់វិនិយោគិនទាំងនោះក្នុងការធ្វើប៊ុកបៀលនីង។
- ក្នុងករណីដែលមានមូលបត្រកម្មសិទ្ធិនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្ម ដូចមានចែងក្នុងគោលការណ៍ណែនាំនេះសហក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហក្រុមហ៊ុនធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនៅសល់ទាំងអស់។
- បន្ទាប់ពីការបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយមានជំនួយពីសហក្រុមហ៊ុនធានាទិញមូលបត្រចម្បង និងសហក្រុមហ៊ុនធានាទិញមូលបត្រ និងភ្នាក់ងារបញ្ជិកាមូលបត្ររបស់ខ្លួន ក្រុមហ៊ុនបោះផ្សាយត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃ

ការធ្វើបរិវិសកម្ម និងត្រូវដាក់របាយការណ៍នេះជូន គ.ម.ក. ភ្លាមដើម្បីសុំការពិនិត្យ និងសម្រេច។

**៤.២.៣.ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ**

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង នៃភាគហ៊ុនបោះផ្សាយលក់ចំនួន ១១.៥៧៥.០០០ ក្នុងតម្លៃបោះផ្សាយលក់ដែលពាក្យស្នើសុំទិញត្រូវបានធ្វើឡើងតាមរយៈ ប៊ុកប៉ៀលឌីង និងការធ្វើបរិវិសកម្មដូចមានកំណត់ក្នុងគោលការណ៍ណែនាំស្តីអំពី ប៊ុកប៉ៀលឌីង និងការធ្វើបរិវិសកម្ម។

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិទៅឲ្យសធារណជនក្នុងការទិញមូលបត្រដែលមាន៖

-ការបោះផ្សាយសម្រាប់ការធ្វើបរិវិសកម្ម ឬទិញមូលបត្ររបស់ក្រុមហ៊ុនសាធារណជនជាក់លាក់ ណាមួយ ដែលត្រូវជ្រើសរើសឡើងតាមរបៀបណាក៏ដោយ។

-ការបោះផ្សាយសម្រាប់ការធ្វើបរិវិសកម្ម ឬទិញមូលបត្រដែលធ្វើឡើងតាមរបៀបចៃដន្យចំពោះសាធារណជនដែលបានជ្រើសរើស។

-ការបោះផ្សាយសម្រាប់ការធ្វើបរិវិសកម្ម ឬទិញមូលបត្រទៅឲ្យបុគ្គលដែលក្រុមហ៊ុនបោះផ្សាយបានស្គាល់តាមរយៈការផ្សាយពាណិជ្ជកម្ម ដែលជាទូទៅត្រូវបានធ្វើឡើងក្នុងបំណងពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ឬអញ្ជើញបុគ្គលនោះឲ្យមកស្វែងរកព័ត៌មាន ឬយោបល់អំពីមូលបត្រកម្មសិទ្ធិ។

-ការចែកចាយអត្ថបទផ្សាយពាណិជ្ជកម្ម ឯកសារផ្តល់ព័ត៌មាន ឬពាក្យស្នើសុំដែលទាក់ទងនឹងការដាក់ពាក្យស្នើសុំទិញ ការទិញ ឬការលក់មូលបត្រ។ ប៉ុន្តែការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមិនរាប់បញ្ចូល៖

- ការបោះផ្សាយលក់មូលបត្រជាឯកជនដើម្បីធ្វើបរិវិសកម្ម ការទិញ ឬការលក់ដែលត្រូវបានធ្វើឡើងដោយសហការី។
- ការបោះផ្សាយលក់មូលបត្រជាឯកជនមួយ ដែលធ្វើឡើងសម្រាប់បុគ្គលតិចជាង ៣០ នាក់។
- ការអញ្ជើញឲ្យបុគ្គលណាមួយចុះកិច្ចព្រមព្រៀងធានាទិញមូលបត្រ ឬធានាទិញមូលបត្របន្តក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ។

**៤.២.៤.តម្លៃបោះផ្សាយ**

តម្លៃបោះផ្សាយក្នុងមួយភាគហ៊ុនដែលវិនិយោគិនត្រូវបង់ ត្រូវបានកំណត់តាមរយៈការធ្វើ

ប៉ុកប៉ៀលឹងគឺ ២.៨៦០ រៀល (ប្រមាណ ០,៧១៣ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុនដែលត្រូវគោរពតាមខសន្យា និងលក្ខខណ្ឌណានៃឯកសារផ្តល់ព័ត៌មាន។

### ៤.២.៥.សហក្រុមហ៊ុនធានាទិញមូលបត្រចម្បង

សហក្រុមហ៊ុនធានាទិញមូលបត្រ សំដៅទៅលើក្រុមហ៊ុន កម្ពុ ស៊ីយូរីធី និង អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី (CPS)។ ក្រុមហ៊ុន កម្ពុ ស៊ីយូរីធី និង អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី ជាក្រុមហ៊ុនធានាទិញមូលបត្រចំបងក្នុងដំណើរការ IPO របស់ក្រុមហ៊ុន។ CPS បានចុះបញ្ជី និងទទួលស្គាល់ដោយ គ.ម.ក. ក្នុងការប្រកបអាជីវកម្មធានាទិញមូលបត្រដែលរួមមាន៖

-ផ្តល់យោបល់សំខាន់ក្នុងការបោះផ្សាយលក់មូលបត្រដូចជា ការកំណត់ថ្លៃ ការកំណត់ចំនួនទឹកប្រាក់សរុប នៃកម្មសិទ្ធិបោះផ្សាយ ការកំណត់ចំនួនមូលបត្រដែលត្រូវបោះផ្សាយនៅពេលធ្វើការបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលាបែងចែកមូលបត្រកម្មសិទ្ធិជាដើម។

-ទទួលទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ពីការលក់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពីក្រុនហ៊ុនបោះផ្សាយ។

-រៀបចំការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈក្នុងនាមក្រុមហ៊ុនបោះផ្សាយ ឬចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុន PPSEZ។

### ៤.២.៦.កិច្ចសន្យាធានាទិញមូលបត្រ

កិច្ចព្រមព្រៀងមួយ ដែលរួមបញ្ចូលកិច្ចសន្យាធានាទិញជាមួយសហក្រុមហ៊ុនធានាទិញមូលបត្រ ដែលក្រោមកិច្ចព្រមព្រៀងនេះ បុគ្គលម្នាក់ដែលទទួលបានអាជ្ញាបណ្ណតាមច្បាប់ស្តីពីការបោះផ្សាយមូលបត្រលក់មូលបត្រ និងការជួញដូរមូលបត្រមហាជន ក្នុងការប្រកបអាជីវកម្មមូលបត្រទទួលការធ្វើបរិវិសកម្ម ឬទិញតាមសំណើរលក់មូលបត្រជាសាធារណៈសម្រាប់ការធ្វើបរិវិសកម្ម ការទិញ ឬលក់រហូតដល់កាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម ការទិញ ឬលក់ជាសាធារណៈទោះជាការប្តេជ្ញារបស់ក្រុមហ៊ុន ឬការខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពឡើយ។

### ៤.២.៧.វិនិយោគិនសាធារណៈ

សាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរាប់បញ្ចូលទាំងរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលទ្ធភាពទាំងផ្នែកហិរញ្ញវត្ថុ និងគតិយុត្តិក្នុងការវិនិយោគលើមូលបត្រមហាជនដែលត្រូវបោះផ្សាយលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត

ឬនីតិបុគ្គលប្រតិស្រុតដែលមិនមែនជាក្រុមហ៊ុនជាសម្ព័ន្ធ ឬបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនបោះផ្សាយ ដូចមានចែងក្នុងច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**៤.២.៨.បុគ្គលពាក់ព័ន្ធ**

បុគ្គលពាក់ព័ន្ធរបស់ PPSP គឺជាបុគ្គលណាមួយក្នុងចណោមបុគ្គលខាងក្រោម៖

-ភាគហ៊ុនិកស្ថាបនិករបស់ PPSP

-អភិបាលរបស់ PPSP ឬបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ PPSP

-សាច់ញាតិជិតស្និទ្ធរបស់អភិបាលដែលត្រូវបានលើកឡើងក្នុងអភិបាលរបស់ PPSP ឬបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ PPSP

-បុត្រសម្ព័ន្ធមួយ ឬក្រុមហ៊ុនហូលឌីងរបស់ PPSP ឬបុត្រសម្ព័ន្ធមួយរបស់ PPSP

-អភិបាលឬមន្រ្តី

-បុគ្គលណាមួយដែលកាន់កាប់ភាគហ៊ុនច្រើនជាង ៥% (ប្រាំភាគរយ) នៃភាគហ៊ុនមិនទាន់ទូទាត់

-សមាជិកណាមួយនៃគ្រួសាតរផ្ទាល់ (រួមមានប្ដី ប្រពន្ធ កូន ឪពុក បងប្អូនប្រុស និងបងប្អូនស្រីដូចដែលបានលើកឡើងដូចចំនុចខាងលើ។

-បុគ្គលដដែលមានទំនាក់ទំនងនឹងអភិបាលនៃការបោះផ្សាយ សម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងនៃការបោះផ្សាយ ដែលទំនាក់ទំនងកើតឡើងនៅក្នុងប្រិបត្តិការ ឬរៀបចំដោយអ្នកបោះផ្សាយ។

-បុគ្គលដែលធ្លាប់ជាអភិបាល ឬបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលបោផ្សាយដែលទំនាក់ទនងកើតឡើតនៅក្នុងប្រតិបត្តិការពាណិជ្ជកម្មក្នុងកំឡុងពេលពីរឆ្នាំចុងក្រោយមុនពេលកាលបរិច្ឆេទចេញផ្សាយនៃឯកសារផ្ដល់ព័ត៌មាន។

-អភិបាលដែលមានតួនាទីក្នុងសមាគមឬអង្គការមិនយកចំណេញក្រៅពីក្រុមហ៊ុនបោះផ្សាយ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងបានចុះកម្មសិក្សាដោយផ្ទាល់នៅគណៈកម្មការមូលបត្រកម្ពុជាកន្លងមកបានបង្ហាញអោយឃើញថាអភិបាលកិច្ចសាជីវកម្មក្នុងវិស័យមូលបត្រ គឺជាផ្នែកមួយយ៉ាងសំខាន់គឺ ដើម្បីជួយសម្រួលដល់ប្រសិទ្ធិភាពសហគ្រិនភាព ភាពប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងក្រុមហ៊ុន ដើម្បីធានាបាននូវភាពជោគជ័យរយៈពេលវែងរបស់ក្រុមហ៊ុនប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ការរៀបចំអភិបាលកិច្ចសាជីវកម្មគឺជាយុទ្ធសាស្រ្តដ៏សំខាន់មួយសម្រាប់ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី (PPSEZ) ពីព្រោះវាអាចជួយក្នុងការធានានូវទំនាក់ទំនងក្នុងចំណោមថ្នាក់គ្រប់គ្រង ក្រុមប្រឹក្សាភិបាល ម្ចាស់ភាគហ៊ុនគ្រប់គ្រងអាជីវកម្ម និងអ្នកដ៏ទៃទៀតដែលជាប់ពាក់ព័ន្ធជាមួយក្រុមហ៊ុនដូចជា ឥណទាយក និយោជិក អ្នកផ្គត់ផ្គង់ សង្គម និងរដ្ឋាភិបាលជាដើម។ ដូចនេះហើយបានជាក្រុមហ៊ុនបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការរៀបចំក្រុមប្រឹក្សាភិបាល ដែលជាផ្នែកមួយសំខាន់នៅក្នុងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ចំពោះការបោះផ្សាយមូលបត្រហើយក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភិអិលស៊ី (PPSEZ) បានរៀបចំឲ្យមានគណៈកម្មាធិការមួយចំនួនក្នុងក្រុមប្រឹក្សាភិបាល ដូចជាគណៈកម្មាធិការសវនកម្ម គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល អភិបាលឯករាជ្យ អភិបាលប្រតិបត្តិ និងអភិបាលមិនប្រតិបត្តិ។ ស្របពេលគ្នាជាមួយនេះអភិបាលកិច្ចសាជីវកម្មបានផ្តល់នូវគុណសម្បត្តិយ៉ាងច្រើនទៅឲ្យក្រុមហ៊ុនក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈដូចជា ការបង្កើនទំនុកចិត្តរបស់វិនិយោគិនទៅលើក្រុមហ៊ុន មានភាពងាយស្រួលក្នុងការឈានចូលទីផ្សារមូលបត្រ និងអាចធានាសុវត្ថិភាពចំពោះការវិនិយោគរបស់ភាគហ៊ុនិក។

សរុបសេចក្តីមកការអនុវត្តន៍នូវអភិបាលកិច្ចសាជីវកម្មក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈគឺទាមទារនូវលក្ខខណ្ឌច្រើន ហេតុដូច្នេះហើយបានជាគិតតាមកម្រិតនៃការគ្រប់គ្រងក្រុមប្រឹក្សាភិបាលត្រូវបានចាត់ទុកជាតួអង្គសំខាន់ នៅក្នុងចំណោមតួអង្គផ្សេងទៀតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន។ ដូចដែលបានបង្ហាញ និងពន្យល់ផ្សេងៗពីក្រុមប្រឹក្សាភិបាគឺជាចំនុចសំខាន់មួយសម្រាប់ការកំណត់គោលនយោបាយនិងគោលការណ៍ជាច្រើន ដើម្បីពង្រឹងប្រព័ន្ធផ្ទៃក្នុងរបស់ក្រុមហ៊ុន។

## ២.ការផ្តល់អនុសាសន៍

ផ្អែកលើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះរួចមកឃើញថាការអនុវត្តន៍អភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេ។ ដើម្បីឱ្យការអនុវត្តអភិបាលកិច្ចសាជីវកម្មមានប្រសិទ្ធិភាពខ្ពស់ គឺតម្រូវឱ្យក្រុមហ៊ុនទាំងអស់គោរពតាមបទប្បញ្ញត្តិ ពាក់ព័ន្ធផ្សេងៗ

ឱ្យបានពេញលេញ។ ដូចនេះយើងខ្ញុំសូមផ្តល់អនុសាសន៍បន្ថែមមួយចំនួនចំពោះក្រុមហ៊ុនក្នុងការកែលម្អ ក៏ដូចជាការអភិវឌ្ឍរួមមានៈ

- ក្រុមហ៊ុនគួររៀបចំ និងអនុវត្តអភិបាលកិច្ចសាជីវកម្មរបស់ខ្លួនស្របតាមបទប្បញ្ញត្តិ ព្រោះវាជាយុទ្ធសាស្ត្រមួយដែលធ្វើឱ្យក្រុមហ៊ុនប្រកបអាជីវកម្មប្រកបដោយភាពជោគជ័យរយៈពេលវែង និងបង្កើនទំនុកចិត្តរបស់វិនិយោគិនលើក្រុមហ៊ុន ព្រមទាំងមានឱកាសឈានចូលទីផ្សារមូលបត្របានងាយស្រួល។
- ក្រុមហ៊ុនPPSEZ បានអនុវត្តតាមប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ស្ទើរទាំងស្រុងហើយប៉ុន្តែដើម្បីជាការអនុវត្តកាន់តែប្រសើរទៀតនោះ ក្រុមហ៊ុនគួរតែបង្កើតគណៈកម្មាធិការតែងតាំងមួយបន្ថែមទៀតព្រោះគណៈកម្មាធិការតែងតាំងមានតួនាទីទទួលខុសត្រូវចំពោះការរៀបចំនីតិវិធីឬការពិនិត្យឡើងវិញ និងការផ្តល់អនុសាសន៍ សម្រាប់លាភការ និងប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។
- ក្រុមហ៊ុនគួរបង្កើនលក្ខណៈងាយស្រួលក្នុងការផ្តល់ព័ត៌មានទៅដល់ភាគហ៊ុនិកតាមរយៈគេហទំព័រផ្លូវការ
- ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មានដែលមានតម្លាភាព និងបន្តគោរពតាមបទប្បញ្ញត្តិទាក់ទងក្នុងវិស័យមូលបត្រឱ្យបានម៉ឺងម៉ាត់ដោយសារក្រុមហ៊ុនបោះផ្សាយគឺ ក្រុមហ៊ុនមួយដែលត្រូវទាមទារការទទួលទំនុកចិត្តពីវិនិយោគិន។
- ដើម្បីឱ្យក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះល្បីល្បាញក្រុមហ៊ុនត្រូវមានទំនាក់ទំនងជាមួយសង្គមក៏ដូចជាជួយដល់សង្គមក្នុងការងារមនុស្សធម៌ សាងសងសាលារៀន មន្ទីរពេទ្យជាដើម។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១. អនុក្រឹត្យលេខ៥៥៤ អនក្រ.បក ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩

២. អនុក្រឹត្យលេខ ៧០ អនក្រ.បក ស្ដីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១

៣. ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧

៤. ប្រកាសលេខ០០២ គ.ម.ក.ស្ដីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០

៥. ប្រកាសលេខ០០២/១២ គ.ម.ក./ប្រ.ក. ស្ដីពីការបង្ហាញព័ត៌មានសាជីវកម្មចុះថ្ងៃ២៧ ខែមេសា ឆ្នាំ២០១២

៦. ប្រកាសលេខ ០០៣/១២ គ.ម.ក./ប្រ.ក. ស្ដីពីលក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុ នៃក្រុមហ៊ុនមូលបត្រ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២

៧. គោលការណ៍ណែនាំលេខ០០១ គ.ម.ក./គ.ណ.ន. ស្ដីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១

៨. ប្រកាសលេខ០០៥/១១ គ.ម.ក./ប្រ.ក. ស្ដីពី ការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការ ផាត់ទាត់ និងទូទាត់មូលបត្រ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១

៩. អនុក្រឹត្យលេខ៩៧ អនក្រ.បកស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រ-កម្ពុជា ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨

## សៀវភៅ


១. មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ,បោះពុម្ពលើកទី១.២០១១, លោក បៀន សាំង

២. ធនាគារ និងហិរញ្ញវត្ថុ,២០០៩, លោក សួន ចំរើន

៣.ទីផ្សារភាគហ៊ុនជាអ្វី,២០០៧, លោក ហាស់ វាសនា

៤. Paper P1 Governance, Risk and Ethics

៥. Mishkin and Eakins, fifth edition, 2006, Page 217

## ឯកសារធ្វើបទបង្ហាញ

១. គណៈកម្មការមូលបត្រកម្ពុជា, សិក្ខាសាលាស្តីពី ផ្សារមូលបត្រ អាជីវកម្មមូលបត្រ និងការពង្រឹងការអនុវត្តច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧

២. គណៈកម្មការមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រលេខ៣២ចេញផ្សាយប្រចាំសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០១៧ ហេតុអ្វីក្រុមហ៊ុនគួរមានអភិបាលកិច្ចសាជីវកម្មល្អ?

៣. គណៈកម្មការមូលបត្រកម្ពុជា សហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ, សិក្ខាសាលាស្តីពី ការរៀបចំផែនការសម្រាប់ការអនុវត្តអភិបាលកិច្ចសាជីវកម្ម,ថ្ងៃទី១៤-១៤ ខែមីនា ឆ្នាំ២០១៧

## ឯកសារផ្សេងៗ

១. ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី, ២០១៦, ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

២. ឆេង សុភក្ត្រា និង ឆេង ដាលីន,២០១២, ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជា, ភ្នំពេញៈ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៣. ប៊ុត ស្រីនិច, ២០១៦, ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា, ភ្នំពេញៈ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## គេហទំព័រ

១. គេហទំព័រគណៈកម្មការមូលបត្រកម្ពុជា:http://www.secc.gov.kh/

២. គេហទំព័រផ្សារមូលបត្រកម្ពុជា :http://www.csx.com.kh/

៣. គេហទំព័រភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ីhttp://www.ppsez.com/en/

៤. :http://en.wikipedia.org/wiki/Corporate_governance

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មការមូលបត្រកម្ពុជា

# SECURITIES AND EXCHANGE COMMISSION OF CAMBODIA

# ប្រកាស

# ស្តីពី

# អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

# PRAKAS

# ON

# THE CORPORATE GOVERNANCE FOR LISTED COMPANIES

២០១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០០៧.............គ ម ក

# ប្រកាស
# ស្តីពី
# អភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ/បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការអនុវត្តអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣. –**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវធានាឱ្យបាននូវអភិបាលកិច្ចសាជីវកម្មល្អ តាមរយៈការបង្កើតយន្តការដើម្បីការពារសិទ្ធិរបស់ភាគហ៊ុនិក ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុន ការកំណត់សិទ្ធិអំណាចនិងកាតព្វកិច្ចរបស់ក្រុមប្រឹក្សាភិបាល ការបង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព និងការការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ ស្របតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ៤. –**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ៖

១-ក្រុមប្រឹក្សាភិបាល សំដៅដល់បុគ្គលមួយក្រុមដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគហ៊ុនិកតាមរយៈមហាសន្និបាតភាគហ៊ុនិក ហើយមានសិទ្ធិអំណាចអនុវត្តភារកិច្ចដូចមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុន។

២-គណៈកម្មាធិការសវនកម្ម សំដៅដល់គណៈកម្មាធិការមួយនៃក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ រាល់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការត្រួតពិនិត្យខាងក្នុង និងខាងក្រៅ ព្រមទាំងសវនកម្ម។

៣-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សាភិបាលដែលទទួលខុសត្រូវក្នុងការវិភាគ វាយតម្លៃ តាមដាន និងរាយការណ៍អំពីហានិភ័យរបស់ក្រុមហ៊ុន ព្រមទាំងគ្រប់គ្រងហានិភ័យទាំងនោះ។

៤-គណៈកម្មាធិការតែងតាំង សំដៅដល់គណៈកម្មាធិការឯកទេសមួយរបស់ក្រុមប្រឹក្សា-ភិបាលដែលទទួលខុសត្រូវក្នុងការពិនិត្យឡើងវិញ និងវាយតម្លៃ អំពីគុណវុឌ្ឍិបុគ្គលទាំងឡាយដែលជាបេក្ខភាពសម្រាប់ការតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលទទួលបានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

៥-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៦-បុគ្គលិកជាន់ខ្ពស់ សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋានរហូតដល់អគ្គនាយក រួមទាំងលេខាធិការក្រុមហ៊ុន និងប្រធានសវនកម្មផ្ទៃក្នុង និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៧-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច សំដៅដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចំនួនតិចជាង ០៥ (ប្រាំ) ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន។

៨-សមាជិកគ្រួសារផ្ទាល់ សំដៅដល់ប្តី ប្រពន្ធ កូន ឪពុកម្តាយ បងប្អូនប្រុស បងប្អូនស្រី។

៩-សវនករឯករាជ្យ សំដៅដល់សវនកររបស់ក្រុមហ៊ុនគណនេយ្យជំនាញដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ហើយដែលទទួលស្គាល់ដោយ គ.ម.ក.។

១០-សែលហ្វ៍ឌៀលីង (Self-Dealing) សំដៅដល់ទង្វើរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិ ជំនួស អ្នកផ្តល់ប្រឹក្សាច្បាប់ បុគ្គលិករបស់ក្រុមហ៊ុន ឬគ្រប់បុគ្គលពាក់ព័ន្ធនឹងកិច្ចសន្យាដែលទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួន នៅក្នុងប្រតិបត្តិការណាមួយ។

១១-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

១២-អភិបាលឯករាជ្យ សំដៅដល់សមាជិកឯករាជ្យដែលមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រង ផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅដែលមិនសមស្រប។

១៣-អភិបាលប្រតិបត្តិ សំដៅដល់អភិបាលដែលមានមុខតំណែងជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

១៤-អភិបាលមិនប្រតិបត្តិ សំដៅដល់អភិបាលដែលមិនមែនជាអភិបាលប្រតិបត្តិ។

## ជំពូកទី ២
## ភាគហ៊ុនិក

**ប្រការ ៥.-**

សិទ្ធិជាមូលដ្ឋានរបស់ភាគហ៊ុនិក ដែលបានកំណត់ដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មិនត្រូវបានដកហូតឬរឹតត្បិតដោយការចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុនឡើយ។ ភាគហ៊ុនិកត្រូវទទួលបាននូវការគោរព និងការពារសិទ្ធិទាំងនេះ ពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុន។

ភាគហ៊ុនិកមានសិទ្ធិទទួលបានការចុះបញ្ជីជាកម្មសិទ្ធិករលើបណ្ណភាគហ៊ុនប្រកបដោយសុវត្ថិភាព សិទ្ធិក្នុងការផ្ទេរ ឬកាត់កងបណ្ណភាគហ៊ុន សិទ្ធិទទួលបាននូវព័ត៌មានពីក្រុមហ៊ុន សិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក និងអនុវត្តសិទ្ធិបោះឆ្នោត ដូចជា សិទ្ធិបោះឆ្នោតជ្រើសតាំង ដកចេញ ឬជំនួសនូវសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់។

**ប្រការ ៦.-**

ការជ្រើសរើសអភិបាលត្រូវធ្វើឡើងតាមរយៈការបោះឆ្នោត ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន។ ភាគហ៊ុនិកមានសិទ្ធិធ្វើការបោះឆ្នោតជ្រើសតាំង ដកចេញ ឬជំនួស នូវអភិបាល ព្រមទាំងការបោះឆ្នោតអនុម័តនូវកិច្ចការផ្សេងៗរបស់ក្រុមហ៊ុន តាមរយៈកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកក្នុងរូបភាពដោយផ្ទាល់ តាមរយៈអាណត្តិគាហកៈ។

**ប្រការ ៧.-**

ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ភាគហ៊ុនិកម្នាក់ៗអាចពិនិត្យបញ្ជីឈ្មោះរបស់ភាគហ៊ុនិកទាំងឡាយបាន នៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន ឬនៅទីកន្លែងដែលរក្សាទុកបញ្ជីមូលបត្រនោះ នៅក្នុងម៉ោងធ្វើការ ឬនៅពេលប្រជុំមហាសន្និបាតភាគហ៊ុនិកដែលបញ្ជីឈ្មោះត្រូវបានរៀបចំ។

ក្រុមហ៊ុនគួរតែមានគេហទំព័រមួយដែលអាចឱ្យភាគហ៊ុនិក និងសាធារណជនអាចទទួលបានព័ត៌មាន។ ភាគហ៊ុនិកអាចទទួលបាននូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច លទ្ធផលប្រតិបត្តិការ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ព្រមទាំងព័ត៌មានរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ តាមរយៈគេហទំព័ររបស់ក្រុមហ៊ុន និងព័ត៌មានផ្សេងទៀតអំពីក្រុមហ៊ុន។ ប្រសិនបើក្រុមហ៊ុនមិនមានគេហទំព័រទេ ភាគហ៊ុនិកអាចធ្វើសំណើសុំថតចម្លងឯកសារដូចរៀបរាប់ខាងលើ ដោយតម្រូវឱ្យបង់ថ្លៃសមរម្យសម្រាប់ការបោះពុម្ព និងការចែកចាយឯកសារទាំងនោះ។ ភាគហ៊ុនិកមានសិទ្ធិទទួលបានទាន់ពេល អំពីព័ត៌មានដែលបានរៀបរាប់ខាងលើ។

**ប្រការ ៨.-**

ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ភាគហ៊ុនិកដែលប្រមូលផ្តុំសម្លេងបានចាប់ពី ៥១ (ហាសិបមួយ) ភាគរយឡើងទៅ មានសិទ្ធិស្នើឱ្យអភិបាលរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ និងស្នើឡើងនូវកម្មវត្ថុដើម្បីដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំដែលកម្មវត្ថុទាំងនោះមាន ដូចជា ការកែតម្រូវលក្ខន្តិកៈក្រុមហ៊ុន បញ្ហាអភិបាលកិច្ចរបស់ក្រុមហ៊ុន ការប្រែប្រួលមូលធន ព្រមទាំងកម្មវត្ថុផ្សេងទៀតដែលអនុញ្ញាតដោយលក្ខន្តិកៈក្រុមហ៊ុន។

អភិបាលមានសិទ្ធិកោះប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ និងវិសាមញ្ញ។

**ប្រការ ៩.-**

ក្រុមប្រឹក្សាភិបាលត្រូវតែការពារផលប្រយោជន៍របស់ភាគហ៊ុនិកទាំងអស់ និងត្រូវការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច រួមមាន ៖

-សិទ្ធិស្វែងរកព័ត៌មាន

-សិទ្ធិក្នុងការបញ្ចេញយោបល់

-សិទ្ធិស្នើកែតម្រូវ។

ក្រុមប្រឹក្សាភិបាលត្រូវធានាធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនង និងអន្តរកម្មរវាងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច បុគ្គលិកជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវស្នើសុំការអនុម័តពីភាគហ៊ុនិក លើការកែតម្រូវនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន អំពីប្រព័ន្ធបោះឆ្នោតជ្រើសនៅក្នុងមហាសន្និបាតភាគហ៊ុនិក។ ករណីទទួលបានការអនុម័ត ប្រព័ន្ធបោះឆ្នោតជ្រើសនេះត្រូវបានអនុវត្តនៅរាល់កិច្ចប្រជុំ។

**ប្រការ ១០.-**

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនដែលមានថ្នាក់ដូចគ្នាត្រូវមានសិទ្ធិដូចគ្នា។ នីតិវិធី និងដំណើរការនៃមហាសន្និបាតភាគហ៊ុនិក ត្រូវរៀបចំឡើងក្នុងលក្ខខណ្ឌដែលអនុញ្ញាតឱ្យភាគហ៊ុនិកទទួលបាននូវសិទ្ធិដូចគ្នា។

ភាគហ៊ុនធម្មតាក្នុងមួយភាគហ៊ុន ត្រូវផ្តល់ឱ្យភាគហ៊ុនិកនូវសិទ្ធិបោះឆ្នោតមួយសម្លេង ដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ហើយសិទ្ធិបោះឆ្នោតនេះមិនអាចត្រូវបានរឹតត្បិតដោយបុគ្គលណាឡើយ។

ភាគហ៊ុនិកត្រូវតែទទួលបាននូវព័ត៌មានចាំបាច់ និងទាន់ពេល ពីក្រុមហ៊ុនដូចៗគ្នា ដោយគ្មានភាគហ៊ុនិកណាម្នាក់អាចទទួលបានព័ត៌មានដែលមិនទាន់បង្ហាញជាសាធារណៈពីក្រុមហ៊ុននោះទេ។

**ប្រការ ១១.-**

អភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិក មិនត្រូវមានជាប់ពាក់ព័ន្ធ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬសៃហ្វ៍ឌៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនមិនត្រូវធ្វើការជួញដូរមូលបត្ររបស់ក្រុមហ៊ុនក្នុងរយៈពេល ៖

- ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ។

- ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល រហូតដល់ ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

នៅក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនត្រូវអនុម័ត និងផ្សព្វផ្សាយគោលនយោបាយគ្រប់គ្រងការជួញដូរមូលបត្ររបស់ក្រុមហ៊ុនដែលធ្វើឡើងដោយអភិបាល និងបុគ្គលិក។

**ប្រការ ១២.-**

ភាគហ៊ុនិកត្រូវមានការទទួលខុសត្រូវ ចំពោះការប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់ខ្លួន។ ចំពោះភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុប ត្រូវតែមានកាតព្វកិច្ចផ្ដល់ព័ត៌មានដល់សាធារណជន នៅពេលដែលមានការផ្លាស់ប្ដូរចំនួនភាគហ៊ុនដែលខ្លួនកាន់កាប់ ដូចមានចែងក្នុងអនុក្រឹត្យ។

## ជំពូកទី ៣
## ក្រុមប្រឹក្សាភិបាល

**ប្រការ ១៣.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវមានក្រុមប្រឹក្សាភិបាលដែលដឹកនាំ និងត្រួតពិនិត្យក្រុមហ៊ុន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ ក្រុមប្រឹក្សាភិបាលត្រូវតែជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតរបស់ភាគហ៊ុនិក ដែលចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក។

**ប្រការ ១៤.-**

ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកយ៉ាងតិចបំផុតចំនួន ០៥ (ប្រាំ) រូប និងមិនត្រូវលើសពី ១៥ (ដប់ប្រាំ) រូបឡើយ។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវតែមានអភិបាលឯករាជ្យយ៉ាងតិចចំនួន ១/៥ (មួយភាគប្រាំ) នៃចំនួន

អភិបាលសរុប។ ករណីអភិបាលឯករាជ្យជាជនបរទេស អភិបាលនេះត្រូវមានបទពិសោធន៍ការងារនៅកម្ពុជាយ៉ាងហោចណាស់រយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលក្លាយជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុន។

អភិបាលត្រូវមានការទទួលខុសត្រូវច្បាស់លាស់ ក្នុងន័យថា គ្មានបុគ្គលជាអភិបាលណាម្នាក់ ឬបុគ្គលមួយក្រុមតូចណាមួយ អាចគ្រប់សង្កត់លើការសម្រេចចិត្តរបស់ក្រុមប្រឹក្សា-ភិបាលឡើយ។

**ប្រការ ១៥.-**

ក្រុមប្រឹក្សាភិបាលត្រូវបំពេញតួនាទីរបស់ខ្លួន ប្រកបដោយសុចរិត ជំនាញ និងយកចិត្តទុកដាក់ ដោយអនុវត្តនូវតួនាទីសំខាន់ៗ ដូចខាងក្រោម ៖

១-ត្រូវមានការទទួលខុសត្រូវពេញលេញ និងបម្រើផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុន និងភាគហ៊ុនិក។

២-ត្រូវតែប្រតិបត្តិដោយស្មោះត្រង់ ប្រកបដោយសុឆន្ទៈ និងដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក។

៣-ត្រូវធានាថា ក្រុមហ៊ុនបានធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពជាមួយភាគហ៊ុនិក និងភាគីពាក់ព័ន្ធដទៃទៀត។

៤-ធ្វើការកំណត់ តាមដាន និងវាយតម្លៃយុទ្ធសាស្ត្រ គោលនយោបាយ លក្ខណៈវិនិច្ឆ័យ ប្រសិទ្ធភាពគ្រប់គ្រង និងផែនការធុរកិច្ច។

៥-បង្កើត និងតាមដានការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង។

៦-ផ្តល់នូវភាពជាអ្នកដឹកនាំ ដោយដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រ ព្រមទាំងធានាឱ្យបានថា ធនធានត្រូវបានរៀបចំជាស្រេច ដើម្បីឆ្លើយតបចំពោះគោលដៅដែលបានកំណត់។

៧-អភិបាលមិនត្រូវប្រើអំណាចផ្ទាល់ខ្លួន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាល ទៅគាបសង្កត់បុគ្គលិកជាន់ខ្ពស់ នៅក្នុងការអនុវត្តការងាររបស់គេឡើយ។

**ប្រការ ១៦.-**

ក្រុមប្រឹក្សាភិបាលត្រូវរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់យ៉ាងហោចណាស់ ០១ (មួយ) ដងរៀងរាល់ត្រីមាស។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមដោយផ្ទាល់គ្រប់កិច្ចប្រជុំរបស់ក្រុម-ប្រឹក្សាភិបាលក្រុមហ៊ុន ទាំងសាមញ្ញ និងវិសាមញ្ញ។ ករណីក្រុមហ៊ុនមានអភិបាលឯករាជ្យរាល់ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវតែមានវត្តមានរបស់អភិបាលឯករាជ្យយ៉ាងតិច ០១ (មួយ) រូប។

**ប្រការ ១៧.-**

ក្រុមប្រឹក្សាភិបាលត្រូវមានការទទួលខុសត្រូវ ដោយធានាថា កម្រិតនៃប្រាក់បំណាច់ ឬលាភការត្រូវតែសមល្មមដើម្បីទាក់ទាញ និងរក្សាអភិបាលប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់ ដើម្បីភាពជោគជ័យរបស់ក្រុមហ៊ុន។ សមាមាត្រនៃប្រាក់បំណាច់ និងលាភការរបស់អភិបាលប្រតិបត្តិ ត្រូវតែធ្វើយ៉ាងណាឱ្យមានការជាប់ទាក់ទងរវាងរង្វាន់លើកទឹកចិត្តជាមួយនឹងលទ្ធផលរបស់បុគ្គល ក្រុមការងារ និងមាននិរន្តភាពធុរកិច្ចក្រុមហ៊ុនចំពោះភាគហ៊ុនិក។

ក្រុមហ៊ុនត្រូវមានគោលនយោបាយផ្លូវការ និងមានតម្លាភាពស្តីអំពីលាភការ ដោយត្រូវកំណត់កញ្ចប់លាភការ និងប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ឱ្យបានច្បាស់លាស់។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនត្រូវបង្ហាញដោយឡែកអំពីព័ត៌មានស្តីពីប្រាក់បំណាច់ និងលាភការផ្ទាល់ ឬប្រយោលសរុបរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ រួមទាំងអគ្គនាយក។

**ប្រការ ១៨.-**

អភិបាលត្រូវទទួលបានព័ត៌មានពេញលេញ គ្រប់គ្រាន់ និងទាន់ពេល មុនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តជាគោលការណ៍សម្រាប់ការផ្តល់ព័ត៌មានទាំងនោះជូនក្រុមប្រឹក្សាភិបាល។

បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ជូនក្រុមប្រឹក្សាភិបាលនូវព័ត៌មានពេញលេញ គ្រប់គ្រាន់និងទាន់ពេល។ ករណីចាំបាច់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អ អភិបាលម្នាក់ៗអាចតម្រូវឱ្យបុគ្គលិកជាន់ខ្ពស់ផ្តល់ព័ត៌មានបន្ថែម។

ព័ត៌មានដែលត្រូវផ្តល់ជូនសមាជិកក្រុមប្រឹក្សាភិបាលមានដូចជា សាវតារឿង សេចក្តីពន្យល់លម្អិតពាក់ព័ន្ធនឹងបញ្ហានានា ដែលត្រូវដាក់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ឯកសារផ្តល់ព័ត៌មានថតចម្លង បញ្ជាថវិកាក្រុមហ៊ុន ការព្យាករណ៍ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ។ ពាក់ព័ន្ធនឹងបញ្ជាថវិកា ករណីដែលមានគំលាតណាមួយរវាងគម្រោង និងលទ្ធផលជាក់ស្តែង គឺត្រូវធ្វើការបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់។

**ប្រការ ១៩.-**

អភិបាលត្រូវមានសិទ្ធិដូចខាងក្រោម ៖

១-ទទួលបាននូវរបៀបវារៈ និងព័ត៌មានទាន់ពេល ដើម្បីត្រៀមប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

២-ទទួលបានព័ត៌មានបច្ចុប្បន្នកម្មអំពីក្រុមហ៊ុន។

៣-ជំទាស់ជាលាយលក្ខណ៍អក្សរទៅនឹងសកម្មភាព ឬការសម្រេចចិត្តណាមួយរបស់ក្រុមប្រឹក្សាភិបាល ដោយតម្រូវឱ្យកត់ត្រាឱ្យបានច្បាស់លាស់នូវការបោះឆ្នោតជំទាស់។

៤-ស្នើនូវប្រធានបទពាក់ព័ន្ធណាមួយទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

៥-ជួបជាមួយនឹងបុគ្គលិកជាន់ខ្ពស់ណាម្នាក់តាមការចាំបាច់ ដោយឈរលើភាពសមស្របទៅវិញទៅមក។

៦-ទទួលបានយោបល់លើគ្រប់ភារកិច្ច។

៧-ទទួលបានប្រាក់បំណាច់ ឬលាភការសមរម្យ និងមានតម្លាភាព។

៨-ទទួលបានយោបល់ឯករាជ្យ ប្រសិនបើមានការស្នើសុំ។

**ប្រការ ២០.-**

អភិបាលត្រូវមានមុខងារ និងភារកិច្ច ដូចខាងក្រោម ÷

១-អនុម័តលើគោលនយោបាយ និងនីតិវិធីអនុវត្តសម្រាប់ក្រុមហ៊ុន។

២-ចូលរួមចំណែក និងអនុម័តលើផែនការយុទ្ធសាស្ត្រ។

៣-តាមដាននូវការអនុវត្តគោលនយោបាយ។

៤-ធានាការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។

៥-ទទួលខុសត្រូវចំពោះក្រុមហ៊ុន។

៦-ជ្រើសតាំងនាយកប្រតិបត្តិ។

៧-ធានាសាធនភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន តាមរយៈការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុបានត្រឹមត្រូវ និងការការពារទ្រព្យសកម្មរបស់ភាគហ៊ុនិក។

៨-ផ្តល់នូវភាពជាអ្នកដឹកនាំ ជួយគាំទ្រ និងលើកទឹកចិត្តដល់និយោជិត។

៩-ធានាថា ក្រុមប្រឹក្សាភិបាលមានប្រសិទ្ធភាពក្នុងការដឹកនាំក្រុមហ៊ុន។

១០-ធានានូវការសម្រេចបានគោលដៅរបស់ក្រុមហ៊ុន។

១១-ផ្តល់នូវទស្សនវិស័យស្តីពីប្រសិទ្ធិភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក។

**ប្រការ ២១.-**

ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវចំពោះភាពជោគជ័យរយៈពេលវែងរបស់ក្រុមហ៊ុន ព្រមទាំងចីរភាពនៃរបៀបប្រកួតប្រជែង ដោយធ្វើយ៉ាងណាឱ្យមានសង្គតិភាពជាមួយនឹងការ

ទទួលខុសត្រូវតាមផ្លូវច្បាប់របស់ខ្លួន ហើយត្រូវធ្វើសកម្មភាពណាដែលបម្រើនូវផលប្រយោជន៍ទាំងស្រុងរបស់ក្រុមហ៊ុន និងភាគហ៊ុនិក។

ក្រុមប្រឹក្សាភិបាលត្រូវធានាថា អភិបាលទទួលការបណ្តុះបណ្តាល ដើម្បីធ្វើបច្ចុប្បន្នកម្មអំពីការវិវត្តនៃអភិបាលកិច្ចសាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលមានផលប៉ះពាល់ដល់ដំណើរការធុរកិច្ចក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលគួរបញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំនូវព័ត៌មានស្តីពីការបណ្តុះបណ្តាលអភិបាល។

## ប្រការ ២២.-

សមាជិកក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ចធ្វើការវិនិច្ឆ័យ និងធ្វើសកម្មភាពដោយឯករាជ្យ និងប្រកាន់យកជំហានសមស្របនានា ដើម្បីធានាភាពរឹងមាំនៃការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល។ កាតព្វកិច្ចទាំងនោះ រួមមាន ÷

១-ធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនទាំងមូល និងភាគហ៊ុនិក។

២-ប្រើប្រាស់អំណាចឱ្យចំគោលដៅដើម្បីផលប្រយោជន៍របស់ក្រុមហ៊ុនទាំងមូល។

៣-មិនត្រូវផ្ទេរអំណាច លើកលែងតែមានការអនុញ្ញាតត្រឹមត្រូវ និងមានភារកិច្ចដើម្បីអនុវត្ត។

៤-អនុវត្តការងារដោយប្រុងប្រយ័ត្ន ប្រកបដោយភាពជំនាញ និងភាពវាងវៃ។

៥-ដោះស្រាយរាល់ទំនាស់ផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍របស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ។

៦-មិនត្រូវធ្វើប្រតិបត្តិការណាដែលអភិបាលមានផលប្រយោជន៍ លើកលែងតែស្របតាមគោលនយោបាយ និងនីតិវិធីដែលបានអនុម័ត។

៧-មិនត្រូវកេងយកផលប្រយោជន៍ក្នុងមុខតំណែងជាអភិបាល។

៨-មិនត្រូវប្រើប្រាស់ខុសទិសដៅចំពោះព័ត៌មានដែលទទួលបានពីក្រុមហ៊ុន។

៩-មិនត្រូវទទួលយកអំណោយពីតតិយជន ដែលផ្តល់ឱ្យដោយសារតែមុខតំណែងជាអភិបាល។

១០-អនុវត្តតាមលក្ខន្តិកៈក្រុមហ៊ុន និងសេចក្តីសម្រេចផ្សេងៗរបស់ក្រុមហ៊ុន។

១១-ធ្វើសេចក្តីប្រកាសអំពីទំនាស់ផលប្រយោជន៍របស់ខ្លួនដែលកើតមានពាក់ព័ន្ធនឹងក្រុមហ៊ុន។

**ប្រការ ២៣.-**

ក្រុមប្រឹក្សាភិបាលត្រូវតែអនុម័តក្រមសីលធម៌ សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ហើយត្រូវបង្ហាញជាសាធារណៈ។

**ប្រការ ២៤.-**

ក្រុមប្រឹក្សាភិបាលត្រូវតែងតាំងលេខាធិការរបស់ក្រុមហ៊ុន ដើម្បីជាជំនួយការក្នុងការអនុវត្តការងារ។ លេខាធិការរបស់ក្រុមហ៊ុនត្រូវមានលក្ខណសម្បត្តិល្អ មានសញ្ជាតិខ្មែរ ជាបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដោយអនុវត្តការងារល្អ ស្មោះត្រង់ និងមានគោលជំហរនឹងនរពាក់ព័ន្ធនឹងភារកិច្ចរបស់ខ្លួន។

**ប្រការ ២៥.-**

លេខាធិការក្រុមហ៊ុនត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល តាមរយៈប្រធានក្រុមប្រឹក្សាភិបាល ហើយត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ÷

១-ត្រូវបង្កើតទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់នានារបស់ក្រុមហ៊ុន។

២-ត្រូវគាំទ្រដល់កិច្ចដំណើរការការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

៣-ត្រូវធ្វើបច្ចុប្បន្នកម្មនូវរាល់ការវិវត្តច្បាប់ និងបទប្បញ្ញត្តិ ដែលអាចមានផលប៉ះពាល់ដល់ក្រុមប្រឹក្សាភិបាល និងប្រតិបត្តិការរបស់ក្រុមហ៊ុន។

៤-ត្រូវធ្វើបច្ចុប្បន្នកម្មអំពីអភិបាលកិច្ចសាជីវកម្ម និងការវិវត្តនៃការទទួលខុសត្រូវសង្គម។

៥-ត្រូវបង្កលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីគាំទ្រដល់ដំណើរការនៃការសម្រេចចិត្ត។

៦-ត្រូវចាត់ចែង រៀបចំ នីតិវិធី និងរក្សាទុក កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក។

## ជំពូកទី ៤
## ការជ្រើសរើស និងការបញ្ចប់តំណែងសមាជិកក្រុមប្រឹក្សាភិបាល

**ប្រការ ២៦.-**

នៅពេលដែលក្រុមហ៊ុនបង្កើតគណៈកម្មាធិការតែងតាំង រាល់ការជ្រើសតាំងបេក្ខភាពអភិបាលត្រូវធ្វើឡើងដោយគណៈកម្មាធិការតែងតាំងដូចមានចែងក្នុងប្រការ ៣៦ នៃប្រកាសនេះ។ ការជ្រើសតាំងត្រូវធ្វើឡើងតាមនីតិវិធីផ្លូវការ និងមានតម្លាភាព ដោយត្រូវធានានូវភាពត្រឹមត្រូវ និងឯករាជ្យ។

គណៈកម្មាធិការតែងតាំងត្រូវតែបញ្ចូលនូវនីតិវិធី ដើម្បីអនុញ្ញាតឱ្យភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចអាចស្នើឡើងនូវបេក្ខភាពអភិបាល។ អភិបាលទាំងអស់ត្រូវបានបោះឆ្នោតជ្រើសរើសដោយភាគហ៊ុនិក។

**ប្រការ ២៧.-**

គណៈកម្មាធិការតែងតាំងត្រូវពិចារណាលើលក្ខខណ្ឌគុណវុឌ្ឍិរបស់បេក្ខភាពអភិបាលដូចខាងក្រោម ÷

១-នីត្យានុកូលភាព ទេពកោសល្យ សមត្ថភាព និងសុចរិតភាព។

២-មានការប្តេជ្ញាចិត្តខ្ពស់ដើម្បីបម្រើផលប្រយោជន៍របស់ក្រុមហ៊ុននិងភាគហ៊ុនិក។

៣-មានពេលវេលា ថាមពល និងការគាំទ្រដើម្បីបំពេញគ្រប់ភារកិច្ច រួមមានការជួបប្រជុំ និងការចូលរួមសន្និសីទ។

៤-មានលទ្ធភាពធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព។

៥-មានលទ្ធភាពអាចធ្វើការប្រកបដោយប្រសិទ្ធភាពឆ្ពោះទៅរកគោលដៅរួមរបស់ក្រុមហ៊ុន និងភាគហ៊ុនិក ។

៦-យល់អំពីតួនាទីរបស់ខ្លួនជាអភិបាលក្នុងធុរកិច្ច។

៧-មានបទពិសោធន៍យ៉ាងតិច ០៣ (បី) ឆ្នាំ ក្នុងវិស័យពាក់ពន្ធ័ជាមួយនឹងមុខតំណែងរបស់ខ្លួន

៨-បង្ហាញអំពីភាពជាអ្នកដឹកនាំ។

៩-មានលទ្ធភាពដើរតួនាទីយ៉ាងសកម្មនៅពេលដែលក្រុមហ៊ុនជួបប្រទះស្ថានភាពវិករ។

**ប្រការ ២៨.-**

គណៈកម្មាធិការតែងតាំងមិនអាចជ្រើសតាំងបេក្ខភាពអភិបាល នូវបុគ្គលដែលស្ថិតក្នុងស្ថានភាព ដូចខាងក្រោម ÷

១-បុគ្គលនោះធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ។

២-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការមានសមត្ថកិច្ច ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងការបំភាន់ ការកេងបន្លំ ការក្លែងបន្លំ ការសូកប៉ាន់ ការរំលោភលើសេចក្តីទុកចិត្ត ការញុះញង់ ការសមគំនិត ឬការចូលរួមក្នុងការប្រព្រឹត្តអំពើល្មើសណាមួយ។

៣-បុគ្គលដែលតុលាការបានប្រកាសក្ស័យធនក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ ចុងក្រោយ។

៤-បុគ្គលដែលត្រូវបានផ្តន្ទាទោសដោយតុលាការបរទេស ឬត្រូវបានដាក់ទណ្ឌកម្មដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស។

៥-បុគ្គលដែលជាប់ពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

**ប្រការ ២៩.-**

អភិបាលមិនត្រូវបានបញ្ឈប់ពីតំណែង ឬត្រូវបានបណ្តេញចេញ ដោយគ្មានមូលហេតុត្រឹមត្រូវ និងសមស្របឡើយ និងត្រូវជូនដំណឹងជាមុនទៅអភិបាលនោះដើម្បីជ្រាបជាព័ត៌មាន។

មូលដ្ឋានសម្រាប់ការបញ្ឈប់ ឬការបណ្តេញចេញពីតំណែង រួមមាន ÷

១-ការមិនបង្ហាញព័ត៌មានពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍។

២-ករណីអវត្តមាន ឬមិនបានចូលរួមទាំងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក លើសពី ៥០ (ហាសិប) ភាគរយឡើងទៅ ក្នុង ០១ (មួយ) ឆ្នាំសារពើពន្ធ ទោះបីក្នុងហេតុផលអ្វីក៏ដោយ។

៣-ករណីត្រូវបានព្យួរ បញ្ឈប់ ឬបណ្តេញចេញពីតំណែងជាអភិបាលក្នុងក្រុមហ៊ុនណាមួយ។

៤-អភិបាលឯករាជ្យបានក្លាយជាបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតរបស់ក្រុមហ៊ុន។

៥-អភិបាលឯករាជ្យមានភាគហ៊ុនរបស់ក្រុមហ៊ុនលើសពី ០១ (មួយ)ភាគរយឡើងទៅ។

៦-ត្រូវបានផ្តន្ទាទោសពីបទល្មើសណាមួយ ដូចមានចែងក្នុងប្រការ ២៨។

## ជំពូកទី ៥
## អភិបាលឯករាជ្យ

**ប្រការ ៣០.-**

អភិបាលឯករាជ្យត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ ដោយត្រូវបំពេញលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ÷

១-មិនត្រូវបានជួលដោយក្រុមហ៊ុន ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ។

២-មិនមានទំនាក់ទំនងជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់ដ៏សំខាន់របស់ក្រុមហ៊ុន។

៣-មិនមានកិច្ចសន្យាផ្ទាល់ខ្លួនជាមួយក្រុមហ៊ុន ឬជាមួយបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន។

៤-មិនជាប់ទាក់ទងជាមួយអង្គការ ឬសមាគមមិនស្វែងរកប្រាក់ចំណេញណាមួយ ដែលធ្លាប់ទទួលមូលនិធិពីក្រុមហ៊ុន។

៥-មិនមែនជាសមាជិកក្រុមគ្រួសាររបស់បុគ្គលដែលធ្លាប់ធ្វើជាអភិបាលឱ្យក្រុមហ៊ុន ឬធ្លាប់បានជួលដោយក្រុមហ៊ុន ឱ្យធ្វើជាអគ្គនាយក ឬបុគ្គលិកជាន់ខ្ពស់ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ។

៦-មិនធ្លាប់ធ្វើជាសវនករ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ ឬកំពុងធ្វើជាសវនករឱ្យក្រុមហ៊ុន ។

**ប្រការ ៣១.-**

អភិបាលឯករាជ្យត្រូវមានកាតព្វកិច្ចចូលរួមនៅគ្រប់ការសម្រេចចិត្តសំខាន់ៗរបស់ក្រុមហ៊ុន ព្រមទាំងត្រូវតាមដានត្រួតពិនិត្យ និងគាំទ្រដល់បុគ្គលិកជាន់ខ្ពស់។ ក្រុមប្រឹក្សាភិបាលត្រូវបញ្ជាក់ថា អភិបាលឯករាជ្យមិនមានទំនាក់ទំនងសំខាន់ជាមួយបុគ្គលិកជាន់ខ្ពស់ និងបុគ្គលិកដទៃទៀត ដែលអាចនាំឱ្យមានផលប៉ះពាល់ដល់ការវិនិច្ឆ័យប្រកបដោយឯករាជ្យ ដើម្បីបម្រើផលប្រយោជន៍របស់ក្រុមហ៊ុន និងបំពេញនូវតួនាទី ដូចខាងក្រោម ÷

១-ចូលរួមនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលដោយនាំមកនូវការសម្រេចចិត្តឯករាជ្យទៅលើបញ្ហានានា ដូចជា យុទ្ធសាស្ត្រ គោលនយោបាយ ការអនុវត្ត គណនេយ្យភាព ធនធាន ការជ្រើសតាំងបុគ្គលិកជាន់ខ្ពស់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការដឹកនាំ។

២-ត្រូវឈានមុខគេក្នុងការដោះស្រាយ និងទប់ស្កាត់នូវទំនាស់ផលប្រយោជន៍ជាសក្តានុពលដែលនឹងអាចកើតឡើង។

៣-បម្រើការងារក្នុងគណៈកម្មាធិការនានា ដូចជា គណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំង ប្រសិនបើមាន ព្រមទាំងគណៈកម្មាធិការផ្សេងៗទៀត។

៤-ត្រួតពិនិត្យយ៉ាងហ្មត់ចត់នូវការអនុវត្តរបស់ក្រុមហ៊ុន ដើម្បីសម្រេចបានតាមគោលបំណង និងគោលដៅដែលបានឯកភាព និងតាមផែនការអនុវត្តការងារ។

**ប្រការ ៣២.-**

អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ ដែលនាំឱ្យរារាំងដល់ឯករាជ្យភាពរបស់ខ្លួនឡើយ។

អភិបាលឯករាជ្យ ៖

១-មិនត្រូវកាន់កាប់ភាគហ៊ុនក្រុមហ៊ុនលើសពី ០១ (មួយ) ភាគរយនៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនឡើយ។

២-ត្រូវដាក់លិខិតបញ្ជាក់ថា មិនមានផលប្រយោជន៍សំខាន់ណាមួយនៅក្នុងក្រុមហ៊ុននៅពេលត្រូវបានតែងតាំង។

បុគ្គលមិនមានគុណវុឌ្ឍិជាអភិបាលឯករាជ្យ ប្រសិនបើខ្លួនគេ ឬសមាជិកគ្រួសាររបស់គេត្រូវបាន ៖

ក-ផ្តល់ឱ្យធ្វើការ ដោយ/ជា បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

ខ-បម្រើការងារជាសវនករផ្ទៃក្នុង ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុន។

គ-កំពុងបម្រើការងារជាសវនករផ្ទៃក្នុង ឬជាសវនករឯករាជ្យរបស់ក្រុមហ៊ុនដែលចូលរួមធ្វើសវនកម្មក្រុមហ៊ុននោះ ឬធ្លាប់បានធ្វើសវនកម្មផ្ទាល់លើក្រុមហ៊ុននោះ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ។

ឃ-កំពុងបម្រើការងារជាបុគ្គលិកជាន់ខ្ពស់ក្នុងក្រុមហ៊ុនធានារ៉ាប់រងដែលកំពុងធានារ៉ាប់រងឱ្យក្រុមហ៊ុននោះ។

ង-ផ្តល់ឱ្យធ្វើការ ដោយ/ជា បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលបុគ្គលិកជាន់ខ្ពស់នោះធ្លាប់ជាសមាជិកគណៈកម្មាធិការតបស្នងរបស់ក្រុមហ៊ុននោះ។

ច-បម្រើការងារជាបុគ្គលិកជាន់ខ្ពស់របស់អង្គភាព ឬអង្គការដែលទទួលបានវិភាគទានពីក្រុមហ៊ុន។

## ជំពូកទី ៦
## គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល

**ប្រការ ៣៣.-**

ដើម្បីធានានូវអភិបាលកិច្ចសាជីវកម្មល្អ ក្រុមប្រឹក្សាភិបាលត្រូវបង្កើតនូវគណៈកម្មាធិការមួយចំនួន ដូចខាងក្រោម ៖

-គណៈកម្មាធិការសវនកម្ម

-គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ករណីទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈមានចំនួនចាប់ពី ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល។ ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល អាចបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ទៅតាមការចាំបាច់។

ដោយឡែក ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការតែងតាំង និងគណៈកម្មាធិការផ្សេងទៀត ទៅតាមការចាំបាច់ និងតាមការណែនាំរបស់ **គ.ម.ក.**។

**ប្រការ ៣៤.-**

គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ និងសមាជិកដទៃទៀតត្រូវមានការយល់ដឹងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវតួនាទី និងភារកិច្ចជាអាទិ៍ ដូចខាងក្រោម ៖

-ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

-ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង

-ពិនិត្យការធ្វើសវនកម្មខាងក្រៅ

-រាយការណ៍ទៅឱ្យក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន។

**ប្រការ ៣៥.-**

គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវមានតួនាទីគន្លឹះក្នុងការគ្រប់គ្រងហានិភ័យ នៅក្នុងកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុន។ គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិច ០៣ (បី) រូប ដែលមានអភិបាលឯករាជ្យជាប្រធាន។ យ៉ាងហោចណាស់សមាជិក ០១ (មួយ) រូប ត្រូវមានឯកទេស និងបទពិសោធន៍ខាងហិរញ្ញវត្ថុ ឬគ្រប់គ្រងហានិភ័យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល។ តួនាទី និងភារកិច្ចអាចមានជាអាទិ៍ ដូចខាងក្រោម ÷

-ការវិភាគហានិភ័យ (Risk Analysis) រួមមាន ការពិពណ៌នាហានិភ័យ (Risk Description) ការកំណត់អត្តសញ្ញាណហានិភ័យ (Risk Identification) ការប៉ាន់ស្មានអំពីហានិភ័យ (Risk Estimation)

-ការវាយតម្លៃអំពីហានិភ័យ (Risk Evaluation)

-ការរាយការណ៍អំពីហានិភ័យ (Risk Reporting)

-ការលើកវិធានការទប់ទល់ហានិភ័យ (Risk Treatment)

-ការតាមដានអំពីហានិភ័យ (Risk Monitoring)

ចំពោះក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈដែលមានទ្រព្យសកម្មតិចជាង ២០០.០០០.០០០.០០០ (ពីររយពាន់លាន) រៀល តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យអាចអនុវត្តដោយគណៈកម្មាធិការសវនកម្ម។

**ប្រការ ៣៦.-**

ករណីដែលមានគណៈកម្មាធិការតែងតាំង គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងតិចចំនួន ០៣ (បី) រូប ដែលសមាជិកទាំងអស់ត្រូវតែជាអភិបាលមិនប្រតិបត្តិ ដោយក្នុងនោះត្រូវមានសមាជិកយ៉ាងតិច ០១ (មួយ) រូប ជាអភិបាលឯករាជ្យ។

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ចដែលត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយរាប់បញ្ចូលនូវការពិនិត្យ និងការវាយតម្លៃអំពីគុណវុឌ្ឍិបេក្ខភាពអភិបាល ឬបុគ្គលិកជាន់ខ្ពស់ដែលត្រូវតែងតាំងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

គណៈកម្មាធិការតែងតាំងអាចមានការទទួលខុសត្រូវផងដែរ ចំពោះការរៀបចំនីតិវិធី ឬការពិនិត្យឡើងវិញ និងការផ្តល់អនុសាសន៍ សម្រាប់លាភការ និងប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។

## ជំពូកទី ៧
## ការត្រួតពិនិត្យ

**ប្រការ ៣៧.-**

ក្រុមប្រឹក្សាភិបាលត្រូវមានគណនេយ្យភាពចំពោះភាគហ៊ុនិក ហើយបុគ្គលិកជាន់ខ្ពស់ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ជូនភាគហ៊ុនិកនូវការវាយតម្លៃប្រចាំឆមាស ឬការកំណត់ផ្សេងទៀតដោយ **គ.ម.ក.** ឬវិធាននៃការចុះបញ្ជីលក់មូលបត្រ ដែលអាចទទួលយកបាន និងមានតុល្យភាព អំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន។ បុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវការវាយតម្លៃប្រចាំត្រីមាសដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន ហើយត្រូវតែរាយការណ៍ជូនក្រុមប្រឹក្សាភិបាលជារៀងរាល់ខែ អំពីហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុន។

**ប្រការ ៣៨.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវមានសវនកម្មផ្ទៃក្នុង។ សវនករផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម និងត្រូវមានការទទួលខុសត្រូវ និងភារកិច្ច ដូចខាងក្រោម ៖

១-បង្ហាញពីការវាយតម្លៃដែលអាចទទួលយកបាន និងមានតុល្យភាពអំពីប្រសិទ្ធភាព ស្ថានភាព និងការរំពឹងទុករបស់ក្រុមហ៊ុន។

២-រាយការណ៍អំពីដំណើរការធុរកិច្ចរបស់ក្រុមហ៊ុន និងបញ្ហាជាសក្តានុពល។

៣-រក្សាភាពរឹងមាំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីការពារផលប្រយោជន៍របស់ភាគហ៊ុនិក និងការវិនិយោគរបស់ភាគីពាក់ព័ន្ធ និងទ្រព្យសកម្មរបស់ក្រុមហ៊ុន។

៤-អនុវត្តការស៊ើបអង្កេតសវនកម្មផ្ទៃក្នុងគ្របដណ្តប់ទៅលើការវាយតម្លៃពីភាពសមស្រប និងប្រសិទ្ធភាពនៃអភិបាលកិច្ច ប្រតិបត្តិការ និងប្រព័ន្ធព័ត៌មាន ដោយរាប់បញ្ចូលទាំងការការពារទ្រព្យសកម្ម និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ។

៥-ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម និងបុគ្គលិកជាន់ខ្ពស់នូវរបាយការណ៍ប្រចាំឆ្នាំស្តីអំពីសកម្មភាពពាក់ព័ន្ធនឹងផែនការសវនកម្ម និងយុទ្ធសាស្ត្រដែលបានទទួលការយល់ព្រម

ពីគណៈកម្មាធិការសវនកម្ម។ របាយការណ៍ប្រចាំឆ្នាំនេះត្រូវរាប់បញ្ចូលទាំងការប្រឈមហានិភ័យ បញ្ហាត្រួតពិនិត្យ បញ្ហាអភិបាលកិច្ចសាជីវកម្ម និងបញ្ហាផ្សេងទៀតដែលស្នើដោយក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់។ គណៈកម្មាធិការសវនកម្មត្រូវតែផ្តល់របាយការណ៍ឱ្យភាគហ៊ុនិករបស់ក្រុមហ៊ុន ដែលជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។

៦-គណៈកម្មាធិការសវនកម្មត្រូវធានាថាសវនករផ្ទៃក្នុងមានសិទ្ធិទទួលបានព័ត៌មានទាំងស្រុងអំពីកំណត់ត្រា ទ្រព្យ និងបុគ្គលិកពាក់ព័ន្ធនឹងសកម្មភាពសវនកម្ម និងធានាថាសកម្មភាពសវនកម្មផ្ទៃក្នុង មិនទទួលរងការជ្រៀតជ្រែកក្នុងការកំណត់ពីវិសាលភាពនៃការត្រួតពិនិត្យ ការអនុវត្តការងារ និងការបញ្ចូនលទ្ធផលនៃការត្រួតពិនិត្យ។

**ប្រការ ៣៩.-**

ប្រធានសវនកម្មផ្ទៃក្នុងត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម ៖

១-មានសញ្ញាបត្រកម្រិតឧត្តមសិក្សាឡើងទៅដោយមានការបណ្តុះបណ្តាល ព្រមទាំងបទពិសោធន៍ខាងសវនកម្ម។

២-មានចំណេះដឹងស្តីពីបទដ្ឋានបច្ចេកទេស និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន។

៣-មានសមត្ថភាពក្នុងការដឹកនាំ និងចាត់ចែងបុគ្គលិកសវនកម្ម។

៤-ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមស្តង់ដារពាក់ព័ន្ធនឹងសវនកម្ម។

៥-មានជំនាញទំនាក់ទំនងល្អក្នុងការងារ។

៦-មានភាពស្មោះត្រង់ និងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ។

**ប្រការ ៤០.-**

ប្រធានសវនកម្មផ្ទៃក្នុងមិនត្រូវអនុវត្តការងារដែលបង្កើតឱ្យមានទំនាស់ផលប្រយោជន៍។ ប្រធានសវនកម្មផ្ទៃក្នុងត្រូវអនុវត្តតាមគោលការណ៍ ដូចខាងក្រោម ៖

១-របាយការណ៍សវនកម្មដែលធ្វើដោយសវនករផ្ទៃក្នុងត្រូវផ្ញើទៅឱ្យគណៈកម្មាធិការសវនកម្ម ព្រមទាំងបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធ និងបុគ្គលិកជាន់ខ្ពស់ដែលទទួលខុសត្រូវក្នុងផ្នែកដែលត្រូវបានធ្វើសវនកម្ម។

២-រាល់ការរកឃើញនានាដែលអាចមានផលប៉ះពាល់ដល់ដំណើរការរបស់ក្រុមហ៊ុនត្រូវបញ្ជូនទៅឱ្យគណៈកម្មាធិការសវនកម្ម។

៣-ត្រូវជួបជាមួយគណៈកម្មាធិការសវនកម្មយ៉ាងហោចណាស់ ០១ (មួយ) ដង ក្នុង ០១ (មួយ) ឆ្នាំ ដោយពុំចាំបាច់មានវត្តមានរបស់បុគ្គលិកជាន់ខ្ពស់ ។

៤-អនុវត្តការងារផ្សេងទៀតដែលគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាលប្រគល់ជូន។

**ប្រការ ៤១.** -

សវនកម្មហិរញ្ញវត្ថុត្រូវអនុវត្តដោយសវនករឯករាជ្យដែលជ្រើសរើសដោយក្រុមប្រឹក្សា-ភិបាល តាមសំណើរបស់គណៈកម្មាធិការសវនកម្មក្នុងចំណោមក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលស្គាល់ដោយ **គ.ម.ក.**។ អន្តរកម្មរវាងក្រុមហ៊ុនសាមី និងសវនករឯករាជ្យត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់គណៈកម្មាធិការសវនកម្ម។ ដើម្បីកម្រិតហានិភ័យនៃទំនាស់ផលប្រយោជន៍ រាល់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម និងកម្រៃដែលត្រូវបង់ទៅឱ្យសវនករឯករាជ្យសម្រាប់សេវាសវនកម្ម និងសេវាមិនមែនសវនកម្ម ត្រូវតែទទួលបានការយល់ព្រមជាមុនពីគណៈកម្មាធិការសវនកម្ម ហើយត្រូវបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវផ្លាស់ប្តូរក្រុមហ៊ុនគណនេយ្យជំនាញដែលធ្វើសវនកម្ម ក្នុងរយៈពេលមិនលើសពី ០៣ (បី) ឆ្នាំ។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ មិនត្រូវប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនគណនេយ្យជំនាញដែលឡើងវិញ ក្នុងរយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់ពីកិច្ចសន្យាប្រើប្រាស់សេវាកម្មមុនត្រូវបានបញ្ចប់។ ក្នុងគោលបំណងជៀសវាងនូវទំនាស់ផលប្រយោជន៍ ក្រុមហ៊ុនគណនេយ្យជំនាញមិនត្រូវផ្តល់សេវាកម្ម ដូចជា សវនករផ្ទៃក្នុង សេវាកម្មបញ្ជិកាគណនេយ្យ ការបង្កើតនិងអនុវត្តន៍ប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ សេវាកម្មវាយតម្លៃ សេវាកម្មពាក់ព័ន្ធនឹងការកំណត់សោធននិវត្តន៍បុគ្គលិករបស់ក្រុមហ៊ុន និងសេវាកម្មដទៃទៀតដែលអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

**ប្រការ ៤២.** -

រាល់ការសុំឈប់ ការបញ្ឈប់ ឬការផ្អាកសេវាកម្មសវនកម្មរបស់ក្រុមហ៊ុនគណនេយ្យជំនាញត្រូវមានការបញ្ជាក់នូវហេតុផលឱ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** ភ្លាមក្នុងរយៈពេលមិនលើសពី ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ របាយការណ៍ប្រចាំឆ្នាំត្រូវបញ្ចូល ការពិភាក្សាអំពីការមិនយល់ស្របរបស់...

អតីតក្រុមហ៊ុនគណនេយ្យជំនាញទៅលើបញ្ហាគោលការណ៍ និងការអនុវត្តគណនេយ្យ ទៅលើការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងវិសាលភាពនៃសវនកម្ម ឬលើនីតិវិធីសវនកម្ម ដែលមិនមានដំណោះស្រាយធ្វើឱ្យពេញចិត្តអតីតក្រុមហ៊ុនគណនេយ្យជំនាញ។

**ប្រការ ៤៣.-**

សវនករឯករាជ្យត្រូវមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម ÷

១-ត្រូវផ្តល់នូវទស្សនៈឯករាជ្យ និងប្រាកដនិយមថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ក្រុមហ៊ុន ស្របទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ ដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ត្រូវអនុវត្តតាមស្តង់ដារសវនកម្ម ដែលបានអនុម័តឱ្យប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៨
## ភាគីពាក់ព័ន្ធ

**ប្រការ ៤៤.-**

ឥណទាយក បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ ឬមានកិច្ចសន្យាជាមួយក្រុមហ៊ុន ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ រាល់ភាគីពាក់ព័ន្ធទាំងអស់របស់ក្រុមហ៊ុនត្រូវទទួលបាននូវការការពារសិទ្ធិ។ ក្រុមហ៊ុនត្រូវធានាការការពារសិទ្ធិដល់ភាគីពាក់ព័ន្ធជាអាទិ៍ ដូចខាងក្រោម ÷

១-ត្រូវមានគោលនយោបាយគ្រប់គ្រងយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីគាំទ្រ និងការពារសិទ្ធិរបស់ភាគីពាក់ព័ន្ធ។

២-ត្រូវធានាការអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

៣-មិនត្រូវធ្វេសប្រហែសចំពោះការទទួលខុសត្រូវសង្គម ដូចជាការការពារអ្នកប្រើប្រាស់ និងការការពារបរិស្ថាន។

៤-ទទួលស្គាល់ និងការពារសិទ្ធិដាច់ចេញពីគ្នានៅពេលដែលបុគ្គលជាភាគីពាក់ព័ន្ធ និងជាភាគហ៊ុនិក។

**ប្រការ ៤៥.-**

ក្រុមហ៊ុនត្រូវផ្ដល់ឱ្យភាគីពាក់ព័ន្ធដូចជា ឥណទាយក និងនិយោជិត នូវព័ត៌មានពាក់ព័ន្ធដែលចាំបាច់ដើម្បីតាមដាននូវដំណើរការរបស់ក្រុមហ៊ុន ព្រមទាំងត្រូវការពារសិទ្ធិរបស់ពួកគេ។

## ជំពូកទី ៩
## ការបង្ហាញព័ត៌មាន និងតម្លាភាព

**ប្រការ ៤៦.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងក្រុមហ៊ុនតាមរយៈយន្តការទីផ្សារ ដូចជា ៖

១-យន្តការត្រូវធ្វើឡើងតាមរយៈនីតិវិធីប្រកបដោយយុត្តិធម៌ និងមានតម្លាភាពនៅពេលដែលមានសកម្មភាពនាំឱ្យមានការផ្លាស់ប្ដូរក្នុងការត្រួតត្រាក្រុមហ៊ុន ដូចជា ការទទួលកាន់កាប់បន្ត (Takeovers) ការរួមបញ្ចូល (Mergers) ការទិញយក (Acquisitions) និងការផ្ទេរអាជីវកម្ម (Transfers of business)។

២-យន្តការទាក់ទងនឹងសកម្មភាពការពារក្រុមហ៊ុនឱ្យផុតពីការការត្រួតត្រា ដោយធ្វើយ៉ាងណាសកម្មភាពការពារនោះមិនត្រូវឱ្យមានការលះបង់ផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក។ ប្រសិនបើសកម្មភាពការពារនោះតម្រូវឱ្យមានការលះបង់ផលប្រយោជន៍របស់ក្រុមហ៊ុន និងភាគហ៊ុនិក ការលះបង់ផលប្រយោជន៍នោះត្រូវមានការយល់ព្រមពីភាគហ៊ុនិក។

៣-យន្តការចាំបាច់នានាក្នុងការចាត់វិធានការប្រឆាំងនឹងការទទួលកាន់កាប់បន្តអមិត្ត (Hostile takeovers) ដូចជា ការទិញភាគហ៊ុនត្រឡប់មកវិញក្នុងបំណង ដើម្បីការពារការត្រួត-ត្រាក្រុមហ៊ុនដែលការទិញភាគហ៊ុនត្រឡប់មកវិញនេះត្រូវធ្វើការប្រកាសឱ្យបានលម្អិត ដើម្បីឱ្យភាគីពាក់ពន្ធ័យល់ដឹងពីហេតុផលនិងអាចព្យាករណ៍បាននូវផលវិបាកដែលអាចកើតឡើង។

**ប្រការ ៤៧.-**

ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មាន ទាន់ពេល និងមានប្រសិទ្ធភាព ដែលតម្រូវដោយច្បាប់និងបទប្បញ្ញត្តិ និងពត៌មានផ្សេងទៀតដែលអាចមានផលប៉ះពាល់ដល់ការសម្រេចចិត្តរបស់ភាគហ៊ុនិក និងភាគីពាក់ពន្ធ័ដទៃទៀត។

ព័ត៌មានសំខាន់ៗដែលទាក់ទងនឹងអភិបាលកិច្ចសាជីវកម្ម ដែលក្រុមហ៊ុនត្រូវបង្ហាញ រួមមាន ៖

១-សមាសភាពក្រុមប្រឹក្សាភិបាល រួមទាំងអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ អភិបាលឯករាជ្យ រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល រចនាសម្ព័ន្ធគ្រប់គ្រង គោលនយោបាយលើកទឹកចិត្ត គោលនយោបាយពាក់ព័ន្ធទំនាស់ផលប្រយោជន៍ និងក្រមសីលធម៌របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

២-សិទ្ធិ តួនាទី និងភារកិច្ច និងសកម្មភាពនៃគណៈកម្មាធិការនានារបស់ក្រុម-ប្រឹក្សាភិបាល។

៣-សកម្មភាពរបស់អភិបាលម្នាក់ៗ និងក្រុមប្រឹក្សាភិបាល។

៤-ដំណើរការប្រព័ន្ធបោះឆ្នោតត្រួត ករណីទទួលបានការអនុម័តពីភាគហ៊ុនិក។

**ប្រការ ៤៨.-**

ក្រុមហ៊ុនត្រូវរៀបចំព័ត៌មានដើម្បីធ្វើការបង្ហាញក្នុងទម្រង់ងាយយល់ ដោយជៀសវាងការប្រើប្រាស់ពាក្យដែលមានន័យមិនច្បាស់លាស់ និងពាក្យបច្ចេកទេសស្មុគស្មាញ។ ការបង្ហាញព័ត៌មានជាសាធារណៈត្រូវធ្វើយ៉ាងណាងាយទទួលបាន និងមានតម្លៃទាប។ ចំពោះពាក្យបច្ចេកទេសស្មុគស្មាញទាំងនោះ ក្រុមហ៊ុនត្រូវរៀបចំឱ្យមានការពន្យល់ភ្ជាប់មកជាមួយដើម្បីឱ្យសាធារណជនទូទៅបានយល់។

ករណីឯកសារដែលត្រូវបង្ហាញធ្វើឡើងជាភាសាបរទេសក្រុមហ៊ុនត្រូវតែរៀបចំបកប្រែឯកសារទាំងនោះមកជាភាសាខ្មែរដោយភ្ជាក់ងារបកប្រែដែលទទួលស្គាល់ដោយ **គ.ម.ក.**។

ក្រុមហ៊ុនត្រូវចាត់តាំងបុគ្គលិកម្នាក់ ដើម្បីទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មាន រួមទាំងការរាយការណ៍ទៅផ្សារ និង **គ.ម.ក.** ដោយក្រុមប្រឹក្សាភិបាល និងត្រូវមានប្រព័ន្ធត្រួតពិនិត្យព័ត៌មានផ្ទៃក្នុង (Internal Information Control System) ដែលអាចបញ្ជូនព័ត៌មានសំខាន់ៗរបស់ក្រុមហ៊ុនឱ្យបានឆាប់រហ័សដល់បុគ្គលិកនោះ។ ដើម្បីបញ្ជូនព័ត៌មានដល់សាធារណជនឱ្យបានទាន់ពេល ត្រឹមត្រូវ និងមានប្រសិទ្ធភាព បុគ្គលិកដែលទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានត្រូវមានសិទ្ធិទទួលបានព័ត៌មានភ្លាមៗរបស់ក្រុមហ៊ុន។

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**ប្រការ ៤៩. –**

បុគ្គលណាមួយដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការរដ្ឋបាល ដូចខាងក្រោម ៖

-ការព្រមាន

-ការណែនាំឱ្យកែតម្រូវកំហុស

-ការព្យួរជាបណ្ដោះអាសន្ន ឬការបញ្ឈប់ការងាររបស់អភិបាល និង/ឬ បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

-ការព្យួរ ឬការលុបចោលការចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន

-ការព្យួរ ឬការបញ្ឈប់ការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៥០. –**

បុគ្គលណាមួយដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ៥០.០០០.០០០ (ហាសិបលាន) រៀល។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៥១. –**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំ ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ភាគី ឬបុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងសាធារណជន។

**ប្រការ ៥២. –**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៣.** –

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋាន អង្គភាពដទៃទៀត ចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មករា ឆ្នាំ២០១០

**ណាត ឈន់**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- -ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងយុត្តិធម៌
- -ធនាគារជាតិនៃកម្ពុជា
- -គណៈកម្មការមូលបត្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ ៥៣
  "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:........003/១៥........គ.ម.ក/ប្រ.ក.

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh,
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh,

- បានឃើញប្រកាសលេខ ០០៤/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- បានឃើញប្រកាសលេខ ០០១/១២ ស្ន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំការពិនិត្យ វិសោធនកម្ម និងអនុម័ត លើវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសនេះ ត្រូវជំនួសប្រកាសលេខ ០០៤/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងប្រកាសលេខ ០០១/១២ ស្ន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ..០០៦/១៥...

ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

# វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីគោលការណ៍នានាដែលចាំបាច់សម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា ផ.ម.ក.) អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងវិធាននេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

-បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ សំដៅដល់បុគ្គលដែលមានបំណងធ្វើសំណើចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ដែលមិនធ្លាប់បានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-បុគ្គលចុះបញ្ជីលក់មូលបត្រសំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយបានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ សំដៅដល់ភាគហ៊ុនិក និងបុគ្គលពាក់ព័ន្ធពិសេសនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេរបស់បុគ្គលស្នើសុំចុះបញ្ជីនេះ។ ក្នុងករណីនេះ ភាគហ៊ុនដែលកាន់កាប់ក្នុងគោលបំណងវិនិយោគជាកញ្ចប់ដោយវិនិយោគិនស្ថាប័ន ត្រូវបានដកចេញពីការគណនាចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ៣០ (សាមសិប) ភាគរយ ឡើងទៅ នៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ ឡើងទៅនៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

-ភាគហ៊ុនិកយុទ្ធសាស្ត្រ (Strategic Shareholders) សំដៅដល់ភាគហ៊ុនិកដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់នៃបុគ្គលចុះបញ្ជីលក់មូលបត្រ និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលទាំងនេះ។

-មូលធនភាគហ៊ុនិក (Shareholders Equity) សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

## ជំពូកទី ២
## លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

### ប្រការ ៣.- ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

### ប្រការ ៤.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម មក ផ.ម.ក. ៖

១- ព័ត៌មានទូទៅ÷

ក- ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងអក្សរឡាតាំង។

ខ- អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

គ- កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ឃ- កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ង- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

ច- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២-ព័ត៌មានអំពីបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ÷ អត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

៣-ព័ត៌មានអំពីភាគហ៊ុនិក÷ អត្តសញ្ញាណភាគហ៊ុនិក។

៤-ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ខ- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ។

គ- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។

ឃ-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៥-ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក-ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច។

ខ-ព័ត៌មានអំពីហានិភ័យ។

៦-ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧-ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

## ប្រការ ៥.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី

ផ.ម.ក. ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រទៅបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ១ (មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។

ករណី ផ.ម.ក. បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ផ.ម.ក. ត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រអាចស្នើសុំការបំភ្លឺពី ផ.ម.ក.។ បុគ្គលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក គ.ម.ក. ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេច។

## ប្រការ ៦.- ការដាក់ផ្ញើមូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលទទួលបានការអនុញ្ញាតលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រត្រូវដាក់ផ្ញើមូលបត្រដែលមានស្រាប់នៅប្រតិបត្តិកររក្សាទុកមូលបត្រ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងមុនដំណើរការនៃការកំណត់ថ្លៃលក់មូលបត្រ។

# ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

### ប្រការ ៧.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

បន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ ៨.- លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

ឃ- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

២. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយ ដូចខាងក្រោម÷

- ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (Positive Operating Cashflow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។

គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ១០០ (មួយរយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមសំណើរបស់ ផ.ម.ក.។

ឃ-ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ (ដប់) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមសំណើរបស់ ផ.ម.ក.។

## ប្រការ ៩.- លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវមិនមែនជាតួលេខ ដូចខាងក្រោម÷

១-មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ១ (មួយ) ឆ្នាំចុងក្រោយ រហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

២-មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

## ប្រការ ១០.- ឯកសារដែលត្រូវផ្តល់ជូន ផ.ម.ក.

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារ ដូចខាងក្រោម÷

១-ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ គ.ម.ក.។

២-ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។

៣-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

៤-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

៥-របាយការណ៍បែងចែកមូលបត្រ។

៦-លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

## ប្រការ ១១.- ការចុះបញ្ជីលក់មូលបត្រជាផ្លូវការ

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញដូចមានចែងក្នុងប្រការ១០នៃវិធាននេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ ១២.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ

មុននឹងត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ តាមគំរូដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

### ប្រការ ១៣.- ការមិនសងត្រលប់នៅវិញនូវឯកសារពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជី និង ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ

រាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រដែលតម្រូវដោយវិធាននេះ មិនត្រូវប្រគល់ជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រវិញនោះទេ ទោះបីពាក្យស្នើសុំនោះត្រូវបានបដិសេធ ឬត្រូវដកទៅវិញក៏ដោយ។

## ជំពូកទី ៤

## លក្ខខណ្ឌ និងនីតិវិធីនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

### ប្រការ ១៤.- លក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

ផ.ម.ក ត្រូវដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនូវមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្នុងករណីណាមួយដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. ៖

១- បុគ្គលចុះបញ្ជីលក់មូលបត្រមិនបានដាក់របាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធចុងក្រោយ ក្នុងអំឡុងពេល ៣ (បី) ខែ បន្ទាប់ពីកាលវសានដែលកំណត់ដោយ គ.ម.ក.។

២- យោបល់របស់សវនករនៅក្នុងរបាយការណ៍សវនកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ មានយោបល់ជំទាស់ ឬបដិសេធ សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ។

៣- របាយការណ៍ប្រចាំឆ្នាំបានបង្ហាញថា មូលធនភាគហ៊ុនិករបស់បុគ្គលចុះបញ្ជីលក់មូលបត្របានថយចុះក្នុងរយៈពេល ២ (ពីរ) ឆ្នាំជាប់គ្នា ច្រើនជាង ៥០ (ហាសិប) ភាគរយ។

៤- បុគ្គលចុះបញ្ជីលក់មូលបត្របានបំពានលើកាតព្វកិច្ចផ្តល់ព័ត៌មានជាញឹកញាប់។

៥- បុគ្គលចុះបញ្ជីលក់មូលបត្រមិនអាចទូទាត់ជាស្ថាពរលើផលបត្រពាណិជ្ជកម្ម ឬមូលប្បទានបត្រដែលខ្លួនបានចេញ ឬប្រតិបត្តិការរបស់ខ្លួនជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៦-បុគ្គលចុះបញ្ជីលក់មូលបត្រស្ថិតក្រោមករណីណាមួយនៃមូលហេតុរំលាយ ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវបានដាក់កំហិតក្នុងការផ្ទេរកម្មសិទ្ធិភាគហ៊ុន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តនោះទេ ចំពោះករណីដែលការដាក់កំហិតត្រូវបានចាត់ទុកថាមិនប៉ះពាល់ដល់ការជួញដូរនៅលើទីផ្សារ ពីព្រោះការដាក់កំហិតនេះត្រូវធ្វើឡើងដោយច្បាប់ផ្សេងទៀតដែលមិនពាក់ព័ន្ធដល់វិស័យមូលបត្រ។

## ប្រការ ១៥.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្រដែលដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

នៅពេលដកចេញពីបញ្ជីនូវមូលបត្រចុះបញ្ជីលក់មូលបត្រជាផ្លូវការណាមួយ ផ.ម.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្រដែលពាក់ព័ន្ធ។

ករណីដកចេញពីបញ្ជីនូវមូលបត្រណាមួយ ផ.ម.ក. អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្រនោះ សម្រាប់រយៈពេល ១០ (ដប់) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

# ជំពូកទី ៥
# ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់

## ប្រការ ១៦.- កាតព្វកិច្ច និងនីតិវិធីផ្តល់ព័ត៌មាន

បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ជូន ផ.ម.ក. ឱ្យទាន់ពេលវេលានូវឯកសារផ្តល់ព័ត៌មានជាប្រចាំ និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ប្រការ ១៧.- កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យា ដូចខាងក្រោម÷

១. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុន ដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែដំបូង នៃរយៈពេល ១ (មួយ) ឆ្នាំ។ សម្រាប់រយៈពេលនៅសល់ ៦ (ប្រាំមួយ) ខែទៀត ភាគហ៊ុនិកនេះ អាចធ្វើការលក់ភាគហ៊ុនរបស់ខ្លួនក្នុងកម្រិតអតិបរមា ៥០ (ហាសិប) ភាគរយ នៃភាគហ៊ុនដែលខ្លួនកាន់កាប់។

២.ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ និងភាគហ៊ុនិកយុទ្ធសាស្ត្រ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែ ។

កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុនដូចមានចែងក្នុងកថាខណ្ឌទី១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

## ប្រការ ១៨.- ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរជាថ្មី

ផ.ម.ក អាចព្យួរការជួញដូរមូលបត្រក្នុងករណីណាមួយដូចខាងក្រោម÷

១- ករណីភាគហ៊ុនចុះបញ្ជីលក់មួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២- ករណីដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការណាមួយនៃប្រការ ១៤ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្រមិនទាន់បានអនុវត្ត។

៣- ករណីមានការបំបែក ឬការបង្រួមមូលបត្រកម្មសិទ្ធិ ឬតាមសំណើរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤- ករណីមានការសម្រេចពីអគ្គនាយកនៃ គ.ម.ក.។

ការព្យួរការជួញដូរមូលបត្រ ស្របតាមកថាខណ្ឌទី ១ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច លើកលែងតែមានការសម្រេចបន្ថែមពីអគ្គនាយកនៃ គ.ម.ក.។

## ប្រការ ១៩.- ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម ត្រូវអនុវត្តនីតិវិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិដូចមានចែងក្នុងវិធាននេះ។

## ប្រការ ២០.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ករណីមានការកែប្រែឈ្មោះបុគ្គលចុះបញ្ជីលក់មូលបត្រ តម្លៃចារឹករបស់មូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ ឬចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបំពេញនីតិវិធីកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.។

## ប្រការ ២១.- ការផ្លាស់ប្តូរទីផ្សារចុះបញ្ជី

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងផ្លាស់ប្តូរទីផ្សារចុះបញ្ជីពីទីផ្សារកំណើន ទៅទីផ្សារគោលត្រូវបំពេញតាមលក្ខខណ្ឌចុះបញ្ជីនៃទីផ្សារដែលបុគ្គលចុះបញ្ជីមានបំណងផ្ទេរទៅ និងត្រូវដាក់ពាក្យស្នើសុំផ្ទេរទីផ្សារមកកាន់ ផ.ម.ក ។

### ប្រការ ២២.- ការជូនដំណឹងអំពីការក្លែងបន្លំផ្ទេរមូលបត្រ

ករណីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមក គ.ម.ក. អំពីករណីមានការក្លែងបន្លំក្នុងការផ្ទេរមូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជូនដំណឹងភ្លាមមក ផ.ម.ក.។ ការជូនដំណឹងមក ផ.ម.ក. នេះ អាចធ្វើឡើងតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

## ជំពូកទី ៦
## ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

### ប្រការ ២៣.- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវបង់ថ្លៃសេវា ផ.ម.ក. លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ទីផ្សារគោល និង ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ទីផ្សារកំណើន ។

### ប្រការ ២៤.- ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រដោយផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ១០.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០៣០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០២៥% |
| ពី | ២០០.០០០.០០០.០០១៛ | ដល់ | ៤០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ៤០០.០០០.០០០.០០០៛ | ០,០១០% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល (ថ្លៃអប្បបរមា) ឬ ចំនួន ០,០២៥ (សូន្យក្បៀសសូន្យម្ភៃប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដោយយកចំនួនណាមួយដែលធំជាងគេ។

### ប្រការ ២៥.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ៣.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០២០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ២០០.០០០.០០០.០០០៛ | ០,០០៥% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.០០០.០០០ (បួនលាន) រៀល (ថ្លៃសេវាប្រចាំឆ្នាំអប្បបរមា) ឬ ចំនួន ០,០១៥ (សូន្យក្បៀសសូន្យដប់ប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដោយយកចំនួនណាមួយដែលធំជាងគេ។

* * *

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:.......០០៥/១៥.........គ.ម.ក/ប្រ.ក.

# ប្រកាស
## ស្តីពី
## ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណ:
* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១-ច្បាប់ សំដៅដល់ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ÷

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ក្រុមហ៊ុនសក្ដានុពល សំដៅដល់ក្រុមហ៊ុនដែលមានលទ្ធភាពអាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចជាសហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុនដែលទើបបង្កើតថ្មី និងក្រុមហ៊ុនដែលមានកំណើនខ្ពស់ ឬអាចមានកំណើនខ្ពស់។

៥-ក្រុមហ៊ុនហូលឌីង (Holding Company) សំដៅដល់ក្រុមហ៊ុនដែលកាន់កាប់បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ឬក្រុមហ៊ុនសម្ព័ន្ធ ដោយមានភាពជាម្ចាស់កម្មសិទ្ធិដោយកាន់កាប់ភាគហ៊ុនចំនួនច្រើន

ឬចំនួនតិចដែលមានសិទ្ធិបោះឆ្នោតគ្រប់គ្រាន់លើក្រុមហ៊ុនដែលកាន់កាប់។

៦- ភាគហ៊ុនបុរិមា (Preference share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៧- ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់ជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៨- ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩- ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

១០- ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១១- មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១២- សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូល-បត្រកម្មសិទ្ធិជាឯកជន÷

១- សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២- សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវរាយការណ៍ពីលទ្ធផល

ឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ **គ.ម.ក.**។

២- ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជារួមទាំងផ្ដល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច។

៣- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្ដានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្ដល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥- ត្រូវមានឯកសារផ្ដល់ព័ត៌មានដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ។

### ប្រការ ៥.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ÷

១- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

ក្រុមហ៊ុនបោះផ្សាយត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៦ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចខាងក្រោម÷

១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ

២- ព័ត៌មានស្តីពីកត្តាហានិភ័យ

៣- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤- ផែនការវិនិយោគ

៥- ការពិពណ៌នាអំពីធុរកិច្ច

៦- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ

៧- ការពិពណ៌នាអំពីអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

៨- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១០- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២- ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨- សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩- ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

**ប្រការ ៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ រួមទាំងព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម÷

១- ឈ្មោះក្រុមហ៊ុនបោះផ្សាយ

២- ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣- តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤- ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៥- ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៦- កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧- សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម÷

១- ហានិភ័យហិរញ្ញវត្ថុ

២- ហានិភ័យសេដ្ឋកិច្ច

៣- ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៤- ហានិភ័យផ្សេងៗតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវប្រើប្រាស់សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុនបោះផ្សាយ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

**ប្រការ ១១.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

**ប្រការ ១២.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការពិពណ៌នាអំពីធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា÷

១-កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

២-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៣-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៤-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៥-វិធីសាស្ត្រចែកចាយផលិតផល។

៦-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៧-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៨-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៩-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើរួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬសេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃចំនួនទឹកប្រាក់សរុបលើផលិតផល ឬសេវាទាំងអស់ដែលបានទិញដោយក្រុមហ៊ុនបោះផ្សាយ ដោយ

បញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១១- ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១២- ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១៣- សក្តានុពលនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៤- ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១- លទ្ធផលប្រតិបត្តិការ។

២- សន្ទនីយភាព និងប្រភពទុន។

៣- ការស្រាវជ្រាវ និងការអភិវឌ្ឍ។

៤- ព័ត៌មាននិន្នាការ និងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់ សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

**ប្រការ ១៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម÷

១- ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្មវត្ថុទាំងនោះ។

២- សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្មវត្ថុទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្មវត្ថុ។

៣- ការវាយតម្លៃលើអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលទទួល

បានការទទួលស្គាល់ពី **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ ប្រសិនមាន។

៤-ប្រសិនបើអចលកម្មរូបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

**ប្រការ ១៥.-**

ករណីមានការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ឯកសារផ្ដល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្ដីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ដោយបង្ហាញនូវ÷

១-ព័ត៌មានសង្ខេបពីការវាយតម្លៃ ឬការវាយតម្លៃឡើងវិញរួមមានតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ដោយត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

២-ហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។

៣-អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្ដល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដូចខាងក្រោម÷

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៦-សេចក្ដីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

ឯកសារផ្ដល់ព័ត៌មានត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម÷

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្ដីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញអំពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ដែលបានកើតឡើងនៅក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំចុងក្រោយ ដូចខាងក្រោម÷

១-បណ្ដឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្ដោះអាសន្នរបស់តុលាការមានសមត្ថកិច្ចចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញអំពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដោយពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្ដល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់-ព័ន្ធ ដូចខាងក្រោម÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ រួមទាំងអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីក្រុមហ៊ុនបោះ-ផ្សាយ និងអភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

២-បុគ្គលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣- សមាជិកគ្រួសារផ្ទាល់របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤- បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥- បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះ-ផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម÷

១- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣- ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤- ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥- ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

**ប្រការ ២០.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដោយត្រូវបញ្ជាក់នូវ÷

១- កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២- ថ្លៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣- ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤- ថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាននូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទ និងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោលក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីកម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋាន ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិ ដើម្បីធ្វើសំណើលក់។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីសិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើ

លក់ ដូចខាងក្រោម÷

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជំរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Information) និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Information) ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៧.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

**ប្រការ ២៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ២៩ .-**

ក្រុមហ៊ុនបោះផ្សាយត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម÷

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤- លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦- កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ប្រសិនមាន។

៧- ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ។

៨- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩- កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១១- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤- កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនមាន។

១៥- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៤ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.** ។

១៦- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់បំពេញ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.** ។

១៧- ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

**ប្រការ ៣០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយផ្តល់ឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស ឬសេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ

**គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីក្រុមហ៊ុនបោះផ្សាយមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ ដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១-ក្រុមហ៊ុនបោះផ្សាយមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-ក្រុមហ៊ុនបោះផ្សាយស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយទូទាត់សងបំណុល។

៥-ក្រុមហ៊ុនបោះផ្សាយ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ÷

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុឬវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមិនទាន់មានលក្ខណៈគ្រប់គ្រាន់

ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្នុងរយៈពេល ២(ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៣.-**

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី÷

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី **គ.ម.ក.**។

**ប្រការ ៣៤.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៨ និងប្រការ ៣៩ នៃប្រកាសនេះ។

**ប្រការ ៣៥.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៦.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៧.-**

ក្រុមហ៊ុនមូលបត្រត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់-

ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ឬភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៨.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើចំពោះសំណើលក់មូលបត្រជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-លេខស៊េរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានអាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ។

**ប្រការ ៤១.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារ-

ណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ និងអនុក្រឹត្យ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៤.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះ ព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដស្ងូ (Road Show) និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្រុមហ៊ុនបោះផ្សាយត្រូវត្រៀមឯកសារផ្ដល់ព័ត៌មានសម្រាប់ផ្ដល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៥.-**

រយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្ដើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១-ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២-ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣-ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤-កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥-សេចក្ដីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការអនុញ្ញាតពី **គ.ម.ក.** រួចហើយ។

៦-សេចក្ដីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្ដល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧-កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនឹងចាប់ផ្ដើម។

៨-សេចក្ដីថ្លែងដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកទៅលើឯកសារផ្ដល់ព័ត៌មាន។

ឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមពីនេះក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិចឱ្យដូចគ្នានឹងឯកសារផ្ដល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## កម្រៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៦.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១២.០០០.០០០

(ដប់ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៧**.-

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមត្រូវបង់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៨**.-

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំពិនិត្យឡើងវិញលើឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៩.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាដូចមានចែងក្នុងប្រការ ៤៦ ប្រការ ៤៧ និងប្រការ ៤៨ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យក្រុមហ៊ុនបោះផ្សាយវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៥០.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម÷

១- ការស្នើឱ្យដាក់អនុស្សារណៈ។

២- ការព្រមាន ឬដាស់តឿន។

៣- ការកត់សម្គាល់ជាសាធារណៈហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤- ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥- ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦- ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥១.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀលដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ ៥២.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួល

ដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធអ្នកចូលរួមក្នុងទីផ្សារមូលបត្រប្រតិស្រុត និងសាធារណជន។

**ប្រការ ៥៣.-**

ប្រកាសនេះត្រូវជំនួសប្រកាសលេខ ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៥៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ